សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

## បទល្មើសរំលោភសេពសន្ថវៈ
## ក្នុងទំនាក់ទំនងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ក. ស្រ៊ាង គឹមស្រ៊ាន**
**ស៊ឹម រិទ្ធី**

សាស្ត្រាចារ្យណែនាំ
លោក **គង់ សាផន**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **កញ្ញា ស្រ៊ាង គីមស្រ៊ាន** និង **លោក ស៊ឹម រិទ្ធី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ ២០១៥ -២០១៦។

សូមលំឱនកាយដើម្បីសម្តែងនូវការគោរព ការដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះ

- លោកឪពុកឈ្មោះ **ស្រ៊ុន ស្រ៊ាង** និងអ្នកម្តាយឈ្មោះ **ឡាយ ឡៃខេង**
- លោកឪពុកឈ្មោះ **ស៊ឹម ឡៃអ៊ី** និងអ្នកម្តាយឈ្មោះ **ជួង នី**

ដែលបានផ្តល់កំណើត និងពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រលាញ់អនុគ្រោះ ព្រហ្មវិហារធម៌ និងអប់រំទូន្មានឲ្យដើរតាមគន្លងធម៌ ព្រមទាំងទំនុកបំរុង ថវិការ និងសិក្ខូបករណ៍ ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ ឧត្តមសិក្សា។ ជាពិសេសកូនសូមអរគុណចំពោះ ការផ្តល់កម្លាំងចិត្ត និងភាពអត់ធ្មត់គ្រប់បែបយ៉ាង។ ការលះបង់ទាំងនេះ គឺជាតម្លៃដែលមិនអាចកាត់ថ្លៃបានក្នុងជីវិតរបស់កូន។ លោកឪពុក អ្នកម្តាយគឺជាព្រះរស់របស់កូន។

- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការ និងសាស្ត្រាចារ្យទាំងអស់ដែលបានបង្ហាត់បង្រៀន និងអប់រំទូន្មាន ដល់យើងខ្ញុំក្នុងរយៈពេល ៤ឆ្នាំកន្លងមក។
- លោកសាស្ត្រាចារ្យ **គង់ សាផន** ជាសាស្ត្រាចារ្យណែនាំសារណាររបស់យើងខ្ញុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីធ្វើការណែនាំ ផ្តល់យោបល់ និងកែនូវកំហុស ដើម្បីជួយឲ្យសារណារបស់យើងខ្ញុំលេចជារូបរាងឡើង។
- លោកចៅក្រម **ហេង សុខណា** ដែលបានផ្តល់យោបល់ និងឯកសារមួយចំនួន ដើម្បីឲ្យសារណារបស់យើងខ្ញុំកាន់តែប្រសើរឡើង។
- លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ ដែលអនុញ្ញាតឲ្យយើងខ្ញុំបានចូលធ្វើការស្រាវជ្រាវ និងផ្តល់នូវឯកសារមួយចំនួន។

ជាចុងក្រោយយើងខ្ញុំ សូមប្រសិទ្ធិពរជ័យ ដល់អ្នកដែលបានរៀបរាប់ខាងលើជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាឃ្លាតឡើយ។

# អារម្ភកថា

ជាបឋមយើងខ្ញុំសូមគោរពដល់សាស្ត្រាចារ្យ និងអ្នកអានទាំងអស់ដែលបានអានសៀវភៅរបស់យើងខ្ញុំ។ ក្រោយពីការសិក្សាអស់រយៈពេល៤ឆ្នាំកន្លងទៅលើមុខវិជ្ជានីតិព្រហ្មទណ្ឌ គឺជាមុខវិជ្ជាមួយដែលមានភាពលំបាកក្នុងការស្វែងយល់ ដោយផ្អែកទៅលើមូលដ្ឋានគតិយុត្ត ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ។ ទោះបីជាកន្លងមកមាននិស្សិតជាច្រើនដែលបានបញ្ចប់ការសិក្សា និងបានធ្វើសារណាដែលសរសេរទាក់ទងច្រើនទៅនិងនីតិព្រហ្មទណ្ឌ។ ប៉ុន្តែទោះបីជាយ៉ាងណា ក៏ដោយយើងឃើញថាមិនសូវមានឯកសារ និង មិនមានការចងក្រងជាសៀវភៅស្តីអំពីបទល្មើសរំលោភសេពសន្ថវៈក្នុងទំនាក់ទំនងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរទេ។ ហេតុដូច្នេះហើយទើបខ្ញុំលើកយកយកប្រធានបទនេះដើម្បីបញ្ចេញសមត្ថភាព និងចំណេះដឹងដល់មិត្តអ្នកអានទាំងអស់។

ជាទូទៅយើងឃើញថាព្រះរាជាអាជ្ញា និងចៅក្រមស៊ើបសួរពិតជាមានទំនាក់ទំនងគ្នាយ៉ាង`អាជ្ញា និងចៅក្រមស៊ើបសួររួចទៅហើយដោយនីតិវិធីត្រូវធ្វើឡើងដោយរលូនដោយសឹងតែមិនមានបញ្ហាចោទឡើង។ ទោះជាយ៉ាងនេះក្តី ក៏នៅតែមានបញ្ហាខ្លះបានចោទឡើងដោយយើងពុំបានគិតទុកជាមុន ដូច្នេះទើបយើងចង់ដឹងថាតើមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះដែលកើតឡើងក្នុងទំនាក់ទំនងអ្នកទាំងពីរ? ដោយហេតុនេះហើយទើបយើងខ្ញុំជ្រើសរើសយកប្រធានបទនេះដើម្បីធ្វើការពង្រីកចំណេះដឹងរបស់យើងខ្ញុំបន្ថែមទៀត។ ទោះបីជាប្រធានបទមួយនេះ ហាក់បីដូចជាមានវិសាលភាពធំទូលំទូលាយបន្តិចក៏ដោយ តែពុំមានឯកសារគ្រប់គ្រាន់ដើម្បីធ្វើជាទុនក្នុងការបង្កើតនូវគំនិតទៅលើសារណាដែរ ប៉ុន្តែយើងខ្ញុំពិតជាពេញចិត្តនឹងប្រធានបទមួយនេះខ្លាំងណាស់ ពីព្រោះវាគឺជាប្រធានបទមួយដែលថ្មីស្រឡាងសម្រាប់ពួកខ្ញុំដើម្បីធ្វើការស្រាវជ្រាវ និងយល់កាន់តែច្បាស់ពីសមត្ថភាពពិត។

ជាចុងក្រោយនេះ យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាសៀវភៅមួយក្បាលនេះ ពិតជាមានផលប្រយោជន៍ក្នុងការស្រាវជ្រាវដល់មិត្តនិស្សិត និងអ្នកអានទាំងអស់គ្នា ហើយយើងខ្ញុំទាំងពីរនឹងរង់ចាំទទួលដោយក្តីសប្បាយរីករាយជាទីបំផុត ចំពោះមតិរិះគន់ពីអ្នកទាំងអស់គ្នាជានិច្ច ។ ពីព្រោះថាការរិះគន់ដើម្បីស្ថាបនា គឺជារឿងមួយដែលល្អបំផុត និង វាកាន់តែធ្វើឲ្យប្រធានបទរបស់ខ្ញុំកាន់តែមានភាពស៊ីជម្រៅថែមទៀត។

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១ បទល្មើសរំលោភសេពសន្ថវៈ** ........ ៤

**កថាខណ្ឌទី១ ធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ** ........ ៤

១. ធាតុនីត្យានុកូល ........ ៤

២.ធាតុសត្យានុម័ត ........ ៥

៣.ធាតុអត្ថនោម័ត ........ ៦

**កថាខណ្ឌទី២ មូលហេតុដែលនាំឲ្យមានបទល្មើសរំលោភសេពសន្ថវៈ** ........ ៧

១. កត្តាមនុស្ស ........ ៧

១.១ ជនល្មើស ........ ៧

១.២ ជនរងគ្រោះ ........ ៨

២. កត្តាសង្គម ........ ៩

២.១ ការហូរចូលនូវវប្បធម៌បរទេស ........ ៩

២.២ និទណ្ឌភាព ........ ១០

**កថាខណ្ឌទី៣ ដំណោះស្រាយគតិយុត្ត** ........ ១១

១. អនុវត្តបទដ្ឋានគតិយុត្តឲ្យបានតឹងរឹង ........ ១១

១.១ ច្បាប់ ........ ១២

១.១.១ ក្រមព្រហ្មទណ្ឌ ........ ១២

១.១.២ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ........ ១៣

២. ស្ថាប័នអនុវត្តច្បាប់ ........ ១៤

២.១ នគរបាលយុត្តិធម៌ ........ ១៤

២.២ ស្ថាប័នតុលាការ ........ ១៥

**ជំពូកទី២ អំពីព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ** ........ ១៧
**កថាខណ្ឌទី១ អំពីព្រះរាជអាជ្ញា** ........ ១៧
**១. បណ្ដឹងអាជ្ញា** ........ ១៨
១.១ ការចាប់ផ្ដើមបណ្ដឹងអាជ្ញា ........ ១៩
១.២ ការរលត់បណ្ដឹងអាជ្ញា ........ ១៩
**២. បណ្ដឹងបរិហារ** ........ ២០
២.១ បណ្ដឹងបរិហារដោយនគរបាលយុត្តិធម៌ ........ ២០
២.២ បណ្ដឹងដោយជនរងគ្រោះ ........ ២១
**៣. គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់** ........ ២១
៣.១ ការបើកការស៊ើបសួរ ........ ២១
៣.២ ការតម្កល់រឿងទុកឥតចាត់ការ ........ ២២
៣.២.១ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ........ ២២
៣.២.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ........ ២៣
**កថាខណ្ឌទី២ អំពីចៅក្រមស៊ើបសួរ** ........ ២៤
**១. សមត្ថកិច្ចចៅក្រមស៊ើបសួរ** ........ ២៤
១.១ សមត្ថកិច្ចដែនដី ........ ២៤
១.២ សមត្ថកិច្ចតាមការចាត់តាំង និងចែកសំណុំរឿងដោយប្រធានតុលាការ ........ ២៥
**២. ការបើកការស៊ើបសួរ** ........ ២៥
២.១ វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ........ ២៥
២.១.១ ការជូនដំណឹងអំពីការដាក់ស្ថិតក្រោមការពិនិត្យ ........ ២៦
២.១.២ ការសួរចម្លើយ ........ ២៧
២.១.៣ ការឆែកឆេរ និងការចាប់យកវត្ថុតាង ........ ២៨

២.១.៤ កោសលវិច័យ............................................................................................................២៩
២.១.៥ ការស្តាប់ទូរស័ព្ទ...........................................................................................................៣៣
២.១.៦ ដីកាចាត់ឲ្យស៊ើបសួរជំនួស...............................................................................................៣៣
២.២ វិធានការនិរន្តរាយ.................................................................................................................៣៥
២.២.១ ដីកាបង្គាប់ឲ្យចូលខ្លួន.......................................................................................................៣៦
២.២.២ ដីកាបង្គាប់ឲ្យនាំខ្លួន.........................................................................................................៣៧
២.២.៣ ដីកាបង្គាប់ឲ្យចាប់ខ្លួន.......................................................................................................៣៨
២.២.៤ ដីកាបង្គាប់ឲ្យឃុំខ្លួន.........................................................................................................៤០
២.៣ ការត្រួតពិនិត្យតាមផ្លូវតុលាការ..............................................................................................៤២
២.៣.១ បែបបទនៃការដាក់ស្ថិតក្រោមការពិនិត្យ..............................................................................៤៣
២.៣.២ អានុភាពនៃការដាក់ឲ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ.................................................៤៤
**៣. ការបិទការស៊ើបសួរ**.................................................................................................................៤៤
៣.១ ដីកាសម្រេចលើកលែងការចោទប្រកាន់.....................................................................................៤៥
៣.២ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ.......................................................................................៤៦
**ជំពូកទី៣ បទល្មើសរំលោភសេពសន្ថវៈក្នុងទំនាក់ទំនងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ**.........................................................................................................................................៤៧
**កថាខណ្ឌទី១ ទំនាក់ទំនងក្នុងដំណាក់កាលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**..៤៧
១. ការអនុវត្តតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ.......................................................................៤៨
២. ការបើកការស៊ើបសួរនូវអង្គហេតុថ្មី.............................................................................................៤៨
**កថាខណ្ឌទី២ ទំនាក់ទំនងក្នុងដំណាក់កាលបើកការស៊ើបសួរ**.................................៤៩
១. ការសម្រេចដោះលែងជនត្រូវចោទ...............................................................................................៥០
១.១ ការដោះលែងជនត្រូវចោទនៅក្រៅឃុំដោយបណ្តឹងរបស់ព្រះរាជអាជ្ញា...........................................៥១
១.២ ការដោះលែងជនត្រូវចោទនៅក្រៅឃុំដោយបណ្តឹងរបស់ជនត្រូវចោទ............................................៥១

២. ការត្រួតពិនិត្យតាមផ្លូវតុលាការ ..... ៥២
**កថាខណ្ឌទី៣ ទំនាក់ទំនងក្នុងដំណាក់កាលបិទការស៊ើបសួរ** ..... ៥៣
១. ដីកាលើកលែងការចោទប្រកាន់ ..... ៥៤
១.១ ការបើកការស៊ើបសួរលើកស្តុតាងថ្មី ..... ៥៤
១.២ ការប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ..... ៥៥
១.៣ ការណីមិនមែនជាបទល្មើសព្រហ្មទណ្ឌ ..... ៥៥
២. ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ..... ៥៦
សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ..... ៥៩
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

**ទិដ្ឋភាពទូទៅនៃប្រធានបទៈ** ប្រទេសនីមួយៗតែងតែមានច្បាប់សម្រាប់ប្រជាជនរបស់គេ ត្រូវតែគោរព និងអនុវត្តតាម ច្បាប់ទាំងនោះ ធ្វើឲ្យមានសមភាព មិនប្រកាន់ពូជសាសន៍ វណ្ណៈ ជំនឿ និងភាសាឡើយពោលគឺបុគ្គលទាំងឡាយត្រូវតែគោរពសិទ្ធិសេរីភាពរបស់អ្នកដ៏ទៃ ដែលជាគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់។ ប៉ុន្តែផ្ទុយមកវិញ បទល្មើសតែងតែកើតឡើងដែលបង្កឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ សាធារណៈ សន្តិសុខសង្គម ទំនៀមទម្លាប់ ប្រពៃណី និងសីលធម៌ក្នុងប្រទេសជាតិរបស់ខ្លួន។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាយើង បទល្មើសតែងតែកើតឡើងជាញឹកញាប់មានដូចជា អំពើឃាតកម្ម អំពើជួញដូរមនុស្ស អំពើអាជីវកម្មផ្លូវភេទ និងបទល្មើសរំលោភសេពសន្ថវៈជាដើម។

**លក្ខណៈពិសេសនៃប្រធានបទៈ** ដោយហេតុបែបនេះហើយទើបប្រទេសនីមួយៗ ត្រូវការវិធានការណ៍ជាចាំបាច់ក្នុងការទប់ស្កាត់បទល្មើសទាំងនេះ។ ក្នុងនោះយើងសំឡឹងឃើញថាប្រទេសកម្ពុជា មានបទល្មើសរំលោភសេពសន្ថវៈបានកើនឡើងជាហូរហែរ ដែលជាក្តីបារម្ភរបស់រដ្ឋាភិបាលក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងប្រជាជនទាំងមូល។ ម្យ៉ាងវិញទៀត នីតិវិធីសម្រាប់ដោះស្រាយរឿងក្តីនេះមានការទាក់ទងពីស្ថាប័នមួយទៅស្ថានប័នមួយ ក្នុងនោះយើងខ្ញុំបានធ្វើការផ្តោតសំខាន់ទៅលើព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរនៅក្នុងករណីបទល្មើសរំលោភសេពសន្ថវៈ ដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ពីព្រោះអ្នកទាំងពីរនេះហើយ ដែលជាតួអង្គយ៉ាងសំខាន់ក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដែលមានលក្ខណៈគតិយុត្ត និងមានការប្រមូលផ្តុំនូវសំណុំរឿងក្តីទាំងអស់ដែលជាផលវិបាកនៅក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរក្នុងការដោះស្រាយ និងចាត់ការនៃរឿងក្តីនេះផងដែរ។

**លំនាំដំណោះស្រាយៈ** ស្ថាប័នតុលាការជា ស្ថាប័នមួយដែលទទួលស្គាល់ថាជាស្ថាប័នក្នុងការស្វែងរកយុត្តិធម៌ និងជាអ្នកមានសិទ្ធិអំណាចដាក់ទោសទៅលើបុគ្គលគ្រប់រូបដែលបានប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ ដែលជាក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋក៏ដូចជា ជនរងគ្រោះ។ ដូច្នេះហើយ ដើម្បីឲ្យក្តីសង្ឃឹមដ៏មុតមាំនេះអាចកើតឡើងបានត្រូវធ្វើការការពារ និងទប់ស្កាត់បទល្មើសកុំឲ្យកើតឡើងច្រើនជាងនេះទៀត ដោយត្រូវតែធ្វើការរឹតបន្តឹងនូវច្បាប់ដោយដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរចំពោះជនដែលបានប្រព្រឹត្តបទល្មើស។ ជាពិសេសយន្តការនៃការដោះស្រាយរបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរត្រូវធ្វើតាមនីតិវិធី និងធ្វើការតាមដានស៊ើបអង្កេតយ៉ាងហ្មត់ចត់ដោយមានការសហការគ្នា

ជាមួយអាជ្ញាធរមានសមត្ថកិច្ចក៏ដូចជាជនរងគ្រោះជាដើម ដើម្បីធ្វើការបង្ក្រាបទៅលើបទល្មើសរំលោភសេពសន្ថវៈនេះ។

**ចំណោទបញ្ហា:** បច្ចុប្បន្នទោះបីជាមានស្ថាប័ន និងអង្គការជាច្រើនដែលបានធ្វើការទៅលើសិទ្ធិមនុស្ស ក៏ដូចជាសិទ្ធិស្ត្រី និងកុមារ ក៏ប៉ុន្តែករណីបទល្មើសរំលោភសេពសន្ថវៈនៅតែបន្តកើតឡើង។ ទោះបីជាច្បាប់ ក៏ដូចជាមានវិធានការក្នុងការដាក់ទណ្ឌកម្មដដែលប្រព្រឹត្តផ្ទុយទៅនឹងច្បាប់ក៏ដោយ សំណួរចោទឡើងថា ចុះហេតុអ្វីបានជាបទល្មើសរំលោភសេពសន្ថវៈនៅតែបន្តកើតឡើងជាហូរហែរ? តើត្រូវមានយន្តការអ្វីបន្តទៀតដើម្បីធ្វើការទប់ស្កាត់បទល្មើសកុំឲ្យកើតឡើងបន្តទៀត? តើព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរត្រូវចាត់ការទៅលើរឿងក្តីនេះយ៉ាងដូចម្តេច? ហើយក្នុងពេលអនុវត្តតួនាទី និងអំណាចអ្នកទាំងពីរអាចមានបញ្ហាដែរឬទេ? បញ្ហាអ្វីខ្លះដែលកើតមានឡើងរវាងអ្នកទាំងពីរ?

**គោលបំណង:** គោលបំណងដែលយើងខ្ញុំជ្រើសរើសយកប្រធានបទស្តីពី "បទល្មើសរំលោភសេពសន្ថវៈក្នុងទំនាក់ទំនងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរគឺដោយសារយើងខ្ញុំយល់ឃើញថានាពេលបច្ចុប្បន្ននេះបទល្មើសរំលោភសេពសន្ថវៈបានកើតឡើងជាហូហែរដោយពេលខ្លះជនល្មើសពុំត្រូវបានដាក់ទណ្ឌកម្មទេ ដោយសារតែនិទណ្ឌភាព នោះវាហាក់បីដូចជាមានភាពអយុត្តិធម៌យ៉ាងខ្លាំងចំពោះជនរងគ្រោះ។ អ្វីដែលសំខាន់ជាងនេះទៅទៀត យើងឃើញថាច្បាប់បានកំណត់យ៉ាងច្បាស់អំពីនីតិវិធីនៃការអនុវត្តក៏ដូចជាសិទ្ធិ និងអំណាចរបស់ព្រះរាជអាជ្ញា ក៏ដូចជាចៅក្រមស៊ើបសួរក្នុងការដំណើរការដោះស្រាយរឿងក្តីយ៉ាងល្អប្រសើរ។ ប៉ុន្តែបទល្មើសនេះនៅតែបន្តកើតឡើងជារៀងរាល់ថ្ងៃ ដូច្នេះយើងខ្ញុំចង់ដឹងថាតើការអនុវត្តតួនាទី និងអំណាចរបស់អ្នកទាំងពីរនៅមានភាពខ្វះចន្លោះដែរឬយ៉ាងណា តើភាពខ្វះចន្លោះនោះអាចជះឥទ្ធិពលអ្វីខ្លះដល់ជនរងគ្រោះ។ ម្យ៉ាងទៀតអ្វីទៅជាផលវិបាករបស់អ្នកទាំងពីរក្នុងការអនុត្តកាតព្វកិច្ចទាំងនេះ។

**ផលលំបាកនៃការស្រាវជ្រាវ:** ដូចដែលយើងខ្ញុំបានលើកឡើងពីផលលំបាក ប្រធានបទនៃសារណារួចមកហើយ។ ប៉ុន្តែចំពោះការលំបាកដែលយើងខ្ញុំតែងតែជួបប្រទះវិញនោះមានដូចជាការសុំចុះស្រាវជ្រាវនៅស្ថាប័ន តុលាការ និងនៅបណ្តាអង្គការនានា ជាពិសេសគឺការចំណាយពេលវេលាក្នុងការរង់ចាំនូវការយល់ព្រមឲ្យយើងខ្ញុំចុះស្រាវជ្រាវ ជាពិសេសគឺការប្រមូលឯកសារដែលពាក់ព័ន្ធនឹងប្រធានបទរបស់យើងខ្ញុំតែម្តង។ លើសពីនេះទៅទៀតផលវិបាកខ្លាំងបំផុតនោះគឺការខ្វះខាតឯកសារដើម្បីយកមកធ្វើជាគោលគំនិត ព្រោះប្រធានបទនេះគឺថ្មីស្រឡាងខុសប្លែកពីប្រធាន

បទដែលធ្លាប់មានកន្លងមក ហើយខណៈពេលដែលកំពុងសរសេរសារណា វាក៏បានលេចចេញនូវចំណុចថ្មីៗគឺសុទ្ធសឹងតែប្រើនូវគំនិតផ្ទាល់ខ្លួនទាំងស្រុងតែម្តង ឯចំណុចខ្លះទៀតត្រូវធ្វើការកែប្រែមួយចំនួនទៅលើខ្លឹមសារ និងមាតិកាដែលធ្វើឲ្យយើងខ្ញុំមានការលំបាកក្នុងការផ្លាស់ប្តូរក៏ដូចជាការបំពេញបន្ថែមផងដែរ។

**ដែនកំណត់:** ដូចដែរយើងបានដឹងរួចហើយថាពីមួយថ្ងៃទៅមួយថ្ងៃបទល្មើសកើតឡើងសឹងតែគ្រប់ករណីទាំងអស់ទោះបីជាមានស្ថាប័នមានសមត្ថកិច្ចដូចជា នគរបាលយុត្តិធម៌ និងតុលាការបានធ្វើចំណាត់ការដោយដាក់ទណ្ឌកម្មតឹងរឹងយ៉ាងណាក៏ដោយ។ ប៉ុន្តែនៅក្នុងប្រធានយើងខ្ញុំសូមធ្វើការបកស្រាយដែលទាក់ទងនិងអាជ្ញាធរដែលពាក់ព័ន្ធ ជាពិសេសត្រឹមតែនៅក្នុងរង្វង់ដែនសមត្ថកិច្ច របស់ព្រះរាជាអាជ្ញា និងចៅក្រមស៊ើបសួរក្នុងការអនុវត្តនីតិវិធីនៅក្នុងករណីបទល្មើសរំលោភសេពសន្ថវៈនេះតែប៉ុណ្ណោះ។ ហើយយើងខ្ញុំនឹងលើកពីផលប៉ះពាល់ដែលកើតចេញពីខ្វែងគំនិត ឬទំនាស់ទៅលើនីតិវិធី និងពីបទញ្ញត្តិ និងសៀវភៅសំខាន់ៗដែលមានទាក់ទងទៅនឹងប្រធានបទយើងខ្ញុំដើម្បីធ្វើការបកស្រាយ។

**រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**: ដើម្បីបកស្រាយនូវប្រធានបទនេះឲ្យកាន់តែមានន័យ និងងាយស្រួលក្នុងការស្វែងយល់ នោះយើងខ្ញុំនឹងធ្វើការបកស្រាយអត្ថន័យទាំងស្រុងដោយមានការបែងចែកជាបីជំពូក ដោយពីជំពូកមួយទៅជំពូកមួយគឺរៀបតាមលំដាប់លំដោយឲ្យទាក់ទងគ្នាតាំងពីបទល្មើសរំលោភសេពសន្ថវៈ រហូតដល់ទំនាក់ទំនងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ ដែលមានដូចជា៖

១. ជំពូក១ ស្តីអំពីបទល្មើសរំលោភសេពសន្ថវៈ
២. ជំពូកទី២ សិក្សាអំពី ព្រះរាជាអាជ្ញា និងចៅក្រមស៊ើបសួរ
៣. ជំពូកទី៣ សិក្សាអំពីបទល្មើសរំលោភសេពសន្ថវៈក្នុងទំនាក់ទំនងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ

# ជំពូក១ បទល្មើសរំលោភសេពសន្ថវៈ

គ្រប់អំពើបញ្ចូលអង្គជាតតាមបែបណាក៏ដោយឬ អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះមានភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយ ដោយប្រើហិង្សា ការបង្ខិតបង្ខំ កាគំរាមកំហែង ដោយការឆ្មក់ឱកាស ជាបទល្មើសរំលោភសេពសន្ថវៈ [១]។

## កថាខណ្ឌទី ១ ធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ

ចំពោះបទល្មើសរំលោភសេពសន្ថវៈក៏ដូចជាបទល្មើសផ្សេងទៀតដែរ មុននឹងធ្វើការចោទប្រកាន់បុគ្គលណាមួយ គឺត្រូវតែកំណត់ពីធាតុផ្សំនៃបទល្មើសឲ្យបានច្បាស់លាស់។

នៅក្នុងច្បាប់ព្រហ្មទណ្ឌគេបានបែងចែកធាតុផ្សំនៃបទល្មើសជាបីធំៗ ដើម្បីកំណត់ថាអំពើមួយជាបទល្មើសត្រូវតែបំពេញគ្រប់ល័ក្ខខ័ណ្ឌនៃធាតុផ្សំទាំងបីគឺ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។

### ១. ធាតុនីត្យានុកូល

ធាតុនីត្យានុកូលគឺជាធាតុច្បាប់សម្រាប់កំណត់អំពើណាមួយជាបទល្មើស។

មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តបទល្មើសប៉ុណ្ណោះ ទើបអាចប្រកាសបាន[២]។

គ្មានបុគ្គលណាត្រូវបានគេកំណត់ថាមានទោសឡើយប្រសិនបើគ្មានច្បាប់ចែងថាអំពើនេះជាបទល្មើស ។ គោលការណ៍នេះ ការពារសន្តិភាពបុគ្គលឯកជនតាមរយៈការធានានូវសេរីភាពជាមូលដ្ឋានរបស់បុគ្គល ប្រឆាំងនឹងការរំលោភបំពានតាមតែអំពើចិត្ត និងគ្មានហេតុផលសមរម្យពីសំណាក់រដ្ឋ។ ចំពោះបទល្មើសរំលោភសេពសន្ថវៈ បានចែងក្នុងក្រមព្រហ្មទណ្ឌនៅមាត្រា ២៣៩ ដែលបានកំណត់ទោសដូចតទៅ:

[១] មាត្រា ២៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[២] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០១០

គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះមានភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយ ដោយប្រើហិង្សា ការបង្ខិតបង្ខំ កាគំម្រាមកំហែង ដោយការឆ្មក់ឱកាស ជាបទល្មើសសេពសន្ថវៈ។

បទរំលោភសេពសន្ថវៈ ត្រូវដាក់ពន្ធនាគារពី ៥ ទៅ ១០ ឆ្នាំ ។ ចំពោះការពិន័យជាទឹកប្រាក់ត្រូវបានគេផ្តល់ឆន្ទានុសិទ្ធិឲ្យចៅក្រមជាអ្នកសម្រេចទៅតាមទំហំនៃបទល្មើស និងជីវភាពរបស់ជនល្មើស។

## ២.ធាតុសត្យានុម័ត

ធាតុនេះសំដៅទៅលើអំពើ និងព្យសនកម្មដែលប្រព្រឹត្តឡើងដោយជនល្មើស ធាតុនេះស្តែងចេញឲ្យគេឃើញជាសម្ភារៈខាងក្រៅ។ ធាតុសត្យានុម័តនៃបទល្មើស គឺស្តែងចេញឲ្យឃើញ:

- អំពើគ្រោះថ្នាក់ដល់សង្គម
- បច្ច័យ
- ទំនាក់ទំនងហេតុផល អំពើនិងបច្ច័យ
- ពេលវេលា ទីកន្លែង ឧបាយកល មធ្យោបាយ។

ចំពោះបទល្មើសរំលោភសពសន្ថវៈ ជនល្មើសបានប្រើហឹង្សា ឬការបង្ខិតបង្ខំ ឬ គំរាមកំហែងដើម្បីបញ្ចូលអង្គជាតរបស់ខ្លួនទៅក្នុងអង្គជាតរបស់ជនរងគ្រោះ ឬ ទៅកន្លែងណាមួយរបស់ជនរងគ្រោះ។ ជួនកាលជនល្មើសបានឆ្មក់ឱកាសទៅលើជនរងគ្រោះមិនដឹងខ្លួន ឬ យល់ព្រមដោយការភ័ន្តច្រលំជាដៃគូស្នេហា ឬ សហព័ទ្ធរបស់ខ្លួនដោយបញ្ចូលអង្គជាតរបស់ខ្លួន ទៅក្នុងអង្គជាតរបស់ជនរងគ្រោះ ឬ ទៅកន្លែងណាមួយរបស់ជនរងគ្រោះ។ ក្នុងល័ក្ខខ័ណ្ឌផ្សេងទៀតក៏ជាល័ក្ខខ័ណ្ឌនៃធាតុសម្ភារៈនៃបទល្មើសនេះដែរដូចជា ជនល្មើសបានបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតរបស់ជនរងគ្រោះដោយប្រើហឹង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ការឆ្មក់ឱកាស។ ជនល្មើសអាចប្រើវិធីជាច្រើនដោយការប្រើប្រាស់អាវុធ ឬមិនប្រើប្រាស់អាវុធ ការគំរាមកំហែង ការប្រើប្រាស់គ្រឿងញៀន ឬ មធ្យោបាយផ្សេងទៀតដែលធ្វើឲ្យជនរងគ្រោះមិនអាចទប់ទល់បាន។ បទល្មើសនេះត្រូវចាត់ទុកថាបានកើតឡើងទោះបីជាជនល្មើស និងជនរងគ្រោះមានភេទដូចគ្នា ឬ ផ្ទុយគ្នាក៏ដោយ[៣]។

[៣] សៀវភៅមេរៀននីតិព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចងក្រងដោយលោក សឿន មុន្នីរ័ត្ន ឆ្នាំ ២០១១

## ៣.ធាតុអត្តនោម័ត

ធាតុអត្តនោម័ត គឺចង់សំដៅទៅលើសភាវៈផ្លូវចិត្តរបស់ជនល្មើសក្នុងការប្រព្រឹត្តបទល្មើស។ ការសម្គាល់នូវចរិកគ្រោះថ្នាក់នៅក្នុងផ្លូវចិត្តរបស់បុគ្គលម្នាក់ក្នុងការប្រព្រឹត្តបទល្មើសរួមមានៈ

- កំហុស
- មូលហេតុនៃការប្រព្រឹត្តបទល្មើស
- គោលបំណងនៃការប្រព្រឹត្តបទល្មើស។

ក្នុងបទល្មើសរំលោភសេពសន្ថវៈ ជនល្មើសមានចេតនាប្រព្រឹត្តដើម្បីបំពេញចំណង់ផ្លូវភេទរបស់ខ្លួនដោយគ្មានការព្រមព្រៀងពីជនរងគ្រោះ។ ធាតុផ្សំអត្តនោម័ត គឺជាកាយវិការផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ ប៉ុន្តែធាតុផ្សំអត្តនោម័តនេះ ពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្កើតជាបទល្មើសបានទេ លុះត្រាតែមានបទល្មើសកើតឡើងទើបយើងអាចកំណត់បានពីអំពើនៃការប្រព្រឹត្ត ដូច្នេះធាតុផ្សំមួយនេះមានលក្ខណៈស្មុគស្មាញក្នុងការវិនិច្ឆ័យខាងផ្លូវចិត្តរបស់ជនល្មើស ។ ចំពោះធាតុផ្សំនេះគេបានបែងចែងកំហុសជាពីរប្រភេទគឺ កំហុសចេតនា និងកំហុសអចេតនា។ ប៉ុន្តែនៅក្នុងបទល្មើសរំលោភសេពសន្ថវៈមិនអាចមានកំហុសអចេតនាឡើយ។

❖ ***កំហុសចេតនា:*** ក្នុងករណីនេះជនល្មើសបានដឹងអំពីអំពើរបស់ខ្លួនថាជាបទល្មើសរួចទៅហើយ តែគាត់នៅតែមានចេតនាក្នុងការប្រព្រឹត្តបទល្មើសនោះទៀត។ ឧទាហរណ៍ បុរស "ក" បានលួងលោមនារី "ខ" ដែលជាសង្សាររបស់គាត់រួមភេទជាមួយ ប៉ុន្តែនារី "ខ" មិនយល់ព្រម។ ថ្ងៃមួយបុរស "ក" បានប្រើឧបាយកលដោយប្រើថ្នាំសម្រើបដាក់ចូលទៅក្នុងទឹកឲ្យនារី "ខ" ផឹករួចហើយក៏រំលោភនាងបានសម្រេច។ ក្នុងករណីនេះបុរស "ក" មិនអាចបដិសេធបានឡើយថាការដាក់ថ្នាំ ដើម្បីធ្វើឲ្យជនរងគ្រោះមានចំណង់ខាងផ្លូវភេទហើយរួមភេទជាមួយខ្លួនមិនមែនជាបទល្មើសឡើយ ព្រោះនៅក្នុងគោលការណ៍របស់ច្បាប់បានចែងថាគ្មានជនណាម្នាក់អាចបដិសេធថាខ្លួនមិនដឹង ឬមិនចេះអំពីច្បាប់នោះទេ។ ដូច្នេះគេសន្មត់ថាបុរស "ក" បានយល់ដឹងយ៉ាងច្បាស់លាស់អំពីអំពើដែលខ្លួនបានប្រព្រឹត្តគឺជាបទល្មើសរំលោភសេពសន្ថវៈ។

## កថាខណ្ឌទី២ មូលហេតុដែលនាំឲ្យមានបទល្មើសរំលោភសេពសន្ថវៈ

បច្ចុប្បន្នបញ្ហាជាច្រើនបានកើតឡើង មិនថានៅទីណាក៏ដូចទីណាដែរ។ គ្រប់បញ្ហាមិនមែននៅសុខៗកើតមាននោះទេ វាសុទ្ធតែមានចំណងហេតុ និងផល។ បទល្មើសរំលោភសេពសន្ថវៈ ក៏ដូចគ្នាដែរ គឺសុទ្ធតែមានមូលហេតុរបស់វា។ មូលហេតុដែលធ្វើឲ្យជនល្មើសប្រព្រឹត្តនូវអំពើទាំងនោះ គឺអាចបណ្ដាលមកពីអត្តចរិតរបស់ជនល្មើសដោយផ្ទាល់ ឬ មកពីជនរងគ្រោះខ្លួនឯងដែលគេហៅថាកត្តាមនុស្ស ហើយក្រៅពីនេះគឺអាចមកពីជីវភាពប្រចាំថ្ងៃ និងមជ្ឈដ្ឋាននៅជុំវិញដែលគេហៅថាកត្តាសង្គម។

### ១. កត្តាមនុស្ស

មនុស្សម្នាក់ៗកើតមកតែងតែមានអត្តចរិតខុសៗគ្នា អ្នកខ្លះល្អ អ្នកខ្លះអាក្រក់ ដូច្នេះទើបមានការប្រព្រឹត្តបទល្មើសកើតឡើង។ រាល់ការប្រព្រឹត្តបទល្មើសអាចទាក់ទងនឹងអត្តចរិតរបស់ជនល្មើសពីកំណើត បុគ្គលមួយចំនួនមានអត្តចរិតប្រព្រឹត្តបទល្មើសលួច ឯបុគ្គលខ្លះទៀតមានអត្តចរិតប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសផ្សេងៗទៀតជាដើម។ ប៉ុន្តែរាល់ការប្រព្រឹត្តបទល្មើសមិនមែនសុទ្ធតែមកពីជនល្មើសទាំងអស់ទេពេលខ្លះក៏អាចមកពីជនរងគ្រោះផងដែរ។

### ១.១ ជនល្មើស

មានមូលហេតុជាច្រើនដែលធ្វើឲ្យជនល្មើសប្រព្រឹត្តបទល្មើស ប៉ុន្តែចំពោះបទល្មើសរំលោភសេពសន្ថវៈមូលហេតុចំបងដែលធ្វើឲ្យមានបទល្មើសកើតឡើងគឺ:

- *គ្រឿងញៀន*

គ្រឿងញៀន គឺជាសារធាតុម្យ៉ាងដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព។ វាអាចផ្តល់ផលអាក្រក់យ៉ាងធ្ងន់ធ្ងរ ទៅដល់ខួរក្បាល បេះដូង ដំណើរការលូតលាស់ធំធាត់ របស់កុមារ យុវជន និងសរីរាង្គ ដ៏ទៃទៀតនៃសារពាង្គកាយ។ វាធ្វើឲ្យយើងក្លាយជាមនុស្សមិនឯករាជ្យ ដែលមិនអាចរស់នៅដោយអត់ថ្នាំបាន ហើយរវើរវាយនៅមិនសុខ។ ហើយពេលខ្លះពួកគេត្រូវតម្លើងកម្រិតថ្នាំទើបអាចទទួលបានប្រសិទ្ធភាពថ្នាំ។ នៅពេលអ្នកប្រើប្រាស់បានប្រើវាហើយ វាធ្វើឲ្យអ្នកប្រើបាត់បង់នូវសតិសម្បជញ្ញៈ មិនអាចគ្រប់គ្រងអារម្មណ៍ខ្លួនឯងបាន ជួនកាលអាចឈានទៅដល់ការប្រព្រឹត្តបទល្មើសទៀតផង។ ដូច្នេះហើយទើបមានការកើតឡើងនូវបទល្មើសរំលោភសេពសន្ថវៈជាដើម។

❖ *គ្រឿងស្រវឹង*

ការប្រើប្រាស់គ្រឿងស្រវឹង អាចមានទាំងផលប្រយោជន៍ និងផលប៉ះពាល់កាលណាការសេពគ្រឿងស្រវឹងមិនលើសកម្រិតដែលគេបានកំណត់វាអាចជួយឲ្យមនុស្សមានអារម្មណ៍ល្អ បំបាត់ភាពតានតឹងជាដើម។ តែបើប្រើប្រាស់លើសកម្រិត នោះវាអាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទាំងសុខភាព។ នៅពេលបច្ចុប្បន្ននេះ ការប្រើប្រាស់គ្រឿងស្រវឹងមានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃដោយសារមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ជាពិសេសមានការផ្សព្វផ្សាយពាណិជ្ជកម្ម ក៏ដូចជាការចាប់រង្វាន់ដែលធ្វើឲ្យមានការទាក់ទាញយ៉ាងខ្លាំងពីអ្នកប្រើប្រាស់ដូចជា យុវវ័យ ក៏ដូចជាមនុស្សចាស់។ គួរកត់សំគាល់ឃើញថា ការប្រើប្រាស់គ្រឿងស្រវឹងច្រើនហួសកម្រិតពេកអាចធ្វើឲ្យមនុស្សបាត់បង់ស្មារតី វង្វេងវង្វាន់ ភ្លេចភ្លាំងដែលធ្វើឲ្យពេលខ្លះអាចជ្រុលខ្លួនឈានដល់ការប្រព្រឹត្តបទល្មើស ជាពិសេសបទល្មើសដែលកើតឡើងដោយសារការសេពគ្រឿងស្រវឹង គឺជាបទល្មើសរំលោភសេពសន្ថវៈនេះតែម្តង។ កម្រិតនៃការប្រព្រឹត្តបទល្មើសរំលោភដោយសារការសេពគ្រឿងស្រវឹងបានកើតឡើងគួរឲ្យកត់សំគាល់ ដែលជាហេតុធ្វើឲ្យស្ថាប័នមានសមត្ថកិច្ចមានការលំបាកក្នុងការបង្ក្រាប ព្រោះវាជាសារធាតុមួយដែលមានការទទួលស្គាល់ដោយស្របច្បាប់ និងមានការពេញនិយមនៃអ្នកប្រើប្រាស់។

**១.២ ជនរងគ្រោះ**

មិនត្រឹមតែជនល្មើសទេដែលធ្វើឲ្យមានបទល្មើសកើតឡើង ជនរងគ្រោះក៏ដូចគ្នាដែរ។ មានកត្តាជាច្រើនដែលជនរងគ្រោះបានចូលរួមបទល្មើសដោយមិនដឹងខ្លួន។

❖ *ការស្លៀកពាក់*

ដោយមានការវិវត្តន៍ពីសម័យកាលមួយទៅសម័យកាលមួយមនុស្សតែងតែមានការផ្លាស់ប្តូរនូវទម្លាប់របស់ខ្លួនបន្តិចម្តងៗ។ ជាពិសេសមនុស្សយើងចូលចិត្តភាពឆ្នៃប្រឌិត និងធ្វើអ្វីដែលថ្មីៗ និងប្លែកសម្រាប់ពួកគេ មិនថាទាំងអាកប្បកិរិយា ឧបករណ៍ប្រើប្រាស់ ឬ សំលៀកបំពាក់ឡើយ។ យ៉ាងណាមិញ ចំពោះនារីមួយចំនួនបានផ្លាស់ប្តូរការស្លៀកពាក់តាមសម័យកាល ដូចជាកាលសម័យសង្គមរាស្ត្រនិយមនារីខ្មែរចូលចិត្តស្លៀកពាក់ហូលផាមួង ប៉ុន្តែនាសម័យបច្ចុប្បន្នស ពួកគេចូលចិត្តស្លៀកពាក់រឹបបញ្ចេញរាង ឯអ្នកខ្លះទៀតស្លៀកខើចលើខើចក្រោមជ្រុលហួសហេតុ ដែលធ្វើឲ្យជនល្មើសមិនអាចទ្រាំនឹងចំណង់តណ្ហារបស់ខ្លួនដែលបណ្តាលឲ្យមានការប្រព្រឹត្តបទល្មើស។

❖ *ខ្វះការប្រុងប្រយ័ត្ន*

ដោយសារបច្ចុប្បន្នមានការរីកចម្រើននៃសេដ្ឋកិច្ច និងបច្ចេកវិទ្យាទាន់សម័យ ដោយមានការបង្កើតនូវល្បែងកំសាន្ត និងក្លឹបកំសាន្តជាច្រើនដែលជាចំណាប់អារម្មណ៍របស់យុវវ័យក្នុងការលំហែរកាយបន្ទាប់ពីការតានតឹងដោយសារការងារ និងការសិក្សាជាដើម។ ម្យ៉ាងទៀតយុវជនសម័យនេះចូលចិត្តដើរកំសាន្តនាពេលរាត្រី ព្រោះជាពេលវេលាក្រៅម៉ោងធ្វើការ និងការសិក្សា។ មនុស្សមួយចំនួនចូលចិត្តដើរលក្ខណៈជាក្រុម ឯខ្លះទៀតចូលចិត្តដើរម្នាក់ឯង។ ចំពោះបញ្ហាកើតឡើងជាញឹកញាប់ ក៏ដូចជាបទល្មើសរំលោភ គឺតែងតែកើតឡើងចំពោះបុគ្គលដែលដើរម្នាក់ឯង ព្រោះជាឱកាសល្អសម្រាប់ជនល្មើសក្នុងការប្រព្រឹត្តបទល្មើស។ ក្រៅពីនេះដោយនារីមួយចំនួនមិនបានគិតល្អិតល្អន់ដោយហ៊ានដើរលេងជាមួយជនមិនស្គាល់មុខតែពីរនាក់ ឬ ទៅទីកន្លែងដែលគ្មានមនុស្សអ៊ូអរ ឬកន្លែងដែលមិនស្គាល់ជាដើម ដូនេះការខ្វះការប្រុងប្រយ័ត្នក៏ជាបញ្ហាមួយដែលអាចបណ្តាលឲ្យមានបទល្មើសកើតឡើងបានដែរ។

## ២. កត្តាសង្គម

មិនត្រឹមតែកត្តាមនុស្សទេដែលនាំឲ្យមានបទល្មើសរំលោភសេពសន្ថវៈកើតឡើង សូម្បីតែកត្តាសង្គមក៏ដូចគ្នាដែរ។ ជាក់ស្តែងនៅក្នុងសង្គមបច្ចុប្បន្ន បទល្មើសនេះបានកើតឡើងជាញឹកញាប់ដោយសារតែ សង្គមមិនទាន់មានសន្តិសុខ លំហូរចូលនូវវប្បធម៌បរទេស ការផ្សព្វផ្សាយច្បាប់មិនទាន់បានទូលំទូលាយទេ ដែលជាហេតុធ្វើឲ្យស្ត្រីភាគច្រើនរងនូវការបំពារបំពានលើរាង្គកាយដោយអយុត្តិធម៌។ ជាពិសេសការអប់រំនៅមានកម្រិត ដែលធ្វើឲ្យបទល្មើសកើតឡើងជាបន្តបន្ទាប់គួរឲ្យគត់សម្គាល់។

### ២.១ ការហូរចូលនូវវប្បធម៌បរទេស

ប្រទេសកម្ពុជាជាប្រទេសសេរី គឺផ្តល់សិទ្ធិឲ្យប្រជាពលរដ្ឋពេញលេញក្នុងការធ្វើអ្វីៗដោយខ្លួនឯងដោយគ្មានការបង្ខិតបង្ខំពីសំណាក់តតីយជន ឬ រដ្ឋឡើយ។ ដូច្នេះប្រជាជនកម្ពុជាបានទទួលយកនូវវប្បធម៌បរទេសជាច្រើនក្នុងការអភិវឌ្ឍន៍ខ្លួនឯង និងប្រទេសឲ្យកាន់តែរីកចម្រើន។ ទោះបីជាយ៉ាងណាក៏ដោយការហូរចូលនូវវប្បធម៌នេះក៏អាចមានផលប៉ះពាល់ផងដែរ។ ដូចជាការនាំចូលមកនូវវីដេអូអាសអាភាស ឬ អាកប្បកិរិយាដែលមិនមែនជាវប្បធម៌ល្អរបស់ខ្មែរ (ការបឺតមាត់ ឱបរឹតក្នុងទីធ្លាសាធារណៈ) ។ ចំពោះវីដេអូអាសអាភាសរបស់បរទេសភាគច្រើនគឺការរួមភេទដោយប្រើហិង្សា ឬ ការរួមភេទដែលមានគ្នាច្រើន។ ទាំងនេះជាហេតុនាំឲ្យអ្នកមើលហើយមានគំនិតវើរវាយមិនអាច

ទប់នូវតណ្ហារបស់ខ្លួនបានហើយអាចឈានទៅប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ដោយការប្រើហិង្សា ឬការរំលោភដោយមានសហចារីជាដើម។ ម្យ៉ាងវិញទៀត វិស័យអប់រំនៅតែមិនទាន់មានភាពគ្រប់គ្រាន់នៅឡើយ ដូចជានៅតាមតំបន់ដាច់ស្រាលនៅតែមានការខ្វះខាតយ៉ាងខ្លាំងនូវសាលារៀនគ្រូបង្រៀន សម្ភារៈសិក្សា ជាពិសេសទាក់ទងនឹងជីវភាពខ្វះខាតរបស់ប្រជាពលរដ្ឋដែលមិនអាចផ្គត់ផ្គង់ជីវភាពសម្រាប់ឲ្យកូនទៅរៀនបាន ដែលជាហេតុនាំឲ្យប្រជាជននៅទីនោះគ្មានចំណេះដឹងគ្រប់គ្រាន់ទាក់ទងទៅនឹងសីលធម៌ និងច្បាប់ជាដើម។ កត្តាទាំងអស់នេះហើយដែលធ្វើឲ្យយើងឆាប់ទទួលយកវប្បធម៌ពីគេដោយពុំបានធ្វើការត្រិះរិះពិចារណាច្រើនឡើយ។

## ២.២ និទណ្ឌភាព

និទណ្ឌភាពជាមូលហេតុចំបងមួយក្នុងការធ្វើឲ្យមានអំពើរំលោភសេពសន្ថវៈបានកើតម្តងហើយម្តងទៀត។ ហើយបញ្ហានិទណ្ឌភាពនេះហើយដែលវាអាចកើតចេញពីការចរចារ និងការបង់ប្រាក់ដែលធ្វើឡើងជាលក្ខណៈឯកជនរវាងជនសង្ស័យនិងមន្ត្រីសារធារណៈ នោះវាអាចធ្វើឲ្យមានការបញ្ចប់រឿងដោយសំណង ដោយសារមានការធ្វើការផ្តួចផ្តើមដោយនគរបាលក្នុងការធ្វើការចរចារកដំណោះស្រាយរវាងជនរងគ្រោះ និងជនល្មើស។ ហើយជាពិសេសប្រសិនបើមានករណីនេះកើតឡើងមែនពិត វាពិតជាមានភាពលំបាកណាស់ក្នុងការធ្វើការដោះស្រាយពីព្រោះនគរបាល និងមន្ត្រីតុលាការគឺមានភាពប៉ិនប្រសព្វយ៉ាងខ្លាំងក្នុងការលុបបំបាត់នូវភស្តុតាង។ ទន្ទឹមនិងនេះ បញ្ហានិទណ្ឌភាពបណ្តាលមកពីសង្គមកម្ពុជាបានឲ្យតម្លៃខ្ពស់ទៅលើសីលធម៌ផ្លូវភេទ និងព្រហ្មចារីរបស់ស្ត្រីការរក្សាគុណតម្លៃរបស់ខ្លួនទាំងនេះគឺមានទម្ងន់យ៉ាងធ្ងន់ធ្ងរ។ ដូច្នេះហើយបានជាយើងឃើញមានការរៀបអាពាហ៍ពិពាហ៍រវាងជនរងគ្រោះជាមួយជនសង្ស័យ ព្រោះក្រោយពីត្រូវបានគេរំលោភសេពសន្ថវៈស្ត្រីគិតថាខ្លួនហាក់បីដូចជាអស់តម្លៃ ព្រោះពួកគេឲ្យតម្លៃទៅលើភាពបរិសុទ្ធរបស់ពួកគេ។ ផលវិបាកមួយទៀតនោះគឺទាក់ទងទៅនិងការចំណាយ និងផលវិបាកជាក់ស្តែងក្នុងការបន្តរឿងក្តីតាមរយៈតុលាការ សម្រាប់កូនក្តីដែលក្រីក្រខ្លាំងមិនអាចមានប្រាក់គ្រប់គ្រាន់ក្នុងការចំណាយសម្រាប់ការធ្វើដំណើរទៅតុលាការទៅវិញទៅមកបានទេ គឺអាចធ្វើឲ្យមានការបន្តរឿងក្តីមានភាពលំបាក។ លើសពីនេះទៅទៀត ប្រជាជនកម្ពុជាភាគច្រើនបានដឹងអំពីអំពើពុករលួយក្នុងផ្លូវតុលាការ និងបានដឹងថាទោះបីជាការពិត មិនមានការបង់ប្រាក់ណាមួយត្រូវបានទាមទារ នៅក្នុងច្បាប់ក៏ដោយ ក៏ជនរងគ្រោះទំនងជាត្រូវបង់ប្រាក់ក្រៅផ្លូវនៅគ្រប់ដំណាក់កាលនៃរឿងក្តី។ មូលហេតុទាំងអស់នេះហើយដែលធ្វើឲ្យជនល្មើសមិនមានភាពខ្លាចរអាក្នុងការប្រព្រឹត្តបទល្មើសឡើយ ព្រោះភាគ

ច្រើននៃពួកគេមិនត្រូវបានទទួលទោសទណ្ឌអ្វីទាំងអស់។ ជាងនេះទៅទៀតប្រសិនបើអំពើរំលោភសេពសន្ថវៈនេះបង្កឡើយដោយស្វាមី នោះវាជាផ្នែកមួយនៃអំពើហិង្សារយៈពេលវែង។ ក្នុងរណីនេះមានតែចំនួន ១ ភាគ ១០ នៃជនរងគ្រោះប៉ុណ្ណោះដែលបានដាក់ពាក្យបណ្តឹងទៅតុលាការ ក្រៅពីនេះត្រូវបានបញ្ចប់ដោយការលែងលះ។ ករណីមួយចំនួនជនរងគ្រោះមិនហ៊ានធ្វើការប្តឹងដោយមូលហេតុជនសង្ស័យជាសមាជិកគ្រួសារ[៤]។

## កថាខណ្ឌទី៣ ដំណោះស្រាយគតិយុត្ត

ដោយសារការអនុវត្តច្បាប់នូវប្រទេសកម្ពុជាមិនទាន់មានភាពល្អប្រសើរ ព្រោះមន្ត្រីតុលាការ និងមន្ត្រីនគរបាលយុត្តិធម៌មិនទាន់មានការឯកភាពគ្នានៅឡើយទេ។

ការផ្តល់ភាពយុត្តិធម៌ដល់ប្រជាពលរដ្ឋនៅតែមានការតិះទៀន ដូច្នេះមន្ត្រីអនុវត្តច្បាប់ទាំងអស់ត្រូវតែជជែកពិភាក្សារគ្នារកភាពអសកម្មនានាទាំងនោះ និងដោះស្រាយឲ្យសង្គមជាតិមាននូវសន្តិសុខ សណ្តាប់ធ្នាប់ល្អ និងងាកមករកការខិតខំផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឲ្យមានភាពប្រសើរឡើងវិញ[៥]។

### ១. អនុវត្តបទដ្ឋានគតិយុត្តឲ្យបានតឹងរឹង

ដើម្បីធ្វើឲ្យមានការអនុវត្តច្បាប់ឲ្យបានតឹងរឹង គឺលុះត្រាមានការផ្សព្វផ្សាយច្បាប់ឲ្យបានទូលំទូលាយមិនថានៅទីក្រុងភ្នំពេញ ឬ នៅតាមបណ្តាលខេត្តនានា និងមានការចូលរួមពីស្ថាប័នអនុវត្តច្បាប់ខ្លួនឯង និងឲ្យប្រជាពលរដ្ឋបានដឹង ហើយជាពិសេសត្រូវមានការដាក់ទណ្ឌកម្មចំពោះជនណាដែលបានប្រព្រឹត្តផ្ទុយនឹងបទបញ្ញត្តិដែលបានចែងឲ្យបានតឹងរឹង។ ទន្ទឹមនឹងនេះ ច្បាប់ដែលបានដាក់ចេញឲ្យប្រើនោះ ត្រូវតែជាច្បាប់ដែលអាចអនុវត្តបាននៅពេលបច្ចុប្បន្ន និងពេលអនាគត់ ហើយមានការយល់ព្រមពីប្រជាពលរដ្ឋ លើសពីនេះទៅទៀតត្រូវមានការលើកទឹកចិត្ត និងមានការជម្រុញឲ្យមានការអនុវត្តច្បាប់មួយប្រកបដោយប្រសិទ្ធិភាព។

---

[៤] ការរួចខ្លួនពីបទល្មើស៖ ការនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈក្នុងប្រព័ន្ធតុលាការកម្ពុជា របាយការណ៍ចេញផ្សាយ ខែវិច្ឆិកា ឆ្នាំ ២០១៥ សម្ព័ន្ធរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

[៥] ប្រសាសន៍របស់លោកអង្គវង្ស វឌ្ឍនា នៅក្នុងទស្សសនាវតីCEN ថ្ងៃទី ៥ ឧសភា ២០១៥

នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក៏បានកំណត់អំពីការកំណែទម្រង់ច្បាប់នេះផងដែរ ដោយកំណត់យុទ្ធសាស្ត្រជាសារវ័ន្តដូចជា:

- លើកកំពស់ការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋាន។
- ទំនើបកម្មក្របខ័ណ្ឌច្បាប់។
- កែលំអរការផ្តល់ពិតមានលើបញ្ហានានាដែលពាក់ព័ន្ធ និងច្បាប់[៦]។

**១.១ ច្បាប់**

ច្បាប់ គឺជាបទដ្ឋានគតិយុត្តិដែលបានបញ្ញត្តិអំពីគោលការណ៍សំខាន់ៗ សម្រាប់យកមកអនុវត្តនិងធ្វើការដាក់ទណ្ឌកម្ម។ ការពង្រឹងផ្នែកច្បាប់ គឺជាវិធានការមួយដ៏សំខាន់បំផុត ព្រោះវាជាឧបករណ៍ការពារសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋ។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា មិនទាន់មានច្បាប់គ្រប់គ្រាន់ដូចនៅប្រទេសអភិវឌ្ឍនានាឡើយទេ គឺដោយនៅមានចំនុចខ្វះខាតជាច្រើនទាំងការកំណត់អំពីបទល្មើស និងទោសដែលជាហេតុនាំឲ្យជនល្មើសអាចរកចន្លោះនៃច្បាប់ដើម្បីប្រព្រឹត្តបទល្មើស។

**១.១.១ ក្រមព្រហ្មទណ្ឌ**

បើយោងតាមសៀវភៅ របស់សាស្ត្រាចារ្យ កៅ សីហា ដោយបង្ហាញពីនិយមន័យរបស់ច្បាប់ព្រហ្មទណ្ឌនេះ ដោយមានអត្ថន័យដូចតទៅ:

ច្បាប់ព្រហ្មទណ្ឌ គឺជាសាខាមួយនៃនីតិដែលសិក្សាពីការកំណត់បទល្មើស ការស្វែងរកជនល្មើស ការស្វែងរកអំពីពិរុទ្ធភាព ឬមួយក៏ភាពស្មោះត្រង់របស់ជនល្មើស ការចោទប្រកាន់ ការស៊ើបសួរ ការជំនុំជម្រះ ការប្រកាសទោស ឬ ការអនុវត្តទោសជាដើម។ ឯន័យចង្អៀតនីតិព្រហ្មទណ្ឌ គឺជាសារវន្តនៃវិធានគតិយុត្ត ដែលកំណត់ពីទណ្ឌកម្ម។ តែបើនិយាយពីន័យទូលាយវិញនីតិព្រហ្មទណ្ឌ គឺជាសំណុំនៃបទដ្ឋានគតិយុត្ត ដែលចែងពីការបង្ក្រាបបទល្មើសដោយរដ្ឋអំណាច។

បើនិយាយឲ្យចំច្បាប់ព្រហ្មទណ្ឌជាសាខានៃនីតិដែលរឹតបន្តឹងសិទ្ធិសេរីភាពពលរដ្ឋ ឬ ក៏សេរីភាពបុគ្គលរហូតដល់ពេលខ្លះគឺឈានដល់ការដកហូតសិទ្ធិសេរីភាពមួយចំនួន (ទោសពន្ធនាគារ)

[៦] ការនុវត្តន៍យុទ្ធសាស្ត្រចតុកោណ និង តំរូវការជំនួយអភិវឌ្ឍន៍

ទៀតផង។ ម្យ៉ាងទៀតនីតិព្រហ្មទណ្ឌមានចរិតបង្ក្រាបបទល្មើសហើយការដាក់ទោសនេះបង្ហាញពីប្រតិកម្មរបស់សង្គមចំពោះអំពើឈ្លានពានមិនសមហេតុផល និងគ្មានវិចារណញ្ញាណ។

តាមគោលការណ៍នៃក្រមព្រហ្មទណ្ឌការអនុវត្តច្បាប់ព្រហ្មទណ្ឌ គឺត្រូវមានការកំណត់នៅក្នុងដែនរបស់វា។ ពេលវេលានៃប្រព្រឹត្តបទល្មើសក៏ដូចជាទីកន្លែងនៃការប្រព្រឹត្តបទល្មើស។ ច្បាប់ព្រហ្មទណ្ឌមួយមិនអាចយកមកអនុវត្តគ្រប់បទល្មើសបានទេ។ ហេតុនេះយើងអាចថាការសិក្សានូវដែនអនុវត្តច្បាប់ព្រហ្មទណ្ឌ គឺត្រូវយកច្បាប់ព្រហ្មទណ្ឌមួយមកអនុវត្តនៅពេលដែលមានបទល្មើសកើតឡើង គឺត្រូវពិចារណាទៅលើដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងកាល ឬ ក្នុងពេលវេលាដោយប្រៀបធៀបជាមួយពេលវេលានៃការប្រព្រឹត្តបទល្មើស និងដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ ឬ ដែនដី។

### ១.១.២ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

អំពើលក់-ដូរមនុស្សមានន័យថា ប្រគល់ឲ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬ ទទួលយកដោយខុសច្បាប់នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃដោយដោះដូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង។

អំពើធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ដូរមនុស្ស ត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងអំពើលក់ដូរមនុស្សដោយផ្ទាល់[៧]។

ច្បាប់នេះមានគោលបំណងបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងរក្សាការពារលើកកំពស់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិ និងមានគោលបំណងអនុវត្តឲ្យបានសមស្របផងដែរ តាមពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូមនុស្ស ជាពិសេសស្ត្រី និងកុមារ បន្ថែមលើការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ឬ ឧបករណ៍ ឬ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត ទាក់ទងនឹងការជួញដូរមនុស្សដែលព្រះរាជាណាចក្រកម្ពុជាបានឲ្យសច្ចាប័ន ឬ ចុះហត្ថលេខា[៨]។

---

[៧] មាត្រា ១៣ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

[៨] មាត្រា ១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

## ២. ស្ថាប័នអនុវត្តច្បាប់

ស្ថាប័នអនុវត្តច្បាប់ មានន័យថាគឺជាស្ថាប័នដែលមានសមត្ថកិច្ចដែលច្បាប់បានកំណត់។ ក្នុងបទល្មើសព្រហ្មទណ្ឌក៏ដូចជាបទល្មើសរំលោភសេពសន្ថវៈ ស្ថាប័នដែលមានសមត្ថកិច្ចគឺមាន នគរបាលយុត្តិធម៌ និងស្ថាប័នតុលាការ។

### ២.១ នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយរបស់អំណាចតុលាការមានន័យថា នគរបាលយុត្តិធម៌ជាជំនួយអំណាចព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរក្នុងការត្រួតពិនិត្យបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិម និងបទល្មើសលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។

បេសកកម្មសំខានៗរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងរឿងក្តីរំលោភសេពសន្ថវៈមាន ៣ ចំណុច:

- ការត្រួតពិនិត្យបទល្មើស
- ការទទួលពាក្យបណ្តឹង
- ការស៊ើបអង្កេត

❖ **ការត្រួតពិនិត្យបទល្មើស**

ការពិនិត្យបទល្មើស មានន័យថានៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ឃើញមានបទល្មើសកើតឡើង គាត់មានសិទ្ធិធ្វើកិច្ចការនេះដោយខ្លួនឯង ទោះបីគ្មានអ្នកប្តឹងក៏ដោយ។

❖ **ការទទួលពាក្យបណ្តឹង**

នៅពេលទទួលពាក្យបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុទទួលពាក្យបណ្តឹងដែលមានបញ្ជាក់អត្តសញ្ញាណ របស់អ្នកប្តឹង អំពីអំពើល្មើស និងឈ្មោះ ឋានៈ របស់មន្ត្រី នគរបាលយុត្តិធម៌ ព្រមទាំងអង្គភាព ហើយត្រូវស្រង់ឲ្យបានត្រឹមត្រូវអំពីសេចក្តីរាយការណ៍របស់អ្នកប្តឹង។ ម្យ៉ាងទៀត ករណីអ្នកប្តឹងមិនចេះភាសាខ្មែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែ ដោយហាមមិនឲ្យយកគ្នាឯងដែលចេះភាសាមកបកប្រែទេ គឺត្រូវយកអ្នកក្រៅមកស្បថតាមជំនឿ ឬ សាសនាថាខ្លួននិងបកប្រែភាសា ឲ្យបានត្រឹមត្រូវតាមសេចក្តីរាយការណ៍។

មន្ត្រីនគរបាលយុត្តិធម៌ អាចទទួលពាក្យបណ្តឹងរឿងក្តីព្រហ្មទណ្ឌបានចំណែករឿងក្តីរដ្ឋប្បវេណី មិនអាចទទួលបានទេហើយនៅក្នុងរឿងក្តីព្រហ្មទណ្ឌនេះវាមានបណ្តឹងទាមទារ និងបណ្តឹងបរិហារ។

- បណ្តឹងទាមទារ គឺជាបណ្តឹងដែលធ្វើឡើងដោយជនរងគ្រោះប្តឹងទៅសមត្ថកិច្ច (មន្ត្រីនគរបាលយុត្តិធម៌) ឲ្យជួយដោះស្រាយសំណងខូចខាត ជំងឺចិត្ត និងផ្តន្ទាទោសតាមច្បាប់។
- បណ្តឹងបរិហារ គឺជាបណ្តឹងដែលធ្វើឡើងដោយតតិយជន មន្ត្រីសារធារណៈ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ប្តឹងទៅសមត្ថកិច្ចដើម្បីស្វែងរកភស្តុតាង និងឈានទៅដល់ការវែកមុខជនល្មើសមកផ្តន្ទាទោស។

### ❖ ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម គឺជាការស៊ើបទៅលើបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម ឬ លហុទាំងឡាយណាដែលមិនជាក់ស្តែង។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយខ្លួនឯង ឬ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ប៉ុន្តែការបើកការស៊ើបអង្កេតបឋមនេះត្រូវមានការកំណត់ពេលវេលាឲ្យបានច្បាស់លាស់។ ការបើកការស៊ើបអង្កេតបឋមនេះពិតជាមានសារៈសំខាន់ណាស់ចំពោះបទល្មើសរំលោភសេពសន្ថវៈ និងបទឧក្រិដ្ឋផ្សេងទៀតដោយខានមិនបាន ព្រោះបទល្មើសនេះមានលក្ខណៈស្មុគស្មាញខ្លាំង ដែលទាមទារឲ្យមានការស៊ើបអង្កេតឲ្យបានល្អិតល្អន់ ជួនកាលវាអាចជាបទល្មើសផ្សេងមិនមែនជាបទល្មើសរំលោភសេពសន្ថវៈក៏អាចថាបាន ដូចនេះការស្វែងរកភស្តុតាង និងកោសលវិច័យជាចំនុចសំខាន់ដើម្បីសម្រេចនូវរឿងក្តីនេះ។

## ២.២ ស្ថាប័នតុលាការ

ប្រទេសកម្ពុជាបានទទួលយកគោលនយោបាយប្រជាធិបតេយ្យសេរី ពហុបក្ស និងបែងចែកអំណាចជាបីធំៗ គឺ អំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការ[៩]។ ដោយឡែកអំណាចតុលាការ គឺអំណាចឯករាជ្យដែលមិនឲ្យមានអំណាចណាអាចរំលោភបំពាន ឬ ធ្វើអធិបញ្ញាបានឡើយ ព្រោះឯករាជ្យភាពរបស់តុលាការមានសារៈសំខាន់ណាស់ក្នុងការស្វែងរកយុត្តិធម៌ ជូនប្រជារាស្ត្រ។ អំណាចនេះមានសមត្ថកិច្ចលើការជំនុំជម្រះក្តីផ្តល់យុត្តិធម៌ និងផ្តន្ទាទោសទៅលើការបំពានច្បាប់ និង សម្រេចនូវវិវាទនានា។

[៩] មាត្រា ៥១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

ដូច្នេះគ្រប់រឿងក្តីទាំងអស់រួមទាំងរឿងក្តីរំលោភសេពសន្ថវៈផងនោះ គឺមានតែតុលាការទេ ដែលមានសិទ្ធិក្នុងការជំនុំជម្រះ ហើយក៏មានតែតុលាការដែរ ដែលមានសិទ្ធិក្នុងការវិនិច្ឆ័យថាជនណាម្នាក់ត្រូវមានទោស។ យ៉ាងណាមិញ មុននឹងតុលាការសម្រេចថាជនណាត្រូវមានទោសនោះ គាត់ត្រូវធ្វើការស៊ើបអង្កេតឲ្យបានល្អិតល្អន់ និងធ្វើការតាមដានបទល្មើសឲ្យបានច្បាស់លាស់ជាមុនសិន។ យើងមិនអាចកំណត់ថាវាជាបទល្មើសបានទេប្រសិនបើគ្មានច្បាប់ចែង ប៉ុន្តែក៏នៅមិនទាន់មានភាពគ្រប់គ្រាន់នោះទេ។ ម្យ៉ាងទៀតដើម្បីផ្តល់ទំនុកចិត្តដល់ប្រជាពលរដ្ឋមកលើខ្លួនវិញនោះ

- តុលាការត្រូវពិនិត្យឡើងវិញទាំងឯករាជ្យភាពរបស់ខ្លួន ដោយមិនត្រូវមានការ ជ្រៀតជ្រែកពីអ្នកមានអំណាច ដោយមានការបង្កើនប្រាក់បៀវត្សន៍ដល់មន្ត្រីតុលាការ ព្រមទាំងព្រះរាជអាជ្ញា ឲ្យមានជីវភាពសមស្របក្នុងការរស់នៅប្រចាំថ្ងៃ ដើម្បីកាត់បន្ថយអំពើពុករលួយ
- បង្កើនសមត្ថភាពក្នុងការវិនិច្ឆ័យក្តី គោរពឲ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌
- មានការសហការគ្នាយ៉ាងជិតស្និតជាមួយមន្ត្រីនគរបាលយុត្តិធម៌
- លុបបំបាត់ភាពអសកម្មទាំងឡាយដែលកើតមានក្នុងប្រព័ន្ធតុលាការ
- ក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវពិនិត្យឲ្យបានហ្មត់ចត់ ចំពោះដំណើរការនៃប្រព័ន្ធតុលាការ។

## ជំពូក២ អំពីព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ

នៅក្នុងស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជាបានបែងចែកជាឋានុក្រមដែលមាន សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ដូចជានៅបណ្តាប្រទេសមួយចំនួនមានតែព្រះរាជអាជ្ញាតែប៉ុណ្ណោះ ពុំមានចៅក្រមស៊ើបសួរនោះទេប៉ុន្តែដោយឡែកចំពោះប្រទេសកម្ពុជាវិញមានទាំងព្រះរាជអាជ្ញានិងចៅក្រមស៊ើបសួរ និងមានការបែងចែកមុខងារ និងតួនាទីយ៉ាងច្បាស់លាស់ដោយអ្នកទាំងពីគឺមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធិនីមួយៗមានបែងចែកតួនាទី និងមុខងារ ដូចជា ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជីជាដើម។ ដោយអ្នកទាំងពីសុទ្ធតែជាតួអង្គដែលសំខាន់ក្នុងការកំណត់អំពីបទល្មើស និងស្វែងរកភស្តុតាងក្នុងការដាក់បន្ទុក ឬ ដោះបន្ទុកនោះគឺ ធ្វើឡើងដោយព្រះរាជអាជ្ញាមានព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរនេះឯង។

### កថាខណ្ឌទី ១ អំពីព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាគឺជាម្ចាស់បណ្តឹងអាជ្ញា ជាអ្នកតំណាងឲ្យសង្គម និងការពារផលប្រយោជន៍សាធារណៈ មានតែព្រះរាជអាជ្ញាទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[១០]។ ព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងជាអ្នកសន្និដ្ឋានដើម្បីឲ្យតុលាការអនុវត្តច្បាប់។ ព្រះរាជអាជ្ញាធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទល្មើស ព្រហ្មទណ្ឌព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់របស់ខ្លួន។ ព្រះរាជអាជ្ញា ត្រូវតែមានវត្តមានក្នុងសវនាការជានិច្ចក្នុងរឿងក្តីព្រហ្មទណ្ឌ។

ក្នុងការបំពេញមុខងាររបស់ខ្លួន ព្រះរាជអាជ្ញាមានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ[១១]។ ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ព្រះរាជអាជ្ញាអាចចុះទៅទីកន្លែងស៊ើបងអង្កេត និងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះបាន។ ក្រៅពីនេះគាត់ក៏អាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា

[១០] មាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

[១១] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាចចូលរួមស្តាប់ចម្លើយ អាចត្រូវត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន[១២]។

ព្រះរាជអាជ្ញាត្រូវគោរពអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានុក្រម។ ពោលគឺរដ្ឋមន្ត្រីអាចប្តឹងបរិហារមកព្រះរាជអាជ្ញាអំពីបទល្មើសណាមួយដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ឲ្យព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការបានឡើយ[១៣]។ ម្យ៉ាងទៀតនៅក្នុងសវនាការ ព្រះរាជអាជ្ញាអាចធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរីតាមការដែលខ្លួនយល់ឃើញថាស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះព្រះរាជអាជ្ញា ដោយសារតែវាចារបស់ខ្លួនដែលបានបញ្ចេញនៅពេលសវនាការសោះឡើយ។

## ១. បណ្តឹងអាជ្ញា

បណ្តឹងអាជ្ញា គឺជាបណ្តឹងដែលសុំឲ្យពិន័យជាប្រាក់ ឬ ដាក់ពន្ធនាគារមានកាលកំណត់ ឬដាក់ពន្ធនាគារអស់មួយជីវិត។ មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស និងផ្តន្ទាទោសតាមច្បាប់កំណត់។

បណ្តឹងអាជ្ញាអនុត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ជំនឿ និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ[១៤]។

នៅក្នុងបទល្មើសរំលោភសេពសន្ថវៈ ការធ្វើបណ្តឹអាជ្ញាមានផលវិបាកជាច្រើនជូនកាលអាចអវត្តមាននូវបណ្តឹងអាជ្ញាក៏អាចមានផងដែរ ផលវិបាកនេះគឺដោយសារ ជនរងគ្រោះមានការអៀនខ្មាស់មិនហ៊ានប្តឹងដល់តុលាការថាមានអំពើរំលោភសេពសន្ថវៈមកលើខ្លួន។ ក្រៅពីការអៀនខ្មាស់ជនរងគ្រោះអាចនឹងមានការគំរាមគំហែងពីជនល្មើសដែលធ្វើជនរងគ្រោះមិនហ៊ានប្តឹងដើម្បីឲ្យមានដំណើរការបណ្តឹងអាជ្ញា។

[១២] មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[១៣] មាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[១៤] មាត្រា ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

## ១.១ ការចាប់ផ្តើមបណ្តឹងអាជ្ញា

ការចាប់ផ្តើមបណ្តឹងអាជ្ញាដោយអយ្យការ មានន័យថា តំណាងអយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ (អាចជាបទឧក្រិដ្ឋ មជ្ឈិម ឬ លហុ) និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរនិង យុត្តាធិការជំនុំជម្រះ[១៥]។ ការចាប់ផ្តើមបណ្តឹងអាជ្ញាដោយជនរងគ្រោះ ជាគោលការណ៍ថ្មីនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលអនុញ្ញាត ឱ្យជនរងគ្រោះ អាចដាក់ពាក្យបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ[១៦]។ បណ្តឹងនេះជាសេរីភាពឆន្ទៈរបស់បុគ្គលឯកជន ការដាក់ពាក្យបណ្តឹងនេះ គឺទាមទារឲ្យជនរងគ្រោះពិចារណាឲ្យបានល្អិតល្អន់បំផុត ព្រោះការចាប់ផ្តើមបណ្តឹងអាជ្ញាដោយវិធីនេះមានលក្ខណៈប្រថុយប្រថានខ្លាំងណាស់ ជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានទទួលការផាកពិន័យដោយចៅក្រមស៊ើបសួរនិងសងការខូចខាត ប្រសិនបើបណ្តឹងនោះធ្វើដោយរំលោភ ឬ អូសបន្លាយពេលវេលា[១៧] ។

នៅក្នុងបទល្មើសរំលោភសេពសន្ថវៈ ការចាប់ផ្តើមនៃបណ្តឹងអាជ្ញាភាគច្រើនកើតមកពីមានបណ្តឹងពីជនរងគ្រោះ ព្រោះបទល្មើសនេះមិនដូចជាបទល្មើសផ្សេងទៀតដែលអ្នកផងអាចដឹង ឬ បានឃើញដោយងាយៗនោះទេ។ បន្ទាប់ពីជនរងគ្រោះបានប្តឹងដល់ព្រះរាជអាជ្ញា ឬ មានបណ្តឹងបរិហារពីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញាអាចចាប់ផ្តើមបណ្តឹងអាជ្ញាបាន។

## ១.២ ការរលត់បណ្តឹងអាជ្ញា

ដោយយោងតាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌមានកត្តាជាច្រើនដែលធ្វើឲ្យមានការរលត់នៃបណ្តឹងអាជ្ញា តែដោយឡែកបណ្តឹងអាជ្ញា ចំពោះរឿងក្តីរំលោភសេពសន្ថវៈត្រូវបានរលត់ដោយមូលហេតុដូចខាងក្រោមៈ

- មរណភាពនៃជនល្មើស
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ
- ការផុតអាជ្ញាយុកាល

[១៥] មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[១៦] មាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[១៧] ដកស្រង់ពីការសែតភ្នំពេញប៉ុស្តិ៍ដោយលោក ឡាចសំរោង ថ្ងៃសុក្រ ទី ១៥ ខែកញ្ញា ឆ្នាំ ២០១៤

- ការលើកលែងទោសទូទៅ

## ២. បណ្តឹងបរិហារ

បណ្តឹងបរិហារគឺជាការប្តឹងបរិហារអំពីអំពើល្មើសព្រហ្មទណ្ឌណាមួយដែលបានកើតឡើងដល់មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីសាធារណៈ ឬ ព្រះរាជអាជ្ញាផ្ទាល់តែម្តង។ បណ្តឹងបរិហារអាចធ្វើឡើងដោយបុគ្គលដែលជាសិទ្ធិវន្តនៃជនរងគ្រោះ។ម្យ៉ាងវិញទៀតក្នុងបណ្តឹងនេះបុគ្គលណាក៏អាចធ្វើការប្តឹងបានដែរ ឲ្យតែបានដឹងអំពីអំពើល្មើសនោះច្បាស់លាស់ថាបានកើតឡើង បុគ្គលទាំងនោះអាចជាតតិយជន ជនរងគ្រោះជាដើម។ បណ្តឹងនេះធ្វើឡើងដើម្បីស្វែងរកភស្តុតាង និងឈានដល់ការវែកមុខចាប់ជនល្មើសមកផ្តន្ទាទោសតាមច្បាប់។

### ២.១ បណ្តឹងបរិហារដោយនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ គឺជាជំនួយការរបស់អំណាចតុលាការ ហើយគាត់អាចជាជំនួយរបស់ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរក្នុងការត្រួតពិនិត្យបទល្មើសឧក្រិដ្ឋ បទល្មើសមជ្ឈិម ឬ លហុកំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង[១៨]។

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹង និងពាក្យបណ្តឹងបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬ ពីមន្ត្រីនគរបាលយុត្តិធម៌មក[១៩]។

នេះបញ្ជាក់ឲ្យឃើញថាមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការប្តឹងបរិហារទៅព្រះរាជអាជ្ញាដើម្បីឲ្យព្រះរាជអាជ្ញាថ្លឹងថ្លែងថាតើគួរចេញដីកាស៊ើបអង្កេតបឋមក្នុងបទឧក្រិដ្ឋណាមួយដែរ ឬ ទេ។

ក្រោយពីទទួលបានបណ្តឹងមន្ត្រីនគរបាលយុត្តិធម៌ត្រូវចាត់ការភ្លាមៗ គឺធ្វើការស៊ើបអង្កេតដោយខ្លួនឯង ឬ ក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងទៅព្រះរាជអាជ្ញាដើម្បីចាត់ការ។ មុននឹងធ្វើការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចសុំសេចក្តីណែនាំពីព្រះរាជអាជ្ញា។ ប៉ុន្តែក្នុងករណីជាបទល្មើសរំលោភសេពសន្ថវៈ នគរបាលយុត្តិធម៌ចាំបាច់ត្រូវជូនពត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំព្រោះវាជាបទឧក្រិដ្ឋ។

[១៨] មាត្រា ៥៦នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[១៩] មាត្រា ៤០នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ២.២ បណ្ដឹងដោយជនរងគ្រោះ

កាលណាបុគ្គលម្នាក់រងគ្រោះដោយបទល្មើសមួយ ប្រតិកម្មរហ័សរបស់ជនរងគ្រោះ គឺជូនដំណឹងដល់អង្គភាពនគរបាល ជាទូទៅនៅក្រោមទម្រង់ប្រកាស ប៉ុន្តែនៅក្នុងបទល្មើសរំលោភសេពសន្ថវៈជនរងគ្រោះមួយចំនួន មិនហ៊ានជូនដំណឹងអំពីល្មើសមកលើខ្លួនដក់មន្ត្រីនគរបាលយុត្តិធម៌ភ្លាមៗឡើយ។ សាមីខ្លួនជូនដំណឹងដល់នគរបាលយុត្តិធម៌ ហើយដាក់ពាក្យបណ្ដឹងប្រឆាំងនឹងចារីម្នាក់ ឬ ច្រើននាក់។ បណ្ដឹងរបស់ជនរងគ្រោះគឺ របៀបទទួលបណ្ដឹងដែលគេប្រទះជាញឹកញាប់បំផុត[២០]។ កាលណាការជូនដំណឹងបានធ្វើឡើងតាមរបៀបសេចក្តីសន្និដ្ឋានស៊ើបសួរតាមទូរស័ព្ទការជូនដំណឹងនេះមានអានុភាពដូចគ្នា។ ក្រៅពីការប្ដឹងទៅនគរបាលយុត្តិធម៌ជនរងគ្រោះ ក៏អាចប្ដឹងទៅ មន្ត្រីសាធារណៈ ឬ ព្រះរាជអាជ្ញាដោយផ្ទាល់អំពីបទល្មើសដែលកើតឡើងចំពោះខ្លួនក៏បាន។

## ៣. គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់គឺជម្រើសរបស់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិពេញលេញ ដើម្បីធ្វើមូលវិចារណ៍ថាតើត្រូវ ឬ មិនត្រូវចាត់ការលើបណ្ដឹងរបស់ជនរងគ្រោះ ឬ បណ្ដឹងបរិហារពីជនណា ឬ អង្គការណាមួយពីបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានសន្មត់ថាបានកើតឡើង។

### ៣.១ ការបើកការស៊ើបសួរ

ចំពោះបទល្មើសរំលោភសេពសន្ថវៈ ព្រះរាជអាជ្ញាដាច់ខាតត្រូវបើកការស៊ើបសួរទោះបីជាជនសង្ស័យត្រូវបានគេចាប់បាននៅនឹងកន្លែងក៏ដោយ។ ការបើកការស៊ើបសួរនេះ គឺត្រូវបើកតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរប្ដឹងទៅចៅក្រមស៊ើបសួរ។ ការបើកការស៊ើបសួរនេះអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬ ច្រើននាក់ដោយចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងនឹងអញ្ញាតជន។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួមមាន:

- សេចក្តីសង្ខេបអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

[២០] សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាលអំណោយស្ថានទូតបារាំង

- ឈ្មោះបុគ្គលដែលរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ទម្រង់នេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នោះទេដីកានេះត្រូវចាត់ទុកជាមោឃៈ[២១]។

ដីកានេះមានសារៈសំខាន់ណាស់ក្នុងការផ្តល់សិទ្ធិសមត្ថកិច្ចពេញលេញក្នុងការចាត់ការរឿងក្តីដោយសេរីក្នុងការរកភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុក។ ជាពិសេសគឺស្វែងរកនូវការពិតមិនឲ្យមានភាពអយុត្តិធម៌ណាមួយកើតឡើងឡើយ។

## ៣.២ ការតម្កល់រឿងទុកឥតចាត់ការ

ព្រះរាជអាជ្ញា គឺជាម្ចាស់បណ្តឹងអាជ្ញា គាត់មានសិទ្ធិក្នុងការចោទប្រកាន់ទៅលើជនណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ ប៉ុន្តែ ព្រះរាជអាជ្ញាក៏មានសិទ្ធិតម្កល់រឿងទុកឥតចាត់ការបានដែរក្នុងល័ក្ខខ័ណ្ឌមួយចំនួនដូចជារកមិនឃើញតម្រុយពិរុទ្ធភាព ឬ វាកើតឡើងដោយសារការព្រមព្រៀងរវាងគូរភាគីក្នុងការរួមភេទ ដែលមិនមែនជាបទល្មើសរំលោភសេពសន្ថវៈ។

ប៉ុន្តែមុននឹងសម្រេចតម្កល់រឿងទុកឥតចាត់ការព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែមជាមុនសិន។ ព្រះរាជអាជ្ញា ត្រូវធ្វើតាមបង្គាប់របស់ថ្នាក់លើតាមឋានានុក្រមរបស់ខ្លួន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ អគ្គព្រះរាជអាជ្ញាអាចចេញអធិបញ្ញាឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ទៅលើអំពើណាមួយដែលខ្លួនយល់ឃើញថាជាបទល្មើសព្រហ្មទណ្ឌ។ ផ្ទុយមកវិញ ទោះបីជាមានឋានានុក្រមក៏ដោយ ក៏រដ្ឋមន្ត្រីនៃក្រសួងមហាផ្ទៃ ឬ អគ្គព្រះរាជអាជ្ញា មិនមានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការដែរ។

### ៣.២.១ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

កាលណាបណ្តឹងណាមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ខែ គិតចាប់ពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីដែលមានចែងក្នុងមាត្រា ៥០ (បញ្ជីនៃពាក្យប្តឹង) នៃក្រមនេះ[២២]។

ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងហេតុ និងសំអាងច្បាប់។ ការតម្កល់រឿងទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំទេ។

[២១] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[២២] មាត្រា ៩១ នៃក្រមនីតិព្រហ្មទណ្ឌឆ្នាំ ២០០៧

ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្ដីសម្រេចរបស់ខ្លួនវិញ ក្នុងខណៈដែលបណ្ដឹងមិនទាន់ផុតរលត់នៅឡើយ។

ប្រសិនបើអ្នកប្ដឹងមិនសុខចិត្តនិងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។

ការតវ៉ានេះត្រូវធ្វើឡើងក្នុងរយៈពេល ២ខែ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ការតវ៉ានេះត្រូវធ្វើតាមបណ្ដឹងសាមញ្ញនៅអង្គការអយ្យការដែលពាក់ព័ន្ធ។ បន្ទាប់មក សំណុំរឿងនឹងត្រូវបានបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយតំណាងអយ្យការសាលាដំបូង។

ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ញាឲ្យព្រះរាជអាជ្ញាអមសាលាដំបូងឲ្យធ្វើការចោទប្រកាន់។ អគ្គព្រះរាជអាជ្ញាធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តម្កល់សេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវឲ្យដំណឹងអំពីសេចក្ដីសម្រេចនេះដល់អ្នកប្ដឹងតវ៉ា។

### ៣.២.២ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ អះអាងថាការ តម្កល់រឿងទុកឥតចាត់ការគឺគ្មានអាជ្ញាអស់ជំនុំទេ។ គោលការណ៍អាជ្ញាអស់ជំនុំនៅពេលនេះមានន័យថា ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយជននេះមិនត្រូវបានគេធ្វើការចោទប្រកាន់ចំពោះអំពើដដែលនោះទៀតទេ ទោះបីស្ថិតក្រោមការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ។ ឯការសម្រេចតម្កល់រឿងទុកឥតចាត់ការជាការសម្រេចមួយដោយឆន្ទានុសិទ្ធរបស់ព្រះរាជអាជ្ញា មានន័យថានីតិវិធីនេះផ្ដោតសំខាន់លើការយល់ឃើញរបស់ព្រះរាជអាជ្ញា។ ដូចនេះ ការកំណត់ពីអាជ្ញាអស់ជំនុំមិនអាចស្ដែងឡើងបានទេដោយគ្រាន់តែពឹងលើការយល់ឃើញរបស់ព្រះរាជអាជ្ញា។ ភាពគ្មានអាជ្ញាអស់ជំនុំនេះនាំឲ្យព្រះរាជអាជ្ញាអាចសម្រេចចោទប្រកាន់ជាថ្មីលើអង្គហេតុដដែល នៅពេលណាដែលខ្លួនយល់ថា អង្គហេតុនោះបង្កើតជាបទល្មើសព្រហ្មទណ្ឌ លើកលែងតែផុតរលត់បណ្ដឹងអាជ្ញាប៉ណ្ណោះ។

## កថាខណ្ឌទី ២ អំពីចៅក្រមស៊ើបសួរ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ បានបង្កើតឲ្យមាននូវយុត្តាធិការស៊ើបសួរមានចំនួនពីរគឺ មន្ទីរស៊ើបសួរនៅតាមសាលាដំបូង និងសភាស៊ើបសួរដែលជាយុត្តាធិការស៊ើបសួរនៅសាលាឧទ្ធរណ៍។

ជាគោលការណ៍ ការស៊ើបសួរគឺត្រូវធ្វើឡើងដោយចៅក្រមស៊ើបសួរនៃមន្ទីរស៊ើបសួររបស់តុលាការជាន់ដំបូង ចំណែកឯសភាស៊ើបសួរវិញមានសមត្ថកិច្ចចម្បង គឺធ្វើការជំនុំជម្រះទៅលើពាក្យបណ្តឹងដែលប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលធ្វើឡើងដោយព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែនៅក្នុងល័ក្ខខ័ណ្ឌមួយចំនួនដែលចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់សិទ្ធិឲ្យសភាស៊ើបសួរក៏អាចធ្វើការស៊ើបសួរបានដែរ។

### ១. សមត្ថកិច្ចចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការធ្វើការស៊ើបសួរបានដោយមានការកំណត់ច្បាស់លាស់ពីក្រមនីតិវិធីព្រហ្មទណ្ឌគឺ សមត្ថកិច្ចដែនដី និងសមត្ថកិច្ចតាមការចាត់តាំងរបស់តុលាការ។

### ១.១ សមត្ថកិច្ចដែនដី

ចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចដែនដីគឺ

- ចៅក្រមស៊ើបសួរតួនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរមានតួនាទីនៅលំនៅដ្ឋាន ឬ ទីសំណាក់របស់បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។
- ចៅក្រមស៊ើបសួរមានតួនាទីកន្លែងចាប់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។ នៅក្នុងករណីមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នា ហើយទទួលនូវពាក្យបណ្តឹងព្រហ្មទណ្ឌទាំងអស់គ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលជាអ្នកមានសិទ្ធិសម្រេចថា ចៅក្រមស៊ើបសួររូបណាទទួលភារកិច្ចស៊ើបសួរ[២៣]។

[២៣] មាត្រា ១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ១.២ សមត្ថកិច្ចតាមការចាត់តាំង និងចែកសំណុំរឿងដោយប្រធានតុលាការ

កាលណាចៅក្រមស៊ើបសួរណាម្នាក់ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក ដោយមានជម្ងឺ ឬ មានមូលហេតុដ៏ទៃផ្សេងទៀត ចៅក្រមស៊ើបសួរផ្សេងទៀតនៃតុលាការដដែលត្រូវបានចាត់តាំងជាបណ្តោះអាសន្នដោយប្រធានតុលាការ ដើម្បីបំពេញមុខងារស៊ើបសួរ។

ក្នុងករណីដែលពុំមានចៅក្រមស៊ើបសួរទេ ចៅក្រមផ្សេងទៀតនៃតុលាការដដែលអាចត្រូវបានចាត់តាំងជាបណ្តោះអាសន្នដោយប្រធានតុលាការដើម្បីបំពេញមុខងារស៊ើបសួរ។

ប្រធានតុលាការចេញដីការចាត់តាំងមួយដែលពុំបើកផ្លូវតវ៉ាឡើយ។

លើសពីនេះ បទបញ្ញត្តិនៃមាត្រា ២៦ (ការបែងចែករឿងក្តី) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវតែគោរព[២៤]។

## ២. ការបើកការស៊ើបសួរ

តាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌការបើកការស៊ើបសួរត្រូវបានបើកតាមរយៈមធ្យោបាយពីរយ៉ាង៖

- ការបើកការស៊ើបសួរដោយអយ្យការ (តាមរយៈដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ) និង
- ការបើកការស៊ើបសួរដោយភាគីជនរងគ្រោះ (តាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី) [២៥]។

### ២.១ វិធានការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួររបស់ខ្លួន បើគិតថាមានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញការពិតដោយយោងតាមច្បាប់។ ចៅក្រមស៊ើបសួរដឹកនាំស៊ើបសួរដោយសេរី និងឯករាជ្យដោយមិនទទួលអធិបញ្ជាពីអាជ្ញាធរណាមួយឡើយ គាត់អាចប្រើប្រាស់អំណាចដោយផ្ទាល់ខ្លួន ឬប្រគល់អំណាចមួយចំនួនឲ្យមន្ត្រីនគរបាលយុត្តិធម៌តាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស។

[២៤] មាត្រា ៥១នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[២៥] មាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

### ២.១.១ ការជូនដំណឹងអំពីការដាក់ស្ថិតក្រោមការពិនិត្យ

យោងតាមមាត្រា ១៨៣ និងមាត្រា ១៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានកំណត់អំពីការជូនដំណឹងអំពីការដាក់ស្ថិតក្រោមការពិនិត្យ។

នៅពេលជូនដំណឹងលើកដំបូងចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ហើយប្រាប់ជននេះឲ្យបានដឹងអំពីរឿងរ៉ាវដែលបានចោទប្រកាន់ និងប្រាប់ឈ្មោះនៃបទល្មើសដែលបានកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬ មិនឆ្លើយបានដោយសេរី។ និទ្ទេសស្ដីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។

ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។

ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការស្នើសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។

ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេមេធាវី ត្រូវបានចាត់តាំងនៅក្នុងល័ក្ខខ័ណ្ឌដែលចែងដោយច្បាប់ស្ដីពីលក្ខន្តិកៈ។

ក្រោយពីការចូលបង្ហាញខ្លួនលើកទី១ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសន្នរបស់ខ្លួន។ ជនត្រូវចោទនេះត្រូវទទួលដំណឹងថាៈ

- ខ្លួនត្រូវតែជូនពត៌មានដល់ចៅក្រមស៊ើបសួរនៅពេលណាដែលខ្លួនផ្លាស់ប្ដូរអាសយដ្ឋាន
- គ្រប់ការឲ្យដំណឹងដែលបានធ្វើឡើងតាមអាសយដ្ឋានចុងក្រោយដែលប្រកាសដោយជនត្រូវចោទនោះ ត្រូវចាត់ទុកថាបានធ្វើដោយសាម៉ីខ្លួនផ្ទាល់។

ទោះបីជាមានការកំណត់ដូច្នេះក៏ដោយ នៅក្នុងករណីបទល្មើសរំលោភសេពសន្ថវៈការបង្ហាញខ្លួនលើកទីមួយ ដែលជនល្មើសនៅក្រៅឃុំដូច្នេះត្រូវតែធ្វើការតាមដានឲ្យបានជាប់លាប់ ពីព្រោះពេលខ្លះ ជនល្មើសអាចនឹងមានឱកាសក្នុងការកែប្រែនូវធាតុសំខាន់អ្វីមួយនៃភស្តុតាងក្នុងបទល្មើសរំលោភសេពសន្ថវៈនេះបានដោយងាយស្រួល។

ការឲ្យដំណឹងព្រមទាំងការប្រកាសស្ដីអំពីការផ្លាស់ប្ដូរអាសយដ្ឋាន ត្រូវចុះក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ។ អ្នកបកប្រែនោះត្រូវស្បថស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថាខ្លួននឹងជួយដល់តុលាការថានឹងបកប្រែឲ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ។ ម្យ៉ាងទៀតអ្នកបកប្រែមិនត្រូវជ្រើសរើសក្នុងចំណោម ចៅក្រម ក្រឡាបញ្ជី នគរបាលកងរាជអាវុធហត្ថ ភាគី ឬ សាក្សីទេ។

### ២.១.២ ការសួរចម្លើយ

នៅក្នុងករណីដែរកំពុងបំពេញកិច្ចរបស់ខ្លួន ចៅក្រមស៊ើបសួរមានសិទ្ធិសួរចម្លើយជនត្រូវចោទបាននៅតែចំពោះមុខមេធាវីតែប៉ុណ្ណោះ។ ដូច្នេះចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុតចំនួន ៥ថ្ងៃ មុនការសួរចម្លើយជនត្រូវចោទ ជនត្រូវចោទដោយនៅក្នុងថិរវេលានេះអាចឲ្យមេធាវីពិនិត្យមើលនូវសំណុំរឿងបាន។ ប៉ុន្តែក្នុងករណីនេះ នៅពេលដែលចៅក្រមស៊ើបសួរបានកោះហៅមេធាវីបានត្រឹមត្រូវហើយ ប៉ុន្តែមេធាវីមិនបានចូលបង្ហាញខ្លួនក្នុងថ្ងៃ និងម៉ោងដែលបានកំណត់នោះទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមានមេធាវីបាន ហើយនិទ្ទេសស្តីពីវត្តមានរបស់មេធាវីនេះ ត្រូវចុះនៅកំណត់ហេតុសួរចម្លើយរបស់ជនត្រូវចោទ។

នៅក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយមិនចាំបាច់ធ្វើការកោះហៅមេធាវី តែប្រសិនបើជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នៅវត្តមានរបស់មេធាវីរបស់ខ្លួន។ ការបោះបង់នេះត្រូវចុះនៅកំណត់ហេតុមួយផ្សេងទៀតពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ។ ជាមួយគ្នានេះ នៅករណីបន្ទាន់មួយទៀតចៅក្រមស៊ើបសួរធ្វើការសួរចម្លើយជនត្រូវចោទ ដោយមិនចាំបាច់កោះហៅមេធាវីក៏បានដែរ នៅក្នុងករណីដែលមានភាពបន្ទាន់។ ភាពបន្ទាន់ត្រូវតែបណ្តាលមកពីគ្រោះថ្នាក់រហូតដល់ស្លាប់ ឬ បណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនូវភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[២៦]។

ទន្ទឹមនឹងនេះ នៅក្នុងពេលដែលចៅក្រមស៊ើបសួរកំពុងសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវីក៏អាចលើកជាសំណួរផងដែរ ដោយមានការអនុញ្ញាតដោយចៅក្រមស៊ើបសួរ។

សម្រាប់រយៈពេលអប្បបរមា សម្រាប់ការសួរចម្លើយជនត្រូវចោទវិញ កាលណាថិរវេលា ៤ខែបានកន្លងផុតទៅដោយគិតចាប់ពីពេលសួរចម្លើយនៅពេលបង្ហាញខ្លួនលើកដំបូង ដោយជនត្រូវចោទមិនត្រូវបានសួរចម្លើយ ឬ សួរតទល់ទេ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយប្រសិនជនត្រូវចោទ

[២៦] មាត្រា ១៤៥ នៃក្រមនីតិព្រហ្មទណ្ឌឆ្នាំ ២០០៧

បានស្នើសុំ។ តែបើចៅក្រមស៊ើបសួរមិនបានកោះហៅជនត្រូវចោទក្នុងថេរវេលា ១ខែដោយគិតចាប់ពីថ្ងៃស្នើសុំរបស់ជនត្រូវចោទទេនោះ ជនត្រូវចោទអាចធ្វើការប្តឹងផ្ទាល់ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលទទួលចម្លើយនេះដោយខ្លួនឯងបាន ក្នុងករណីនេះកំណត់ហេតុត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ[២៧]។

ក្រៅពីនេះ មេធាវីក៏ត្រូវបានទទួលសិទ្ធិដែលអាចប្រាស្រ័យទាក់ទងដោយសេរីជាមួយកូនក្តីរបស់ខ្លួននៅក្នុងពន្ធនាគារ ឬ នៅកន្លែងឃុំខ្លួន។ ការសន្ទនារវាងមេធាវី និងជនត្រូវចោទត្រូវរក្សាជាការសម្ងាត់ ពោលគឺមិនត្រូវបានគេស្តាប់ថតបានទេ។ មេធាវីក៏អាចអានលំអិតនូវសំណុំរឿងដល់កូនក្តីរបស់ខ្លួនបានដែរ

## ២.១.៣ ការឆែកឆេរ និងការចាប់យកវត្ថុតាង

ការធ្វើការឆែកឆេរ អាចធ្វើទៅបាននៅទីកន្លែងកើតហេតុ ឬ លើបុគ្គលដែលប្រព្រឹត្តបទល្មើសផ្ទាល់តែម្តងចំពោះបទល្មើសរំលោភសេពសន្ថវៈការឆែកឆេរលើជនល្មើសគឺដើម្បីពិនិត្យមើលថាតើអាចមានតម្រុយដែលទាក់ទងទៅនឹងការប្រព្រឹត្តបទល្មើសដែរ ឬ ទេ។ ការឆែកឆេរនេះភាគច្រើនគេពិនិត្យមើលស្នាមរបួសនៅលើជនល្មើសដែលបានបង្កដោយជនរងគ្រោះ ក្នុងពេលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនោះការឆែកឆេរត្រូវតែមានដីកាពីព្រះរាជអាជ្ញា។ ជាទូទៅចំពោះបទល្មើសរំលោភសេពសន្ថវៈគឺមានការលំបាកក្នុងការឆែកឆេរដើម្បីប្រមូលភស្តុតាង ព្រោះភស្តុតាងក្នុងរឿងក្តីនេះងាយនឹងបាត់ខ្លាំងណាស់។ ដូចយើងបានដឹងរួចមកហើយថា ការឆែកឆេរអាចធ្វើទៅបានលុះត្រាតែគោរពទៅតាមច្បាប់ដែលបានកំណត់ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតជាក់ស្តែងដែរ គឺចន្លោះពីម៉ោង ១៨ និងម៉ោង ៦ ព្រឹក [២៨]។ ជាទូទៅជនរងគ្រោះនៃបទល្មើសរំលោភសេពសន្ថវៈទទួលរងនូវការរំលោភបំពាននៅកន្លែងស្ងាត់ និងដាច់ស្រយាល ដែលអាចឲ្យជនល្មើសធ្វើការគេចខ្លួនទាន់ពេលវេលា។

ដូចគ្នានេះដែរ ការឆែកឆេរការិយាល័យមេធាវីត្រូវធ្វើឡើងដោយមានវត្តមានប្រធានគណៈមេធាវី ឬ ប្រតិភូរបស់គាត់។

[២៧] មាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[២៨] មាត្រា ១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

អ្នកកាន់កាប់កន្លែងត្រូវមានវត្តមាន ឬ បើគ្មានអ្នកកាន់កាប់ទេគឺត្រូវមានសាក្សីពីរនាក់ដែលបានចាត់តាំងដោយចៅក្រមស៊ើបសួរ ដែលសាក្សីនេះមិនអាចជារាជអាវុធហត្ថ ឬ នគរបាល។

ចៅក្រមស៊ើបសួរត្រូវតែធ្វើកំណត់ហេតុស្ដីពីការឆែកឆេរ ដែលត្រូវមានការចុះអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ របស់សាក្សីនីមួយៗ និងជាយថាហេតុអត្តសញ្ញាណរបស់ប្រធានគណៈមេធាវី ឬ ប្រតិភូរបស់គាត់។ ជាចុងក្រោយ កំណត់ហេតុនេះត្រូវមានចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី។

ចំណែកឯការចាប់យកវត្ថុតាងចំពោះបទល្មើសរំលោភសេពសន្ថវៈវិញមានដូចជា សំលៀកបំពាក់ ឬ អាវុធដែលប្រើសម្រាប់ធ្វើការគំរាមដល់ជនរងគ្រោះជាដើម។ ការចាប់យកវត្ថុតាងនេះគឺដើម្បីយកទៅពិនិត្យមើលឲ្យបានច្បាស់លាស់ ថាតើវាមានភាពស៊ីចង្វាក់ក្នុងការប្រព្រឹត្តបទល្មើសទេ ដូចនេះទើបគេអាចយកវាធ្វើជាភស្តុតាងដាក់បន្ទុកលើជនត្រូវចោទបាន។ ច្បាប់អនុញ្ញាតឲ្យចៅក្រមស៊ើបសួរចាប់វត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាងនោះ។ នៅពេលក្រោយមកទៀត ដើម្បីឲ្យមានភាពប្រាកដថាវត្ថុដែលបានចាប់យកមកនោះពិតជាវត្ថុដែលបានចាប់បានក្នុងសុំណុំរឿងនីតិវិធីវត្ថុ ឬឯកសារត្រូវស្ថិតនៅក្រោមទម្រង់តែមួយនៃការបញ្ជាក់អត្តសញ្ញាណ ដូចក្នុងការស៊ើបអង្កេតជាក់ស្ដែងដែរ។ ជាអាទិ៍ វត្ថុតាងត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ និងមានបិទស្លាក បន្ទាប់ពីបានបង្ហាញដល់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សី។

នៅពេលបញ្ចប់នូវការស៊ើបសួរចៅក្រមស៊ើបសួរត្រូវវិនិច្ឆ័យទៅលើវត្ថុចាប់យកនោះ។ ចៅក្រមស៊ើបសួរអាចប្រគល់វត្ថុចាប់យកនោះដល់ម្ចាស់ដើមវិញប្រសិន យល់ឃើញថាវាមិនចូលរួមក្នុងការធ្វើឲ្យបទល្មើសកើតឡើងហើយនិងមិនបង្កគ្រោះថ្នាក់ ដូចជា ការបូប ឬ គ្រឿងអលង្ការជនរងគ្រោះ។ ប៉ុន្តែ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាវត្ថុដែលចាប់យកនោះអាចមានភាពរាំងដល់ការដាក់ទោសជនល្មើសហើយវាមានគ្រោះថ្នាក់ទៀតនោះចៅក្រមស៊ើបសួរត្រូវធ្វើការរក្សារទុក។

### ២.១.៤ កោសលវិច័យ

កោលសវិច័យ គឺជាការពិនិត្យធ្វើឡើងដោយអ្នកជំនាញចាត់តាំងដោយចៅក្រមស៊ើបសួរ ដែលសុំយោបល់បំភ្លឺលើបញ្ហាបច្ចេកទេសសុទ្ធសាធលើវិស័យនៃវេជ្ជសាស្ត្រ ពេទ្យវិជ្ជានីត្យានុកូល ពិន្ទុវិជ្ជា ជីវវិជ្ជា ចិត្តវិជ្ជា អង្គុលីទស្សន៍ អង្គលីលេខ ពិតមានវិទ្យា ។ល។

មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ចៅក្រមអាចបញ្ជាឲ្យមានការធ្វើការកោសលវិច័យ និងចាត់តាំងអ្នកជំនាញភ្លាមតាមពាក្យសុំរបស់ព្រះរាជអាជ្ញាគូភាគី។ ការបដិសេធសំណើរសុំនេះត្រូវធ្វើឡើងតាមរយៈដីកាដោយមានសំអាងហេតុ ដែលត្រូវចេញក្នុងរយៈពេល ៥ថ្ងៃ ប្រសិនបើពាក្យសុំចេញពីព្រះរាជអាជ្ញា និង ១ខែ ប្រសិនបើវាចេញពីជនត្រូវចោទ ឬភាគី រដ្ឋប្បវេណី[២៩]។ ដីកាបើកផ្លូវបណ្ដឹងឧទ្ធរណ៍។

អ្នកជំនាញត្រូវជ្រើសរើសពីក្នុងបញ្ជីអ្នកជំនាញជាតិដែលធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ បែបបទនៃការចុះឈ្មោះ និងលុបឈ្មោះចេញពីបញ្ជីត្រូវកំណត់ដោយប្រកាស។ អ្នកជំនាញដែលបានចុះឈ្មោះក្នុងបញ្ជីនេះ ត្រូវស្បថនៅចំពោះមុខសាលាឧទ្ធរណ៍នៅភ្នំពេញ ស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានឹងជួយដល់តុលាការដោយស្មោះត្រង់[៣០]។

បើចៅក្រមស៊ើបសួរចាត់តាំងអ្នកបច្ចេកទេសណាម្នាក់ដែលមិនមានឈ្មោះក្នុងបញ្ជីទេនោះគាត់ត្រូវឲ្យអ្នកបច្ចេកទេសនោះស្បថនៅចំពោះមុខគាត់[៣១]។

ក្នុងបទល្មើសរំលោភសេពសន្ថវៈ ការធ្វើកោលសវិច័យមានផលវិបាកច្រើន ព្រោះជនរងគ្រោះភាគច្រើនមានការអៀនខ្មាស់ ហើយមិនសូវយល់ដឹងអំពីការធ្វើកោសលវិច័យ។ ជនរងគ្រោះខ្លះដោយសារមានការអៀនខ្មាស់ដោយមិនបានទៅប្ដឹងដល់តុលាការទាន់ពេលវេលា ដូច្នេះការធ្វើកោសលវិច័យមានឧបសគ្គច្រើន ដូចជាការបាត់បង់តម្រុយភស្តុតាងផ្សេងៗជាដើម។

នៅក្នុងការធ្វើកោសលវិច័យបទល្មើលនេះគេបែងចែកជា ២របៀប គឺការធ្វើកោសលវិច័យផ្នែកខាងក្រៅ និងការធ្វើកោសលវិច័យផ្នែកខាងក្នុងៈ

❖ **ការធ្វើកោសលវិច័យផ្នែកខាងក្រៅ**

របួសដែលកើតឡើងច្រើនបំផុតចំពោះជនរងគ្រោះនៃអំពើរំលោភផ្លូវភេទមានៈ

១. របួសស្នាមដោយប្រើកម្លាំង និងមិនមុតដាច់

- ជាំ
- រលាត់ (ឆ្កូត)

[២៩] មាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[៣០] មាត្រា ១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[៣១] មាត្រា ១៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- របួសស្នាមមើលឃើញ

២. ស្នាមខាំ

៣. របួសស្នាមដែលប្រើកម្លាំងមុតដាច់

- របួសដាច់ (កាត់)
- របួសធ្លុះចូល (របួសចាក់)

កន្លែងដែលកើតច្រើនបំផុតនោះគឺ

- ដោះ
- ភ្លៅ
- បរិវេណប្រដាប់ពូជ
- រន្ធគូទ ឬគូទ
- មាត់ និងបបូរមាត់

❖ **ការធ្វើកោសលវិច័យផ្នែកខាងក្នុង**

ការធ្វើកោសលវិច័យនៅបរិវេណប្រដាប់បន្តពូជ-ទ្វាធំ ត្រូវបានអនុវត្តដើម្បីរៀបចំឯកសារពីរបួសស្នាម និងដើម្បីប្រមូលភស្តុតាងជីវសាស្ត្រ។ របួសប្រដាប់បន្តពូជ-ទ្វារធំ កើតឡើងលើជនរងគ្រោះប្រហែលមួយភាគបីដែលសារភាពថាមានអំពើរំលោភផ្លូវភេទថ្មីៗ។ របួសស្នាមស្រដៀងៗគ្នានេះអាចនឹងកើតឡើងក្នុងការរួមភេទដោយការយល់ព្រម។ របួសទាំងនេះជាទូទៅច្រើនមានឡើងក្រហម ជាំ រលាត់ និងរហែកសាច់។ ជាទូទៅ របួសស្នាមនេះកើតឡើងដោយសារការដាក់បញ្ចូល ឬការប៉ុនប៉ងដាក់បញ្ចូលជាមួយនឹងវត្ថុទាល ដូចជាលិង្គ ម្រាមដៃ ឬ វត្ថុដ៏ទៃទៀត។ ជាទូទៅ គឺគេមិនអាចកំណត់អំពីលក្ខណៈនៃវត្ថុដែលដាក់បញ្ចូលនោះទេ។ របួសស្នាមអាចទំនងនឹងកើតឡើងកាន់តែខ្លាំងប្រសិនជាមានសកម្មភាពដាក់បញ្ចូលចម្រុះ ឬ អ្នករំលោភច្រើន ប្រសិនជាវត្ថុនោះអជីវចលក្រោយពីស្ត្រីឈប់មានរដូវ និងមុនអាយុគ្រប់ការ និង ប្រសិនជាមិនមានជាតិរំអិលគ្រប់គ្រាន់[៣២]។

ជាទូទៅការធ្វើកោសលវិច័យខាងរាងកាយគឺ

➢ ពិពណ៌នាអំពីភាពផ្លូវចិត្ត និងអាការៈខាងក្រៅរបស់ជនរងគ្រោះ

[៣២] សេចក្តីណែនាំ ស្តីពី នីតិវេជ្ជសាស្ត្រ សម្រាប់ជំនួយក្នុងការធ្វើកោសលវិច័យ រៀបចំដោយក្រុមការងារអន្តរក្រសួង

- ពិពណ៌នា និងប្រមូលសំលៀកបំពាក់ដែលបានពាក់ក្នុងពេលរំលោភ
- ធ្វើកោសលវិច័យលើរូបរាងកាយទាំងស្រុង ដើម្បីរកមើលរបួស និងប្រមូលសំលៀកបំពាក់ដែលបានពាក់ក្នុងពេលរំលោភ
- ធ្វើកោសលវិច័យលើរូបរាងកាយទាំងស្រុង ដើម្បីរកមើលរបួសស្នាមដែលអាចមើលឃើញ (កត់ត្រាលើឌីយ៉ាក្រាមរាងកាយ និងមានការពិពណ៌នាជាលាយលក្ខណ៍អក្សរ)
  - ទីកន្លែងរបួស
  - ទំហំ
  - ទ្រង់ទ្រាយ
  - លក្ខណៈពិសេសដែលនៅជុំវិញ
  - ពណ៌
  - អាការៈក្រៅ
  - ការប្រែប្រួលស្នាម
  - ប្រភេទនៃស្នាមរបួស
  - គំរូណាមួយនៃស្នាមរបួស
  - ស្នាមខាំ
- រៀបចំមានការថតរូបរបួសស្នាមទូទៅ រាប់បញ្ចូលទាំងរូបថតតាមលំដាប់ជួរ និងរូបថតជិត

នៅពេលបញ្ចប់កោសលវិច័យ អ្នកជំនាញដែលត្រូវបានចាត់តាំងត្រូវប្រគល់ជូនចៅក្រមស៊ើបសួរនូវរបាយការណ៍ដែលមានការពិពណ៌នាអំពីប្រតិបត្តិការរបស់ខ្លួន និងសេចក្តីសន្និដ្ឋាន[៣៣]។ នៅពេលដែលទទួលបានចៅក្រមស៊ើបសួរជូនដំណឹងនេះទៅព្រះរាជអាជ្ញា និងកោះហៅជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទនោះ ដើម្បីប្រាប់ពួកគេឲ្យបានដឹងអំពីសេចក្តីសន្និដ្ឋាននៃរបាយការណ៍។ គាត់ធ្វើដូចគ្នាជាមួយដើមបណ្តឹងរប្បវេណី និងទីប្រឹក្សារបស់ដើមបណ្តឹងរប្បវេណីនោះ។ នៅពេលដែលបានធ្វើការជូនដំណឹងរួចហើយ ចៅក្រមស៊ើបសួរទុកពេលវេលាឲ្យភាគីដើម្បីស្នើសុំជាលាយលក្ខណ៍អក្សរ និងមានមូលហេតុត្រឹមត្រូវឲ្យធ្វើកោសលវិច័យបន្ថែម ឬ ឲ្យធ្វើប្រតិកោសល

[៣៣] មាត្រា ១៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

វិច័យ។ ថិរវេលានេះមិនអាចតិចជាង ១០ថ្ងៃបានទេ។ បើពាក្យសុំធ្វើឡើងដោយព្រះរាជអាជ្ញា ចៅក្រមមានរយៈពេល ៥ថ្ងៃដើម្បីចេញសេចក្តីសម្រេច។ ថិរវេលានេះ និងត្រូវលើកទៅ ១ខែ បើពាក្យសុំធ្វើឡើងដោយជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ បើពុំសម្រេចក្នុងរយៈពេលនេះទេ ភាគីអាចប្តឹងទៅសភាស៊ើបសួរដោយផ្ទាល់[៣៤]។

## ២.១.៥ ការស្តាប់ទូរស័ព្ទ

ការស្តាប់ទូរស័ព្ទ គឺជាការស្តាប់និងការថតសន្ទនាតាមទូរស័ព្ទ ការចាប់និងការថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ ដូចជាសារហ្វាក់ ឬ សារអាំងទែរនេត[៣៥]។ មានតែចៅក្រមស៊ើបសួរដែលទទួលពាក្យបណ្តឹងដោយស្របច្បាប់ប៉ុណ្ណោះ ដែលមានអំណាចបញ្ជាឲ្យមានការចាប់ការថត និងការចម្លងមកជាអក្សរនៃការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍។ ម្យ៉ាងទៀត គាត់អាចចុះដល់ទីកន្លែងដែលធ្វើការចាប់ និងការថតនេះ។ ប៉ុន្តែវិធានស៊ើបសួរនេះ ត្រូវតែចាំបាច់ដើម្បីបង្ហាញការពិត និងត្រូវមានគ្រប់ធាតុនៃការកំណត់អត្តសញ្ញាណនៃការទាក់ទងដែលចាប់ បទល្មើសដែលជាមូលហេតុនាំឲ្យមានការចាប់ និងថិរវេលានៃការចាប់នេះ។ សេចក្តីសម្រេចនៃការចាប់បើកផ្លូវតវ៉ា។

នៅក្នុងបទល្មើសរំលោភសេពសន្ថវៈ ការស្តាប់ទូរស័ព្ទកម្រនឹងកើតមានណាស់ ជាក់ស្តែងមានតែក្នុងករណីមានការគម្រាមកំហែងតែប៉ុណ្ណោះ។ ដូចនេះការស្តាប់ទូរស័ព្ទមិនអាចយកមកធ្វើជាភស្តុតាងក្នុងការចោទប្រកាន់ថាមានការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈទេ វាគ្រាន់តែជាពត៌មានសម្រាប់ការធ្វើការស៊ើបសួរ និងស្វែងរកភស្តុតាងតាមរយៈការស្តាប់នេះប៉ុណ្ណោះ។

## ២.១.៦ ដីកាចាត់ឲ្យស៊ើបសួរជំនួស

ដីកាចាត់ឲ្យស៊ើបសួរជំនួសអាចឲ្យនិយមន័យបានថា ជាប្រតិភូកម្មនៃអំណាចដែលចៅក្រមស៊ើបសួរប្រគល់ឲ្យ ចៅក្រមផ្សេង ឬ មន្ត្រីនគរបាល ឬ អង្គភាពនគរបាល ដើម្បីអនុវត្តកិច្ចស៊ើបសួរមួយ ឬច្រើនដែលគាត់កំណត់ ( មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ )។

ដោយមានន័យថាជាប្រតិភូកម្មអំណាច ដីកាចាត់ឲ្យស៊ើបសួរជំនួសអាចចេញតែដើម្បីផ្ទេរអំណាចដែលចៅក្រមមានតែប៉ុណ្ណោះ។ ដីកាចាត់ឲ្យសួរសាក្សី ក៏ត្រូវបានគ្រប់គ្រងដោយគោល

[៣៤] មាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[៣៥] មាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ការណ៍មួយដែលថែងថា ដីកាមិនអាចមានលក្ខណៈទូទៅទេ។ ព្រោះថាក្នុងករណីនេះ គឺវាដោះបន្ទុកចៅក្រមស៊ើបសួរពីសំណុំរឿង។ ចៅក្រមស៊ើបសួរអាចបញ្ឈប់ដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា និងមុនពេលដែលការអនុវត្តដីកានេះត្រូវបានបញ្ចប់[៣៦]។

ដីកាចាត់ឲ្យស៊ើបសួរជំនួសដែលត្រូវតែពិសេសជាដាច់ខាត ប៉ុន្តែតែត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់នូវកិច្ចដែលអនុញ្ញាត ព្រមទាំងថិរវេលានៃការធ្វើកិច្ចទាំងនេះ។ កិច្ចដែលសុំឲ្យធ្វើត្រូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលបានចោទប្រកាន់។ ក្នុងដីកាត្រូវតែមានចុះកាលបរិច្ឆេទ ហត្ថលេខា និងត្រារបស់ចៅក្រម។

ការភ្លេចនិទ្ទេសមួយក្នុងចំណោមនិទ្ទេសទាំងអស់នេះអាចបណ្តាលឲ្យមានមោឃភាពនៃដីកាចាត់ឲ្យស៊ើបសួរជំនួស និងមោឃភាពនៃគ្រប់កិច្ចដែលបានធ្វើជាបន្តបន្ទាប់។

ចៅក្រមស៊ើបសួរអាចផ្ទេរអំណាចរបស់គាត់ទៅឲ្យគ្រប់ចៅក្រមក្នុងតុលាការជាមួយខ្លួនគ្រប់ចៅក្រមស៊ើបសួរ ឬ មន្ត្រីនគរបាលយុត្តិធម៌ដើម្បីធ្វើកិច្ចក្នុងកន្លែងដែលគាត់មានសមត្ថកិច្ចដែនដី[៣៧]។

នៅពេលដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវបានប្រគល់ឲ្យចៅក្រម ចៅក្រមរូបនេះមានគ្រប់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ។

ក្នុងចំណោមនគរបាល និងអាវុធហត្ថមានតែមន្ត្រីនគរបាលយុត្តិធម៌ប៉ុណ្ណោះដែលអាចទទួលការផ្ទេរបែបនេះ។ ចៅក្រមស៊ើបសួរអាចចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ដែលមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនព្រមទាំងគ្រប់មន្ត្រីនគរបាលយុត្តិធម៌លើដែនដីប្រទេសទាំងមូល។ មន្ត្រីនគរបាលយុត្តិធម៌នេះស្ថិតនៅក្រោមអំណាផ្ទាល់របស់ចៅក្រមស៊ើបសួរ ក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស។

ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចផ្ទេរអំណាចទាំងអស់របស់ខ្លួនបានទេ។ អំណាចដែលមិនអាចត្រូវបានផ្ទេរទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ គឺអំណាចចោទប្រកាន់បុគ្គលណាម្នាក់ អំណាចសួរចម្លើយ ជនត្រូវចោទ ឬស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ( មាត្រា ១៨១នៃក្រមនីតិវិធីព្រហ្មទណ្ឌ )

[៣៦] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[៣៧] មាត្រា ១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

អំណាចសួរតទល់បុគ្គលខាងលើជាមួយ និងមនុស្សផ្សេងទៀត ឬ អំណាចចេញដីកា ឬ ធ្វើការឆែកឆេរក្នុងកន្លែងដែលការពារ ។

អំណាចដែលអាចផ្ទេរបានគឺ:

- ស្តាប់ចម្លើយសាក្សី។ បើក្នុងពេលស្តាប់ចម្លើយ មានលេចចេញនូវតម្រុយពិរុទ្ធភាពប្រឆាំងនិងសាក្សី ការស្តាប់ចម្លើយត្រូវបានបញ្ចប់ ដើម្បីឲ្យមន្ត្រីនគរបាលយុត្តិធម៌ផ្តល់ដំណឹងភ្លាមទៅចៅក្រមស៊ើបសួរ។
- ការឆែកឆេរ និងការចាប់យកវត្ថុ ដោយគោរពល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៥៩ និង ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ការឃាត់ខ្លួន អំណាចត្រួតពិនិត្យដែលធ្វើដោយព្រះរាជអាជ្ញាក្នុងក្រមខ័ណ្ឌនៃការស៊ើបអង្កេតតាមផ្លូវតុលាការត្រូវធ្វើដោយចៅក្រមស៊ើបសួរនៅពេលឃាត់ខ្លួនក្នុងក្របខ័ណ្ឌនៃដីកាចាត់ឲ្យស៊ើបសួរជំនួស។ នៅពេលដែលផុតវិធាននេះ បុគ្គលត្រូវបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។
- ការស្តាប់ទូរស័ព្ទ និងការថតការសន្ទនាតាមទូរស័ព្ទ និងការចាប់ការឆ្លងឆ្លើយតាមមធ្យោបាយទូរគមនាគមន៍ ជាការពិតណាស់ត្រូវធ្វើកំណត់ហេតុស្តីអំពីគ្រប់កិច្ចដែលត្រូវបានបំពេញដោយអនុវត្តតាមដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលនឹងត្រូវប្រគល់ទៅឲ្យចៅក្រមស៊ើបសួរដើម្បីត្រូវបញ្ចូលក្នុងសំណុំរឿងនៅពេលដែលកិច្ចត្រូវបានបំពេញចប់[៣៨]។

## ២.២ វិធានការនិរន្តរាយ

វិធាននេះ គឺជាអំណាចរបស់ចៅក្រមស៊ើបសួរ ក្នុងការបំពេញកិច្ចស៊ើបសួររបស់ខ្លួន ដើម្បីស្វែងរកឲ្យឃើញនូវការពិត នោះចៅក្រមស៊ើបសួរមានសិទ្ធិកោះអញ្ជើញនូវបុគ្គលណាមួយដែលមិនព្រមឆ្លើយតបតាមការកោះរបស់ខ្លួន ដោយការប្រើប្រាស់សិទ្ធិក្នុងការចេញនូវដីកាដែលជាវិធាននិរន្តរាយមួយចំនួនដូចខាងក្រោមនេះ។

[៣៨] ដកស្រង់ចេញពីសៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការឆ្នាំ២០០៧ ទំព័រ ៧៤

### ២.២.១ ដីកាបង្គាប់ឲ្យចូលខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចូលខ្លួន។ មានន័យថាគឺជាបញ្ជាដល់ជនណាម្នាក់ឲ្យចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ឬ មិនតែប៉ុណ្ណោះចៅក្រមស៊ើបសួរក៏អាចចេញដីកានេះ ទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលណាម្នាក់ដែលមាននូវតម្រុយពិរុទ្ធភាព។ នៅក្នុងករណីបទល្មើសរំលោភសេពសន្ថវៈ ការបង្គាប់ឲ្យចូលខ្លួនគឺពុំសូវមានករណីនេះកើតឡើងទេ ព្រោះប្រសិនបើនៅរង់ចាំការចេញដីកាបង្គាប់ឲ្យចូលខ្លួននោះ ជនល្មើសអាចធ្វើការរត់គេចខ្លួនបានយ៉ាងងាយស្រួល។

ដីកាបង្គាប់ឲ្យចូលខ្លួននេះមាននិទ្ទេសដូចតទៅ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ម៉ោង និងទីកន្លែងដែលត្រូវចូលមកបង្ហាញខ្លួននៅចំពោះមុខរបស់ចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា[៣៩]។

មិនតែប៉ុណ្ណោះ ដីកានេះត្រូវមានចុះនូវកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងមានបោះត្រាផង។

បន្ទាប់ពីចៅក្រមស៊ើបសួរបានចេញនូវដីកាបង្គាប់ឲ្យចូលខ្លួនហើយ ត្រូវឲ្យដំណឹងបុគ្គលដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា។ មានន័យថា មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ អាជ្ញាសាលាជាអ្នកមានភារកិច្ចអនុវត្តនៃដីកាបង្គាប់ឲ្យចូលខ្លួននោះ។ នៅពេលដែលអនុវត្តបុគ្គលដែលពាក់ព័ន្ធទទួលនូវចុងដីកា ហើយត្រូវចុះនូវហត្ថលេខានៅដើមដីកា ហើយដើមដីកានេះត្រូវបញ្ជូនទៅឲ្យចៅក្រមស៊ើបសួរវិញ។ ករណីដែលអនុវត្តនៃបេសកម្មនេះ ប្រសិនបើជួបប្រទះនូវការលំបាកនោះ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារ

[៣៩] មាត្រា ១៨៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នគរបាលយុត្តិធម៌ ឬ អាជ្ញាសាលា ត្រូវរាយការណ៍អំពីបញ្ហាលំបាកទាំងនេះជូនទៅដល់ចៅក្រមស៊ើបសួរ[៤០]។

### ២.២.២ ដីកាបង្គាប់ឲ្យនាំខ្លួន

ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាបញ្ជារដល់កងកម្លាំងសាធារណៈឲ្យចាប់នៃខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់នាំខ្លួននេះអាចត្រូវបានចេញទៅលើជនត្រូវចោទ ឬ ទៅលើបុគ្គលដែលមានតម្រុយពិរុទ្ធភាព[៤១]។ និទ្ទេសដែលមានចុះនៅក្នុងដីកាបង្គាប់ឲ្យនាំខ្លួននេះមានដូចជា

- អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់និងបង្ក្រាប់បទល្មើសនេះ។
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

មិនតែប៉ុណ្ណោះដីកានេះ ត្រូវមានការចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងមានបោះត្រាផង[៤២]។

**ចំពោះនីតិវិធីនៃការអនុវត្តៈ** ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនត្រូវប្រគល់ឲ្យទៅមន្ត្រីនគរបាលយុត្តិធម៌។ តែនៅក្នុងករណីបន្ទាន់ដីកាបង្គាប់ឲ្យនាំខ្លួនធ្វើកាផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយដែលអាចធ្វើបាន។ ក្នុងពេលបំពេញបេសកកម្មនេះ ដើមដីកាត្រូវប្រគល់ជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកអនុវត្តនៃដីកានេះ។ មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធ មុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ឡើយ។ ប្រសិនបើជួបប្រទះនូវការលំបាកនោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ពីបញ្ហាលំបាកទាំងនេះជូនទៅចៅក្រមស៊ើបសួរដែលជាអ្នកចេញដីកាបង្គាប់ឲ្យនាំខ្លួននេះ[៤៣]។

[៤០] មាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[៤១] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[៤២] មាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[៤៣] មាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នៅពេលអនុវត្តបេសកកម្មនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ប្រសិនបើមានមូលហេតុនៃកាលៈទេសៈមានដូចជាលំបាកនៅក្នុងការដឹកជញ្ជូន ដែលជាមូលហេតុមិនអាចនាំខ្លួនបុគ្គលដែលមិនពាក់ព័ន្ធទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានភ្លាមៗនោះ បុគ្គលនេះត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬ ទៅក្នុងពន្ធនាគារ។ បុគ្គលនេះត្រូវតែនាំទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសករណីដែលការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។ ហើយកាលណាបុគ្គលម្នាក់ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនត្រូវបានឃុំខ្លួននោះ ចិរវេលានៃការឃុំខ្លួនត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើមាន។

### ២.២.៣ ដីកាបង្គាប់ឲ្យចាប់ខ្លួន

ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាដីកាដែលបញ្ជាដល់កងកម្លាំងប្រដាប់អាវុធឲ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនបុគ្គលនោះនៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ ហើយម្យ៉ាងទៀត ជាការបញ្ជារដល់ពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ។

ជាទូទៅដីកាបង្គាប់ឲ្យចាប់ខ្លួនចំពោះបទល្មើសរំលោភសេពសន្ថវៈ ត្រូវតែធ្វើការចាប់ខ្លួនជនល្មើសឲ្យបានឆាប់រហ័ស ព្រោះដើម្បីបង្ការកុំឲ្យជនល្មើសធ្វើការគេចខ្លួន ឬ ពេលខ្លះអាចបំផ្លាញតម្រុយដ៏សំខាន់។ ដីកាបង្គាប់ឲ្យចាប់ខ្លួន អាចធ្វើទៅបានទោះជាពុំមានដីកាបង្គាប់ឲ្យចូលខ្លួន ឬ នាំខ្លួនក៏ដោយ។

ដីកាបង្គាប់ឲ្យចាប់ខ្លួន ជាដីកាដែលអាចចេញទៅលើជនត្រូវចោទ ឬ បុគ្គលណាដែលមានតម្រុយពិរុទ្ធភាព។ ករណីនេះល័ក្ខខ័ណ្ឌដែលចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបានលុះត្រាតែ:

- បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងស្ថិតនៅកន្លែងណា ឬ ស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។
- មុននឹងចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ចៅក្រមស៊ើបសួរត្រូវតែទទួលនូវយោបល់ពីព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវចេញដីកានេះដោយមានមូលហេតុច្បាស់លាស់ និងក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញាជានាព៌រងនូវការផ្សព្វផ្សាយដីកា

បង្គាប់ឲ្យចាប់ខ្លួននេះ រីឯនិទ្ទេសដែលមានចុះក្នុងដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវចុះនូវពត៌មានដូចខាងក្រោម:

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ។
- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបទល្មើសនេះ។
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។
- ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង[៤៤]។

***នីតិវិធីនៃការអនុវត្ត:*** ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌។ នៅក្នុងករណីបន្ទាន់ ដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។ ដើមដីកាត្រូវប្រគល់ក្នុងរយៈពេលខ្លីបំផុតឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកនូវដីកាបង្គាប់ឲ្យចាប់ខ្លួននោះ។ ករណីនេះមន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨បានឡើយ[៤៥]។ នៅគ្រប់ការលំបាករបស់ខ្លួននៅអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួននេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនទៅចៅក្រមស៊ើបសួរដែលជាអ្នកចេញដីកា។ ក្នុងករណីចាំបាច់ ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានាដែលមានប្រសិទ្ធិភាព។ ម្យ៉ាងទៀត ការបង្ហាញដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាបញ្ជាឲ្យប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ត្រូវទទួលនិងឃុំខ្លួន ជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួន។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនរក្សាទុកនូវដើមដីកា ឬ ចុងដីកាដែលមានបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម[៤៦]។

នៅពេលដែលចាប់ខ្លួនបុគ្គលដែលពាក់ព័ន្ធបានហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវនាំជននោះទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសក្នុងរយៈពេលយ៉ាងខ្លីបំផុត ប្រសិនបើស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ ផ្ទុយទៅវិញករណីដែលជននោះ មិនត្រូវបានបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន បុគ្គលនេះត្រូវព្រះរាជអាជ្ញានាទី

[៤៤] មាត្រា ១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[៤៥] មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[៤៦] មាត្រា ២០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

កន្លែងឃុំខ្លួនស្តាប់ចម្លើយ។ ព្រះរាជអាជ្ញានឹងធ្វើកំណត់ហេតុស្តាប់ចម្លើយ ដែលកំណត់ហេតុនោះនឹងត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ។ កាលណាបុគ្គលម្នាក់ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវបានឃុំខ្លួននោះថិរវេលានៃការឃុំខ្លួននេះ ត្រូវរាប់បញ្ចូលក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើមាន[៤៧]។

### ២.២.៤ ដីកាបង្គាប់ឲ្យឃុំខ្លួន

ដីកាបង្គាប់ឲ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនឲ្យទទួល និងឲ្យឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។ ខ្លឹមសារនៃមាត្រានេះ វាហាក់ដូចជាហាមឃាត់មិនឲ្យជនត្រូវចោទមានសេរីភាពក្នុងការដើរហើរ ព្រោះជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព។ ប៉ុន្តែនៅក្នុងករណីពិសេសជនត្រូវចោទអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នបាន នេះជាបញ្ញត្តិដែលបានចែងពីអំណាចរបស់ចៅក្រមស៊ើបសួរ ដែលខ្លួនត្រូវទទួលបាននូវសិទ្ធិនេះដើម្បីជាជំនួយដល់ការស្វែងរកនូវការពិត។ ទន្ទឹមនឹងនេះមិនមែនមានន័យថា គ្រប់ជនត្រូវចោទសុទ្ធត្រូវបានធ្វើការឃុំខ្លួនបណ្តោះអាសន្នបានឡើយ។ មានន័យថា ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែនៅក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ មជ្ឈិមដែលច្បាប់បានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើស ១ ឆ្នាំ ប៉ុណ្ណោះ[៤៨]។

*មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទល្មើសរំលោភសេពសន្ថវៈ* ដើម្បីឲ្យមានភាពកាន់តែច្បាស់លាស់នោះ សូមពិនិត្យមើលមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងដូចខាងក្រោម:

- ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី។
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។
- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ។
- ដើម្បីធានាការពារសន្តិសុខជនត្រូវចោទ។ នេះជាល័ក្ខខ័ណ្ឌ ដែលអាចធ្វើការឃុំខ្លួនបណ្តោះអាសន្នបាន ទោះបីចៅក្រមស៊ើបសួរធ្វើការជ្រើសរើសយកនូវល័ក្ខខ័ណ្ឌណា

[៤៧] មាត្រា ២០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[៤៨] មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

មួយនៅក្នុងចំនោមល័ក្ខខ័ណ្ឌទាំងនេះក៏ដោយសុទ្ធតែអាចជាមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នបានទាំងអស់[៤៩]។

***នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន:*** ជាគោលការណ៍ នៅក្នុងករណីចៅក្រមស៊ើបសួរសម្រេចធ្វើការឃុំខ្លួនបណ្ដោះអាសន្នដោយគំនិតរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាក៏ដោយ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីដីកាសម្រេចនេះដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញនូវមធ្យោបាយការពារឲ្យកូនក្ដីរបស់ខ្លួន។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នតាមដីកាដែលមានសំអាងហេតុ ហើយត្រូវឲ្យដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[៥០]។

ដីកាសម្រេចឲ្យឃុំខ្លួនត្រូវមានចុះនិទ្ទេសដូចខាងក្រោម:

- អត្តសញ្ញាណជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[៥១]។

***ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន:*** ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានកំណត់ដូចខាងក្រោម:

### ❖ ចំពោះអនីតិជន

ជាគោលការណ៍ ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន គឺមានលក្ខណៈខុសគ្នារវាងអនីតិជន និងនីតិជន។ ចំពោះអនីតិជនដែលមានអាយុតិចជាង ១៤ ឆ្នាំមិនអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្នទេ ដោយចៅក្រមស៊ើបសួរអាចធ្វើការសម្រេចប្រគល់អនីតិជននោះឲ្យទៅឪពុកម្ដាយ ឬ អ្នកអាណា

[៤៩] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[៥០] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[៥១] ដកស្រង់ចេញពីសៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់សាស្ត្រាចារ្យ អៀង សំណាង ឆ្នាំ២០១៥ ទំព័រ១១៦

ព្យាបាល ឬ បើគ្មានអាណាព្យាបាលទេ ត្រូវប្រគល់ឲ្យទៅមជ្ឈមណ្ឌលអប់រំបណ្តោះអាសន្នរង់ចាំសេចក្តីសម្រេចរបស់តុលាការ។ ដោយឡែកអនីតិជនដែលមានអាយុ ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំអាចនឹងត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ប្រសិនអនីតិជននោះបានប្រព្រឹត្តនូវបទឧក្រិដ្ឋណាមួយនោះ។

ការឃុំខ្លួនបណ្តោះអាសន្ននោះត្រូវបានកំណត់ដូចតទៅ:

- ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤ ខែ បានទេ កាលណាអនីតិជនមានអាយុតិចជាង ១៦ ឆ្នាំ។
- ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៦ ខែ បានទេ កាលណាអនីតិជនមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ[៥២]។

❖ **ចំពោះនីតិជន**

ចំពោះនីតិជនដែលបានត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ ខែ បានទេ ។ ប៉ុន្តែនៅពេលផុតថិរវេលានេះចៅក្រមស៊ើបសួរអាចធ្វើការពន្យារការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ៦ ខែ ដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានតែ ២ ដងគត់។

## ២.៣ ការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរមានអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាមិនបានចង្អុលប្រាប់ឈ្មោះនៅដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ។ ចៅក្រមស៊ើបសួរអាចដាក់បុគ្គលឲ្យស្ថិតក្រោមការពិនិត្យក្នុងឋានៈជាចារី ជាអ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត។

ចៅក្រមស៊ើបសួរ វាយតម្លៃអំពីកាលានុវត្តភាពនៃការជូនដំណឹងពីការដាក់ឲ្យស្ថិតក្រោមការពិនិត្យ ជាយថាហេតុ បន្ទាប់ពីបានធ្វើការស៊ើបសួរចាំបាច់ផ្សេងៗរួចមក។

បុគ្គលដែលមានចង្អុលបង្ហាញប្រាប់ឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាត្រូវស្តាប់ដោយចៅក្រមស៊ើបសួរតែក្នុងឋានៈជាជនត្រូវចោទតែប៉ុណ្ណោះ ចៅក្រមស៊ើបសួរមានកាតព្វកិច្ចដាក់ឲ្យស្ថិតក្រោមការពិនិត្យនូវបុគ្គលនោះ។ ចៅក្រមស៊ើបសួរមិនអាចស្តាប់ក្នុង

[៥២] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ឋានៈជាសាក្សីនូវបុគ្គលដែលមានតំរុយពិរុទ្ធភាពនោះទេ[៥៣]។ ប្រសិនបើចៅក្រមស៊ើបសួរបំពានលើមាត្រា ១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះអាចបណ្តាលឲ្យមានមោឃភាពនៃនីតិវិធីបាន។

## ២.៣.១ បែបបទនៃការដាក់ស្ថិតក្រោមការពិនិត្យ

កាលណាចៅក្រមស៊ើបសួរធ្វើការសម្រេចដោយត្រូវដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ ដែលការសម្រេចនេះអាចជាគំនិតផ្តួចផ្តើមរបស់ខ្លួន ឬ តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ ករណីនេះចៅក្រមស៊ើបសួរត្រូវបញ្ជាក់ពីកាតព្វកិច្ចដែលតម្រូវទៅលើជនត្រូវចោទ។

ដីការសម្រេចដាក់ជនត្រូវចោទ ឲ្យស្ថិតនៅក្រោមកាពិនិត្យតាមផ្លូវតុលាការនោះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និងជនត្រូវចោទឲ្យបានដឹងនូវការសម្រេចនេះ។

ជាមួយគ្នានេះ នៅក្នុងករណីដែលចៅក្រមស៊ើបសួរបានទទួលពាក្យបណ្តឹងពីព្រះរាជអាជ្ញាដោយសុំឲ្យដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ តែចៅក្រមស៊ើបសួរមិនយល់ព្រមតាមការសុំទេនោះ ចៅក្រមស៊ើបសួរត្រូវចេញដីការបដិសេធនៅក្នុងពេល៥ថ្ងៃ។ ដីកាសម្រេចបដិសេធនេះ ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាជាបន្ទាន់។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ថ្ងៃទេ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែលមានសិទ្ធិសម្រេចជំនួសទៅចៅក្រមស៊ើបសួរបាន[៥៤]។

នៅក្នុងដីការនេះត្រូវតែមានចុះនិទ្ទេសឲ្យបានច្បាស់លាស់ និងបញ្ជាក់អំពីកាតព្វកិច្ចជាចាំបាច់ដែលតម្រូវឲ្យជនត្រូវចោទយកទៅប្រតិបត្តិ។

ផ្នែកនៃសេចក្តីសម្រេចរបស់ដីកា ត្រូវមានបញ្ជាក់ឲ្យបានច្បាស់លាស់នូវកាតព្វកិច្ចដែលតម្រូវឲ្យជនត្រូវចោទអនុវត្ត។

ដីកានេះត្រូវមានចុះលេខរៀងនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងត្រូវមាន

[៥៣] មាត្រា ១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៥៤] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

បញ្ជាក់អំពីចំណាត់ការបន្តលើការឃុំខ្លួនជនត្រូវចោទ ប្រសិនបើជនត្រូវចោទនោះបានគេចវេសមិនគោរពកាតព្វកិច្ចដែលត្រូវបានកំណត់ក្នុងផ្នែកសេចក្តីសម្រេចនៃដីកា។

ដីកានេះត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ រួមទាំងក្រឡាបញ្ជី និងមានបោះត្រាផង។ ការមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់នៃនិទ្ទេសខាងលើ អាចនឹងនាំឲ្យដីកានេះពុំមានអានុភាព ឬ គ្មានតម្លៃជាកម្មវត្ថុសម្រាប់យកទៅអនុវត្តបានឡើយ។

### ២.៣.២ អានុភាពនៃការដាក់ឲ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ

បុគ្គលដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលការនឹងត្រូវក្លាយជាភាគីនៃសំណុំរឿងក្តីព្រហ្មទណ្ឌ ក្នុងឋានៈជាជនត្រូវចោទ។ គាត់អាចមានសិទ្ធិទទួលជំនួយពីមេធាវីក្នុងការការពារខ្លួន គាត់មានសិទ្ធិឆ្លើយ ឬ មិនឆ្លើយ សិទ្ធិត្រូវបានស្តាប់ចៅក្រម និងមិនមែនដោយមន្ត្រីនគរបាលយុត្តិធម៌ សិទ្ធិទទួលពត៌មានពីសកម្មភាពខាងផ្នែកតុលាការរបស់ចៅក្រម សិទ្ធិសុំមោឃភាពនីតិវិធី សិទ្ធិចូលរួមយ៉ាងសកម្មក្នុងដំណើរការស៊ើបសួរដែលសុំទៅចៅក្រមឲ្យធ្វើការស្រាវជ្រាវមួយចំនួន។ ម្យ៉ាងទៀតគាត់អាចសុំឲ្យចៅក្រម ធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយរបស់ភាគីរដ្ឋប្បវេណី ឬ សាក្សី ធ្វើការសួរចម្លើយតទល់ ឬ ចុះទៅទីកន្លែង។ ការស្នើសុំនេះត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុដែលអនុញ្ញាតឲ្យបញ្ជាក់ពីផលប្រយោជន៍របស់វា។ ប្រសិនបើចៅក្រមស៊ើបសួរបដិសេធនិងសំណើរនេះ គាត់ត្រូវចេញដីកាដោយមានសំអាងហេតុក្នុងចិរវេលា ១ខែបន្ទាប់ពីបានទទួលពាក្យសុំនោះ។ ដីកានេះត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទក្នុងរយៈពេលខ្លីបំផុត។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១ខែដែលបានកំណត់នេះ ជនត្រូវចោទអាចប្តឹងទៅសភាស៊ើបសួរដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបាន[៥៥]។

## ៣. ការបិទការស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរយល់ឃើញថាកិច្ចស៊ើបសួរត្រូវបានបញ្ចប់ នោះចៅក្រមស៊ើបសួរអាចសម្រេចបិទកាស៊ើបសួរដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន។ ចំពោះការបិទការស៊ើបសួរនេះចៅក្រមស៊ើបសួរត្រូវ ជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី អំពីការបិទការស៊ើបសួរនេះ។ បន្ទាប់មកគាត់ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ២ថ្ងៃក្រោយការជូនពត៌មានអំពីការបិទការស៊ើបសួរនេះ។ ក្នុងអំឡុងពេលនេះ ប្រសិនបើព្រះរាជអាជ្ញា ជនត្រូវចោទ

[៥៥] ដកស្រង់ចេញពីសៀវភៅ មេរៀននីតិវិធីព្រហ្មទណ្ឌ របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការឆ្នាំ ២០០៧ ទំព័រ៦១

ដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម ចៅក្រមស៊ើបសួរត្រូវសម្រេចពីបញ្ហានេះ ដោយយោងតាមមាត្រា ១៣២ ដល់ ១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាអាចចេញ ដីកាចាត់ឲ្យស៊ើបសួរបន្ថែម។ ក្រោមពីបានស៊ើបសួរបន្ថែមចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានពីការបិទការស៊ើបសួរសារជាថ្មីម្តងទៀត។

ព្រះរាជអាជ្ញាត្រូវបង្វិលសំណុំរឿងឲ្យចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់មកជាមួយផង ក្នុងរយៈពេល ១៥ថ្ងៃ បើជនត្រូវចោទត្រូវឃុំខ្លួន និង ១ខែ បើជនត្រូវចោទនៅក្រៅឃុំគិតចាប់ពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង។ ដីកាសន្និដ្ឋានស្ថាពរត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ នៅក្នុងដីកាសន្និដ្ឋានស្ថាពរ ព្រះរាជអាជ្ញាអាចប្តឹងឲ្យចៅក្រមស៊ើបសួរ បញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់[៥៦]។

## ៣.១ ដីកាសម្រេចលើកលែងការចោទប្រកាន់

នៅក្នុងបទល្មើសរំលោភសេពសន្ថវៈ ចៅក្រមស៊ើបសួរអាចសម្រេចមិនប្តឹងជនត្រូវចោទទៅសវនកានៅពេលដែល:

- អំពើមិនមែនជាបទល្មើសរំលោភសេពសន្ថវៈទេ តែបែរជាការព្រមព្រៀងរបស់ភាគីទាំងពីរ
- អ្នកប្រព្រឹត្តនៅតែត្រូវគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជននោះ[៥៧]។

ជានិច្ចការនៅក្នុងដីកាត្រូវមានសំអាងហេតុ ចៅក្រមស៊ើបសួរមិនចាំបាច់ត្រូវតែគោរពដីកាស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ក្រោយពេលដែលដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរចូលជាស្ថាពរ ព្រះរាជអាជ្ញាអាចផ្តួចផ្តើមឲ្យមានការបើកការស៊ើបសួរឡើងវិញនៅនូវបន្ទុកថ្មី។ ដីកានេះត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

[៥៦] មាត្រា ២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

[៥៧] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

## ៣.២ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ

នៅពេលដែលចៅក្រមស៊ើបសួរមានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកថាវាជាបទល្មើសរំលោភសេពសន្ថវៈ នោះចៅក្រមស៊ើបសួរចេញដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះនៅចំពោះមុខតុលាការ[៥៨]។

ដីកានេះ ដកសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរឲ្យទៅតុលាការដែលសំណុំរឿងបានបញ្ជូនទៅជំនុំជម្រះ។ ដីកានេះបញ្ចប់ការពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្តោះអាសន្ន ប៉ុន្តែនៅមានល័ក្ខខ័ណ្ឌមួយចំនួនដែលចៅក្រមស៊ើបសួរ ត្រូវសម្រេចរក្សាជនត្រូវចោទឲ្យជាប់ឃុំរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ កាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការអាចរក្សាទុកតាមបែបបទតែមួយនឹងការឃុំខ្លួនរហូតដល់ពេលចូលបង្ហាញខ្លួននៅមុខតុលាការ។ ក្នុងករណីនេះគាត់ត្រូវមានសំអាងហេតុទៅលើសេចក្តីសម្រេចរក្សាទុកឲ្យនៅក្រៅឃុំ ដោយមានមូលហេតុណាមួយដែលមាននៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ប៉ុន្តែប្រសិនបើជនត្រូវចោទមិនបានចូលបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤ ខែ គិតពីកាលបរិច្ឆេទនៃដីកាសន្និដ្ឋានបញ្ជូនទៅជំនុំជម្រះទេ នោះគាត់នឹងត្រូវដោះលែងភ្លាម។

---

[៥៨] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

# ជំពូក ៣ បទល្មើសរំលោភសេពសន្ថវៈក្នុងទំនាក់ទំនង ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ

គ្រប់ការងារទាំងអស់សុទ្ធតែមានទំនាក់ទំនងគ្នា មិនថាការងារបែបណាក៏ដោយ។ សង្គមមួយមានការអភិវឌ្ឍន៍លុះត្រាតែមនុស្សទាំងអស់មានទំនាក់ទំនងគ្នាយ៉ាងជិតស្និត មិនថាទាំងការរស់នៅក៏ដូចជាការប្រាស្រ័យការងារគ្នា ព្រោះដើម្បីផ្លាស់ប្តូរគំនិតយោបល់ និងកែលំអរគ្នាផងទៅវិញទៅមកដែរ។ យ៉ាងណាមិញ ក៏ដូចជាព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរដែរ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងការចាត់ការបណ្តឹងនីមួយៗចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា មានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ដើម្បីធ្វើឲ្យបណ្តឹងដំណើរការមានភាពងាយស្រួលក្នុងការស្វែងរកភស្តុតាងដើម្បីធ្វើការចោទប្រកាន់ ឬ មិនចោទប្រកាន់ឲ្យបានឆាប់រហ័ស និងមានភាពយុត្តិធម៌។ ទទឹមនិងនេះ ចំពោះទំនាក់ទនងរវាងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរក្នុងករណីបទល្មើសរំលោភសេពសន្ថវៈនេះ យើងឃើញថាជួនកាលនីតិវិធីអាចប្រព្រឹត្តមានភាពរលូន ឯពេលខ្លះទៀតអ្នកទាំងពីរអាចមានគំនិតខ្វែងគ្នាដែលអាចបណ្តាលឲ្យមានការប្តឹងទៅឋានានុក្រមថ្នាក់លើជាអ្នកកាត់សេចក្តីផងដែរ។

## កថាខណ្ឌទី ១ ទំនាក់ទំនងក្នុងដំណាក់កាលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាដីកាដែលធ្វើឡើងដោយព្រះរាជអាជ្ញា ហើយបញ្ជូនឲ្យចៅក្រមស៊ើបសួរដើម្បីធ្វើការស៊ើបសួរក្នុងការកំណត់ប្រភេទបទល្មើស ប្រឆាំងនិងបុគ្គលម្នាក់ ឬច្រើននាក់ ឬ ប្រឆាំងទៅនឹងអញ្ញាតជន។ ជាពិសេសក្នុងដីកានេះត្រូវចង្អុលបង្ហាញឲ្យច្បាស់លាស់អំពីអត្តសញ្ញាណរបស់ជនល្មើស។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានអំណាចបង្ខំចំពោះចៅក្រមស៊ើបសួរត្រូវតែធ្វើតាមដោយមិនអាចប្រកែកបានឡើយ[៥៩]។

ចៅក្រមស៊ើបសួរ មិនអាចស៊ើបសួរនូវអង្គហេតុដែលមិនបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ ទោះបីជាចៅក្រមស៊ើបសួរបានដឹងថាមានបទល្មើសផ្សេងក្រៅពីបទល្មើសដែលមានកំណត់ក្នុងដីកាក៏ដោយ ក៏ចៅក្រមស៊ើបសួរមិនអាចបើកការស៊ើបសួរដោយឯកឯង

[៥៩] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

បានឡើយ [៦០]។ មានតែដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះដែលមានសិទ្ធិប្ដឹងទៅអគ្គព្រះរាជអាជ្ញាឲ្យចេញអធិបញ្ញាទៅព្រះរាជអាជ្ញាដើម្បីចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

ប្រសិនបើអគ្គព្រះរាជអាជ្ញាយល់ឃើញថាអង្គហេតុនោះជាបទល្មើសព្រហ្មទណ្ឌ នោះគាត់ត្រូវចេញអធិបញ្ញាទៅព្រះរាជអាជ្ញាដើម្បីចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅដល់ចៅក្រមស៊ើបសួរដើម្បីបើកការស៊ើបសួរបន្ថែម ។

នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះមានការលេចឡើងនូវទំនាក់ទំនងធំៗ ២គឺ ទី១ (ការអនុវត្តតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ) និងទី២ (ការបើកការស៊ើបសួរនូវអង្គហេតុថ្មី)។

## ១. ការអនុវត្តតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានអំណាចបង្ខំចំពោះចៅក្រមស៊ើបសួរត្រូវតែធ្វើតាមដោយមិនអាចប្រកែកបានឡើយ។ ទោះបីជាចៅក្រមស៊ើបសួរ យល់ឃើញថាបទល្មើសនេះមិនគួរធ្វើការស៊ើបសួរក៏ដោយ។

ម្យ៉ាងវិញទៀតទោះបីជាចៅក្រមយល់ឃើញថាបទល្មើសដែលព្រះរាជអាជ្ញាបានបញ្ជូនមកមិនមែនជាបទល្មើសព្រហ្មទណ្ឌក៏ដោយក៏ចៅក្រមស៊ើបសួរនៅតែត្រូវធ្វើការស៊ើបសួរដដែល។ នៅក្នុងទំនាក់ទំនងនេះហើយដែលពេលខ្លះវាមិនត្រឹមតែធ្វើឲ្យខាតបង់ពេលវេលារបស់ចៅក្រមស៊ើបសួរ និងថវិការរបស់តុលាការទេតែពេលខ្លះអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ព្រោះនៅក្នុងនីតិវិធីចំណាត់ការរឿងក្ដីរំលោភសេពសន្ថវៈនេះតម្រូវឲ្យធ្វើការឃុំខ្លួនជនត្រូវចោទជាដើម។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវតែធ្វើការស៊ើបសួរដល់ទីបញ្ចប់ទើបអាចចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់បាន។

## ២. ការបើកការស៊ើបសួរនូវអង្គហេតុថ្មី

ចៅក្រមស៊ើបសួរ មិនអាចស៊ើបសួរនូវអង្គហេតុដែលមិនបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ ទោះបីជាចៅក្រមស៊ើបសួរបានដឹងថាមានបទល្មើសផ្សេងក្រៅពីបទល្មើសរំលោភសេពសន្ថវៈដែលមានកំណត់ក្នុងដីកាក៏ដោយ ចៅក្រមស៊ើបសួរមិនអាចបើកការស៊ើប

[៦០] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧

សួរដោយឯកឯងបានឡើយ។ ករណីលើកលែងមានតែស្ថានទម្ងន់ទោសប៉ុណ្ណោះដែលចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរដោយមិនចាំបាច់មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ក្នុងករណីផ្សេងទៀតប្រសិនបើចៅក្រមស៊ើបសួរចង់បើកការស៊ើបសួរទៅលើអង្គហេតុដែលខ្លួនបានដឹង ចៅក្រមត្រឹមតែអាចស្នើសុំឲ្យព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ តែប្រសិនបើព្រះរាជអាជ្ញានៅតែមិនយល់ព្រមចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទៀតនោះចៅក្រមស៊ើបសួរ ក៏គ្មានសិទ្ធិបង្ខំព្រះរាជអាជ្ញាចេញដីកាបានឡើយ។

នៅក្នុងចំណុចនេះអាចមានករណីនិទណ្ឌភាពកើតឡើងដោយសារនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា មិនអាចបញ្ជាក់បានថាគឺជាការចោទប្រកាន់ដ៏ត្រឹមត្រូវល្អឥតខ្ចោះនោះទេ ដែលពេលខ្លះព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ខុសនូវបទល្មើសដែលបានកើតឡើងជាក់ស្តែង ឬ ក៏ពេលខ្លះព្រះរាជអាជ្ញាអាចខ្វះចន្លោះនូវចំនុចណាមួយក្នុងការចោទប្រកាន់ដែរ។ នៅពេលដែលចៅក្រមស៊ើបសួរធ្វើការស៊ើបសួរទៅលើរឿងក្តីដែលបានបញ្ជូនពីព្រះរាជអាជ្ញាគាត់អាចនឹងរកឃើញនូវតម្រុយនៃបទល្មើសថ្មីបន្ថែម ឬ ជនល្មើសផ្សេងទៀតក្រៅពីអ្វីដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងអំពីបទល្មើសថ្មីដែលខ្លួនបានរកឃើញដល់ព្រះរាជអាជ្ញា ដើម្បីឲ្យព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីបន្ថែម។ តែផ្ទុយទៅវិញប្រសិនបើព្រះរាជអាជ្ញាមិនធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេនោះវាធ្វើឲ្យមាននិទណ្ឌភាពកើតឡើង។ ទំនាក់ទំនងមួយនេះអាចធ្វើឲ្យមានភាពអយុត្តិធម៌ចំពោះជនរងគ្រោះដែលត្រូវបានគេរំលោភសេពសន្ថវៈ និងថែមទាំងធ្វើឲ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម។ ការទុកឲ្យជនល្មើសមានសេរីភាពបែបនោះអាចបង្កឲ្យមានផលវិបាកនៅថ្ងៃក្រោយ ព្រោះថាជនល្មើសអាចនឹងប្រព្រឹត្តឲ្យមានបទល្មើសថ្មីថែមទៀតដោយសារតែភាពខ្វះចន្លោះនៃការអនុវត្តនីតិវិធី។

## កថាខណ្ឌទី ២ ទំនាក់ទំនងក្នុងដំណាក់កាលបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាដំណាក់កាលដែលចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាមានទំនាក់ទំនងគ្នាជាច្រើន។ នៅក្នុងករណីបទល្មើសរំលោភសេពសន្ថវៈ ការអនុវត្តតួនាទី និងភារកិច្ចរវាងព្រះរាជអាជ្ញានិងចៅក្រមស៊ើបសួរ ពិតជាមានផលវិបាកជាច្រើនដែលបានកើតឡើង។

ការបើកការស៊ើបសួរ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ព្រះរាជាអាជ្ញាមានសិទ្ធិពេញលេញក្នុងការសម្រេចធ្វើការចោទប្រកាន់ ឬ តម្កល់រឿងទុកឥតចាត់ការ។ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងដំណាក់កាលនេះចៅក្រមស៊ើបសួររងគំនាបខ្លាំង ជាពិសេសគឺទាក់ទងទៅនឹងការស៊ើបសួររបស់ខ្លួនទៅលើបទល្មើសរំលោភសេពសន្ថវៈនេះតែម្តង។ ប្រសិនបើមានការមិនពេញចិត្តនឹងការស៊ើបសួររបស់ចៅក្រមស៊ើបសួរទេនោះព្រះរាជអាជ្ញានឹងធ្វើការប្តឹងទៅសភាស៊ើបសួរដើម្បីធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរ។ ដូច្នេះចៅក្រមស៊ើបសួរក្នុងដំណាក់កាលនេះត្រូវបំពេញមុខងារដោយមានការប្រុងប្រយ័ត្ន និងធ្វើយ៉ាងណាឲ្យបានឆាប់រហ័ស និងមានភាពយុត្តិធម៌ ពីព្រោះបទល្មើសរំលោភសេពសន្ថវៈនេះវាងាយស្រួលក្នុងការបាត់បង់នូវភស្តុតាង ហើយការជំទាស់របស់ព្រះរាជអាជ្ញានេះហើយដែលអាចធ្វើឲ្យបញ្ហាកើតឡើង និងអាចធ្វើឲ្យមានភាពអយុត្តិធម៌ដល់ជនរងគ្រោះ ប្រសិនបើមិនបានធ្វើការទាន់ពេលវេលានោះ។

## ១. ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ

នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ព្រះរាជអាជ្ញាអាចស្នើសុំឲ្យចៅក្រមស៊ើបសួរឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន។ ប្រសិនបើចៅក្រមស៊ើបសួរមិនយល់ព្រមនឹងការស្នើសុំរបស់ព្រះរាជអាជ្ញានោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចអំពីការមិនឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទនោះនៅក្នុងរយៈពេល ៥ថ្ងៃ ដោយមិនចាំបាច់មានសំអាងហេតុឡើយ។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ថ្ងៃនោះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរឲ្យ សម្រេចជំនួសចៅក្រមស៊ើបសួរ។ នៅក្នុងករណីផ្សេងទៀតប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាធាតុផ្សំនៃបទល្មើសមិនមានលក្ខណៈគ្រប់គ្រាន់នោះទេ ចៅក្រមស៊ើបសួរអាចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំគ្រប់ពេលវេលា។ នៅក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដើម្បីយោបល់ និងបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាធ្វើការត្រួតពិនិត្យក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរធ្វើការសម្រេចក្នុងរយៈពេលយ៉ាងយូរ ៥ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប្រសិនបើមានករណីបន្ទាន់ចៅក្រមស៊ើបសួរអាចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំបានភ្លាមៗ ប៉ុន្តែត្រូវចង្អុលបង្ហាញប្រាប់ពីមូលហេតុនៃការបន្ទាន់នេះ។ ពេលខ្លះយើងឃើញថាភាពបន្ទាន់ ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនដោយមិនចាំបាច់មានការជូនដំណឹងទៅព្រះរាជអាជ្ញាទេ។ ទោះជាបីពេលខ្លះការបំពេញកិច្ចរវាងចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាមានភាព

ទាក់ទងគ្នាក៏ដោយក៏នៅមានមុខងារផ្សេងដាច់ដោយឡែកពីគ្នាផងដែរ ដូចជាការចាប់ខ្លួនដែលមានលក្ខណៈបន្ទាន់ផងដែរ ដែលចៅក្រមស៊ើបសួរអាចមានសិទ្ធិធ្វើការឃុំខ្លួនជនល្មើសដោយគ្មានការជូនដំណឹងទៅព្រះរាជអាជ្ញា ដោយគ្រាន់តែបង្ហាញនូវហេតុផលសមរម្យប៉ុណ្ណោះ។ ជនរងគ្រោះនៃបទល្មើសរំលោភសេពសន្ថវៈភាគច្រើនរងការគំរាមកំហែងដូចជា សម្លាប់ ឬ ធ្វើការសងសឹកដោយសារការប្តឹងរបស់ជនរងគ្រោះ ឬ និយាយអំពីសកម្មភាពពេលរំលោភប្រាប់តតិយជន ឬ ធ្វើការគំរាមថានឹងបង្ហោះវីឌីអូដែលខ្លួនបានថតក្នុងពេលរំលោភ។ ដូច្នេះការដោះលែងជនត្រូវចោទ ទោះបីក្នុងករណីបន្ទាន់ក៏ដោយចៅក្រមស៊ើបសួរត្រូវពិចារណាឲ្យបានល្អិតល្អន់ ឬ ជូនដំណឹងដល់ព្រះរាជាអាជ្ញាអំពីការបន្ទាន់នេះ ក្នុងការដោះលែងនេះដើម្បីបញ្ចៀសពីហានីភ័យណាមួយកើតឡើង។

## ១.១ ការដោះលែងជនត្រូវចោទនៅក្រៅឃុំដោយបណ្តឹងរបស់ព្រះរាជអាជ្ញា

ទោះបីជាបទល្មើសរំលោភសេពសន្ថវៈជាបទល្មើសដែលកម្រមានករណីដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំក៏ដោយ ប៉ុន្តែក៏អាចមានករណីខ្លះដែរ ដែលធ្វើឲ្យព្រះរាជអាជ្ញាសម្រេចធ្វើពាក្យបណ្តឹងដើម្បីឲ្យជនត្រូវចោទនៅក្រៅឃុំដែរ។ ព្រះរាជអាជ្ញា ក៏មានសិទ្ធិស្នើសុំឲ្យដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលាដែរ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃអំពីសំណើរនេះ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចដូចដែលបានកំណត់នោះទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរឲ្យធ្វើការសម្រេចជំនួស។ ប៉ុន្តែប្រសិនបើចៅក្រមស៊ើបសួរមិនព្រមដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំទេ គាត់ត្រូវតែមានសំអាងហេតុបង្ហាញនៅក្នុងដីកាសម្រេចនេះ។ ប្រសិនបើតាមនីតិវិធីយើងឃើញថា ព្រះរាជាអាជ្ញាដើរតួជាម្ចាស់បណ្តឹងអាជ្ញា ហើយមុននិងចៅក្រមស៊ើបសួរសម្រេចធ្វើការឃុំខ្លួនបុគ្គលណាមួយនោះ សុទ្ធតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាដើម្បីឲ្យធ្វើការស៊ើបសួរ ក្នុងករណីនេះព្រះរាជអាជ្ញាហាក់បីដូចជាត្រូវរងសម្ពាធពីព្រោះមិនមែនចេះតែធ្វើការចោទប្រកាន់ ហើយមកប្តឹងឲ្យដោះលែងនៅក្រៅឃុំស្រេចតែតាមចិត្តនោះទេ ដូច្នេះគាត់ត្រូវតែធ្វើការពិចារណាឲ្យបានច្បាស់លាស់ ពីព្រោះគាត់គឺជាទីពំនាក់តែមួយគត់របស់ជនរងគ្រោះដែលមិនអាចខ្វះបាន។ ប៉ុន្តែបើសិនគាត់មានការសម្រេចចិត្តមិនយកចិត្តទុកដាក់នោះអាចមានការបាត់បងទំនុកចិត្តដោយជនរងគ្រោះ។

## ១.២ ការដោះលែងជនត្រូវចោទនៅក្រៅឃុំដោយបណ្តឹងរបស់ជនត្រូវចោទ

ជនត្រូវចោទក៏មានសិទ្ធិដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំគ្រប់ពេលវេលា។ នៅពេលចៅក្រមស៊ើបសួរទទួលបានពាក្យបណ្តឹង គាត់ត្រូវបញ្ជូនពាក្យនោះទៅព្រះរាជអាជ្ញាភ្លាមដើម្បីសុំ

យោបល់ និងឲ្យព្រះរាជអាជ្ញាត្រួតពិនិត្យលើសំណុំរឿង។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលយ៉ាងខ្លីបំផុតដែលអាចធ្វើទៅបាន ហើយចៅក្រមស៊ើបសួរអាចសម្រេចយ៉ាងយូរបំផុតរយៈពេល ៥ថ្ងៃបន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

ប្រសិនបើចៅក្រមស៊ើបសួរ ធ្វើការបដិសេធទៅលើពាក្យសុំនោះ ជនត្រូវចោទអាចដាក់ពាក្យសុំសារជាថ្មីម្តងទៀត ឬ ស្នើសុំទៅសភាស៊ើបសួរក្នុងរយៈពេល ១ខែ បន្ទាប់ពីមានសេចក្តីបដិសេធពាក្យសុំលើកមុន សភាស៊ើបសួរ ឬ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ថ្ងៃក្រោយទទួលបានពាក្យសុំ។ ទោះបីជាយ៉ាងណាក៏ដោយការសុំដោះលែងដោយជនត្រូវចោទត្រូវតែតែត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្នបំផុត ពីព្រោះគ្មានជនល្មើសណាដែលប្រព្រឹត្តខុសហើយព្រមទទួលសារភាពថាខ្លួនបានប្រព្រឹត្តបទល្មើសនោះទេ។ ការសុំដោះលែងនេះ ត្រូវតែមានហេតុផលជាក់លាក់ពិតប្រាកដ។ ផ្ទុយទៅវិញក្នុងករណីនេះប្រសិនជនល្មើសពិតជាមានចេតនាសុច្ចរិត ហើយវាជារឿងដែលអយុត្តិធម៌មួយសម្រាប់ជនត្រូវចោទ ពីព្រោះទស្សនៈមនុស្សទូទៅបានគិតថា អ្នកដែលប្រព្រឹត្តខុសមិនដែលព្រមទទួលស្គាល់នូវកំហុសខ្លួននោះទេ។ ដូច្នេះដើម្បីកុំឲ្យមានវិមតិសង្ស័យទាំងចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាត្រូវតែធ្វើការសម្រេចមួយដែលមានមូលដ្ឋានជាក់លាក់។

## ២. ការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរមានអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថាបានចូលរួមប្រព្រឹត្តបទល្មើសទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ។

ចៅក្រមស៊ើបសួរ អាចដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការក្នុងឋានៈជាចារី សាហាចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត។

ចៅក្រមស៊ើបសួរ គឺជាអ្នកវាយតម្លៃពីកាលានុវត្តភាពនៃការជូនដំណឹង ពីការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ ដោយថាហេតុបន្ទាប់ពីការស៊ើបសួរចាំបាច់ផ្សេងៗរួចមក។ គាត់ត្រូវតែដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ ពេលខ្លះគិតថាពុំមានផលពិបាកខ្លាំងដែលកើតឡើងនោះទេ ដោយសារជនត្រូវចោទមានសិទ្ធិសេរីភាពនៅឡើយ។ ប៉ុន្តែសិទ្ធិដែលមាននោះពុំមានលក្ខណៈសេរីគ្រប់គ្រាន់នោះទេដោយសារតែសិទ្ធិដែលមាននោះត្រូវបានគេធ្វើការតាមដាន និងធ្វើការត្រួតពិនិត្យដូចនេះសិទ្ធិដែលមាននោះត្រូវរងនូវសម្ពាធក្នុងការធ្វើអ្វីមួយទោះបីជាដឹងថាគ្រាន់តែជាជនសង្ស័យ ឬ ពេលខ្លះដឹងថាខ្លួនមិនបានចូលរួមប្រព្រឹត្តបទល្មើសក៏ដោយនៅតែគិតថាដូចជាមិនមានសិទ្ធិពេញលេញ។ បទល្មើសរំលោភសេពសន្ថវៈឃើញឃើញថាសង្គមខ្មែរមានការស្អប់ខ្ពើមបុគ្គលដែលបានប្រព្រឹត្តបទល្មើសខ្លាំងណាស់ពីព្រោះថា គ្មាននណាដែលចង់ឲ្យកើតឡើងទៅលើក្រុមគ្រួសាររបស់ខ្លួននោះទេដោយសារបទល្មើសនេះ គឺវាប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសីលធម៌រស់នៅក្នុងសង្គម។ ដូច្នេះខណៈពេលដាក់ជនសង្ស័យឲ្យស្ថិតក្រោមការត្រួតពិនិត្យនេះ គាត់ពិតជារងនូវការតិះដៀលពីសំណាក់អ្នកជិតខាង។ ហើយម្យ៉ាងទៀតការត្រួតពិនិត្យតាមផ្លូវតុលាការដូចបានរៀបរាប់ខាងលើចៅក្រមស៊ើបសួរមានអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការនូវបុគ្គលគ្រប់រូបទោះបីជាគ្មានការចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ ចំនុចនេះហើយដែលធ្វើការទាមទារឲ្យកំណត់ឲ្យបានច្បាស់លាស់មុននឹងដាក់បុគ្គលណាម្នាក់ក្រោមការត្រួតពិនិត្យពីព្រោះពេលខ្លះវាអាចធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងសេរីភាពក្នុងការដើរហើរមួយចំនួនផងដែរ។

ហើយនៅក្នុងនីតិវិធីនេះចៅក្រមមិនចាំបាច់ស្នើសុំដល់ព្រះរាជអាជ្ញាទេ គាត់មានសេរីភាពពេញលេញក្នុងការដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ គ្រាន់តែជូនដំណឹងទៅព្រះរាជអាជ្ញាប៉ុណ្ណោះ។ ព្រះរាជអាជ្ញាមិនអាចធ្វើការបដិសេធដោយផ្ទាល់ចំពោះការដាក់ឲ្យជនត្រូវចោទស្ថិតក្រោមការពិនិត្យផ្ទាល់ទេ ប្រសិនបើចង់បដិសេធគឺត្រូវប្តឹងទៅសភាស៊ើបសួរ។

## **កថាខណ្ឌទី៣ ទំនាក់ទំនងក្នុងដំណាក់កាលបិទការស៊ើបសួរ**

ការបិទការស៊ើបសួរអាចធ្វើឡើងក្រោយពេលដែលចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរចប់ និងចេញដីកាសម្រេចថាធ្វើការបញ្ជូនទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ ប៉ុន្តែត្រូវតែធ្វើការជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការសម្រេចនេះផងដែរ។ ការបិទការស៊ើបសួរត្រូវធ្វើចំពោះគ្រប់បទល្មើសទាំងអស់ដែលបានបញ្ជូនមកចៅក្រមស៊ើបសួរ។ ប៉ុន្តែចំពោះបទល្មើសរំលោភសេពសន្ថវៈវិញ ពិតជាមានភាពលំបាកក្នុងការអនុវត្ត ជាក់ស្តែងដោយសារតែវាជាបទល្មើសឧក្រិដ្ឋ ហើយមាន

លក្ខណៈស្មុគស្មាញខ្លាំង និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរទាំងកិត្តិយសរបស់ជនរងគ្រោះ និងសណ្តាប់ធ្នាប់សាធារណៈ ដូចនេះចាំបាច់ត្រូវតែតាមដាន និងធ្វើការស៊ើបអង្កេតឲ្យបានល្អិតល្អន់ជាដាច់ខាត។

## ១. ដីកាលើកលែងការចោទប្រកាន់

ដីកាលើកលែងការចោទប្រកាន់ គឺជាការសម្រេចមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា និងមិនបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ក្នុងករណីអំពើនោះមិនមែនជាបទល្មើសឧក្រិដ្ឋ មជ្ឈិម លហុ ឬ មិនស្គាល់មុខអ្នកប្រព្រឹត្ត ឬ គ្មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនត្រូវចោទ។ ដីកានេះនឹងយកជាការបានលុះត្រាតែ ចិរវេលានៃការប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាត្រូវបានបញ្ចប់ ឬ ព្រះរាជអាជ្ញាយល់ព្រមឲ្យដោះលែងភ្លាមៗ។ ដូច្នេះមានន័យថាដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរមិនមែនជាដីកាបិទផ្លូវតវ៉ានោះទេ។ ព្រះរាជអាជ្ញាក៏ដូចជាជនរងគ្រោះអាចប្តឹងឧទ្ធរណ៍ចំពោះដីកានេះបានប្រសិនបើពួកគេមិនយល់ព្រមទៅនិងដីកាសម្រេចនេះ។

### ១.១ ការបើកការស៊ើបសួរលើភស្តុតាងថ្មី

ក្រោយពេលដែលចេញដីកាលើកលែងចោទប្រកាន់របស់ចៅក្រមស៊ើបសួរ និងដីកាលើកលែងចោទប្រកាន់របស់សភាស៊ើបសួរបានចូលជាស្ថាពរ ប្រសិនបើមានលេចឡើងនូវបន្ទុកថ្មី ការស៊ើបសួរអាចបើកឡើងវិញ តាមការផ្តើមគំនិតរបស់ព្រះរាជអាជ្ញា[៦៦]។ ព្រះរាជអាជ្ញាអាចដាក់ពាក្យសុំធ្វើកិច្ចស៊ើបសួរ។ បើព្រះរាជអាជ្ញាយល់ឃើញថាមានកត្តាចាំបាច់ត្រូវធ្វើការស៊ើបសួរជាថ្មីទៀត ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ក្នុងករណីនេះ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមទេ ចៅក្រមអាចបដិសេធក្នុងរយៈពេល ១៥ថ្ងៃ ដោយមានដីកាសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាយ៉ាងឆាប់បំផុត។ ក្នុងករណីដែលចៅក្រមមិនបានសម្រេចក្នុងរយៈពេលដែលបានកំណត់ខាងលើទេ ព្រះរាជអាជ្ញាអាចប្តឹងផ្ទាល់តាមរយៈពាក្យសុំ ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចអាចធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរបាន។

ការបើកការស៊ើបសួរលើភស្តុតាងថ្មីនេះ បានដោយសារតែដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរមិនរំលត់បណ្តឹងអាជ្ញាទេ ព្រោះប្រសិនបើការលើកលែងការចោទប្រកាន់មានហេតុផលដែលបណ្តាលមកពី មិនមានភស្តុតាងគ្រប់គ្រាន់ដែលត្រូវប្រឆាំងនឹងជនត្រូវចោទ ឬ មកពី

[៦៦] មាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ការពុំស្គាល់ចារី ឬ មានបន្ទុកថ្មីគ្រប់គ្រាន់នោះត្រូវបានអនុញ្ញាតឲ្យបើកការស៊ើបសួរសារជាថ្មីម្តងទៀតនៅលើអង្គហេតុដដែល។

## ១.២ ការប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរពីដីកាលើកលែងការចោទប្រកាន់។ ការប្តឹងនេះជាការប្តឹងទៅសភាស៊ើបសួរអំពីការមិនយល់ព្រមទៅនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ហើយបើសិនមានការប្តឹងទាស់បែបនេះ ជនត្រូវចោទដែលនៅជាប់ឃុំត្រូវរក្សាទុកក្នុងពន្ធនាគារបន្តរហូតដល់ពេលសភាស៊ើបសួរសម្រេចអំពីបណ្តឹងនេះ។ បើសភាស៊ើបសួរយល់ព្រមទៅនឹងដីកានេះ ជនត្រូវចោទនឹងដោះលែងឲ្យមានសេរីភាព។ ផ្ទុយទៅវិញប្រសិនបើ សភាស៊ើបសួរចេញដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ នោះគាត់ត្រូវសម្រេចអំពីការរក្សាទុកក្នុងឃុំបន្តទៀត។ ក្រៅពីព្រះរាជអាជ្ញាដើមបណ្តឹងរដ្ឋប្បវេណី ក៏មានសិទ្ធិប្តឹងទៅឧទ្ធរណ៍អំពីដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបានដែរ ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីមិនសុខចិត្តទៅនិងដីកាសម្រេចលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរនេះ។ នៅពេលសភាស៊ើបសួរទទួលបណ្តឹងអំពីការប្តឹងទាស់ដីការបស់ចៅក្រមស៊ើបសួរនេះ សភាស៊ើបសួរធ្វើការត្រួតពិនិត្យ និងថ្លឹងថ្លែង។ ប្រសិនបើសភាស៊ើបសួរយល់ព្រមតាមបណ្តឹងទាស់នោះ សភាស៊ើបសួរអាចធ្វើអធិបញ្ញាឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរបន្ត ឬ ក៏សភាស៊ើបសួរអាចធ្វើការស៊ើសួរដោយផ្ទាល់ក៏បាន។

## ១.៣ ករណីមិនមែនជាបទល្មើសព្រហ្មទណ្ឌ

នៅពេលចៅក្រមស៊ើបសួរ បានធ្វើការស៊ើបសួរអំពីបទល្មើសព្រហ្មទណ្ឌណាមួយតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ប៉ុន្តែក្រោយមកស្រាប់តែគាត់បែជារកឃើញនូវភស្តុតាងមួយចំនួន ដែលបញ្ជាក់ថាអំពើរបស់ជនត្រូវចោទដែលបានប្រព្រឹត្តមិនមែនជាបទល្មើសព្រហ្មទណ្ឌទៅវិញនោះ ចៅក្រមស៊ើបសួរនិងចេញដីការដំណោះស្រាយមួយលើកលែងការចោទប្រកាន់ដើម្បីដោះលែងជនត្រូវចោទនោះឲ្យមានសេរីភាពវិញ។ ប៉ុន្តែមាននីតិវិធីក្នុងរឿងក្តីមួយចំនួនដូចជាបទល្មើសរំលោភសេពសន្ថវៈ គឺតម្រូវឲ្យចៅក្រមស៊ើបសួរចាប់ជនត្រូវចោទឃុំខ្លួនបណ្តោះអាសន្ន ឬ ធ្វើការពិនិត្យតាមផ្លូវតុលាការជាដើម។ ហើយការឃុំខ្លួនបណ្តោះអាសន្ននេះអាចមានការពន្យាពេលបានដល់ទៅពីរដងឯណោះ។ ករណីជនត្រូវចោទនោះមិនបានប្រព្រឹត្តអំពើល្មើសមែននោះគាត់នឹងត្រូវទទួលការចោទប្រកាន់យ៉ាងអយុត្តិធម៌ និងធ្វើឲ្យបាត់បង់កិត្តិយស។ លើសពីនេះទៅទៀតប្រសិនបើគាត់ជាមេគ្រួសារ ឬ ជាអ្នករកប្រាក់ចំណូលសម្រាប់គ្រួសារ ប្រសិនបើគាត់ត្រូវ

បានគេឃុំខ្លួនរហូតទៅច្រើនខែនោះ តើនរណាដែលជាអ្នកទទួលខុសត្រូវចំពោះគ្រួសាររបស់គាត់? ជាពិសេសជាងនេះទៅទៀតគឺអាចធ្វើឲ្យបុគ្គលនោះប៉ះពាល់ដល់អារម្មណ៍ផ្លូវចិត្ត និងអាចឈានដល់ការបាត់បង់ទំនុកចិត្តទៅលើការអនុវត្តច្បាប់ទៀតផង។

## ២. ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ

ដូចដែលបានរៀបរាប់ខាងលើនេះ ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាមានបន្ទុកគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ជនត្រូវចោទដែលបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ចៅក្រមស៊ើបសួរអាចបញ្ជូនរឿងក្តីនេះទៅជំនុំជម្រះបាន។

ព្រះរាជអាជ្ញា ក៏អាចប្តឹងសុំទៅចៅក្រមស៊ើបសួរឲ្យបញ្ជូនជនត្រូវចោទទៅជំនុំជម្រះបានដែរ ក្នុងករណីដែលព្រះរាជអាជ្ញាយល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់ ព្រះរាជអាជ្ញាត្រូវចេញដីកាស្ពាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប៉ុន្តែចៅក្រមអាចយល់ស្រប ឬ មិនយល់ស្របតាមបណ្តឹងរបស់ព្រះរាជអាជ្ញាបាន ព្រោះចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចក្នុងការគោរពតាមដីកាស្ពាពររបស់ព្រះរាជអាជ្ញាទេ នោះប្រសិនបើគាត់យល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់មែន នោះគាត់អាចធ្វើតាមបណ្តឹងរបស់ព្រះរាជអាជ្ញាដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ តែផ្ទុយមកវិញប្រសិនបើគាត់យល់ឃើញថាមិនទាន់មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទេ ចៅក្រមស៊ើបសួរអាចបដិសេធនូវដីកាស្ពាពររបស់ព្រះរាជអាជ្ញាបាន។

ក្នុងករណីនេះ ព្រះរាជអាជ្ញាក៏មិនត្រូវបានបិទសិទ្ធិដើម្បីតវ៉ាអំពីការសម្រេចរបស់ចៅក្រមស៊ើបសួរដែរ។ ប្រសិនបើចៅក្រមស៊ើបសួរបានសម្រេចផ្ទុយទៅនឹងដីកាស្ពាពររបស់ខ្លួន ព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ចំពោះការសម្រេចរបស់ចៅក្រមស៊ើបសួរបាន។

នៅក្នុងករណីនេះការកំណត់អំពីការចេញដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើប និងព្រះរាជអាជ្ញាឃើញថាពិតជាអាចនាំឲ្យលេញចេញនូវផលវិបាកដល់ដំណើរការនៃនីតិវិធីដូចជាការមិនយល់ព្រមទៅនិងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរដោយព្រះរាជអាជ្ញា និងការបញ្ជូនជនល្មើសទៅជំនុំជំម្រះដោយចៅក្រមស៊ើបសួរទោះបីគ្មានការយល់ព្រមរបស់ព្រះរាជអាជ្ញាក៏ដោយ។

# លទ្ធផលនៃការស្រាវជ្រាវ

យោងតាមការស្រាវជ្រាវទៅលើប្រធានបទ ផលវិបាកនៃការអនុវត្តតួនាទី និងអំណាចរវាងព្រះរាជអាជ្ញាក្នុងទំនាក់ទំនងចៅក្រមស៊ើបសួរ (ករណីបទល្មើសសេពសន្ថវៈ) នេះយើងខ្ញុំទទួលបាននូវលទ្ធផលមួយចំនួនដូចខាងក្រោម:

- របាយការណ៍របស់អង្គការ លីកាដូ បទល្មើសរំលោភសេពសន្ថវៈកើតឡើងចាប់ពីដើមឆ្នាំ២០១២ ដល់ចុងឆ្នាំ ២០១៤ មានបទល្មើសរំលោភសេពសន្ថវៈ និងបទប៉ុនប៉ងរំលោភសេពសន្ថវៈកើតឡើងចំនួន ៧៩៣នាក់។ ដែលក្នុងនោះជនរងគ្រោះអាយុក្រោម ៦ឆ្នាំមាន ៥៨នាក់ ត្រូវនិង ៧% ហើយជនរងគ្រោះអាយុពី ៦ឆ្នាំ ដល់ ១១ឆ្នាំ មានចំនួន ១១៨នាក់ ស្មើនិង ២៣% ជនរងគ្រោះអាយុពី ១២ឆ្នាំ ដល់ ១៧ឆ្នាំ មានចំនួន ៣២៨នាក់ ស្មើនិង ៤១% និងជនរងគ្រោះមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅមានចំនួន ២២៦នាក់ ស្មើនិង ២៩%។ ចំពោះការចាត់ការរបស់តុលាការមានការផ្តន្ទាទោសមិនត្រឹមត្រូវ ឬគ្មានការផ្តន្ទាទោសមាន ៣៣% ករណីត្រូវបានបិទមុនពេលជំនុំជម្រះក្តីមាន ៣២% ករណីផ្តន្ទាទោសសមសមស្រប ៣៥%[៦២]។

បើតាមលទ្ធផលខាងលើកិច្ចការងាររបស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាទៅលើបទល្មើសរំលោភសេពសន្ថវៈយើងឃើញថាគាត់មានចំនុចខ្លាំង និងចំនុចខ្សោយមួយចំនួន:

- ***ចំនុចខ្លាំង***

  ចំពោះតុលាការដោយសារមានការរិះគន់ និងបាត់ទំនុកចិត្តពីប្រជាពលរដ្ឋកន្លងមកដោយសារមានអំពើពុករលួយដោយការជ្រៀតជ្រែកពីសំណាក់អ្នកមានអំណាច ឬការធ្វើការធ្វេសប្រហែសរបស់បុគ្គលិកតុលាការ។ នាពេលបច្ចុប្បន្ននេះទើបមានការកែទម្រង់ប្រព័ន្ធតុលាការ ឲ្យកាន់តែមានឯករាជ្យភាព ដោយមានការបង្កើតនូវច្បាប់ដើម្បីកុំឲ្យមានគំនាបពីអង្គនីតិប្រតិបត្តិ។ ម្យ៉ាងទៀតដោយសារតែមានការយកចិត្តទុកដាក់ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលតាមរយៈការលើកទឹកចិត្តដល់ចៅក្រម

[៦២] របាយការណ៍សង្ខេបអំពីការរួចខ្លួនពីបទល្មើសៈ ការអនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈ ក្នុងប្រព័ន្ធតុលាការកម្ពុជា ចេញផ្សាយ ខែមិនា ឆ្នាំ2016

ព្រះរាជអាជ្ញា និងអ្នកបំពេញមុខងារផ្សេងទៀតនៅក្នុងតុលាការ ដោយបន្ថែមនូវប្រាក់បៀវត្សន៍ដើម្បីកាត់បន្ថយអំពើពុករលួយបន្តិចម្តងៗ។ ក្រៅពីនេះចៅក្រមក៏ដូចជាព្រះរាជអាជ្ញាព្យាយាមអនុវត្តន៍ទៅតាមក្រមសីលធម៌ដែលមានចែងស្រាប់នោះឲ្យកាន់តែមានប្រសិទ្ធភាព។ ជាពិសេសអ្វីដែលយើងសងតឃើញនោះគឺការសហការគ្នារវាងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ ចំណុចនេះពិតជាមានលក្ខណៈល្អប្រសើរ ដើម្បីកុំឲ្យភាគីណាមួយចេះតែធ្វើអ្វីតាមតែទំនើងចិត្តខ្លួនក៏ដូចជាការបង្ហាញពីគោលការណ៍យ៉ាងមុតមាំក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងជៀសវាងពីការចោទប្រកាន់ដោយភាពអយុត្តិធម៌ណាមួយ។ មួយវិញទៀត គ្មានបុគ្គលណាមួយដែលធ្វើអ្វីដោយល្អឥតខ្ចោះនោះទេតែងតែមានកំហុសកើតឡើងដោយអចេតនា ដូច្នេះការសហការគ្នានេះហើយដែលអាចជួយបំពេញភាពខ្វះចន្លោះនៃច្បាប់ ឬភាពមិនប្រក្រតីណាមួយបានបានយ៉ាងមានប្រសិទ្ធភាព ក៏ដូចជាបង្ហាញសញ្ញាណគ្រោះថ្នាក់ដល់ជនល្មើសថាមិនអាចជៀសផុតពីសំណាញ់នៃច្បាប់បាន។

❖ ***ចំនុចខ្សោយ***

នៅពេលបច្ចុប្បន្នប្រព័ន្ធតុលាការនៅកម្ពុជាត្រូវបានគេធ្វើការកត់សម្គាល់ថាបាត់បង់ទំនុកចិត្តពីប្រជាពលរដ្ឋយ៉ាងខ្លាំងដោយសារការចោទប្រកាន់ខុសបុគ្គល ឬនិទណ្ឌភាពជាដើម។ នៅក្នុងរដ្ឋធម្មនុញ្ញមាត្រា ៥១ បានបែងចែងថាអំណាចត្រូវបានបែងចែងដាច់ដោយឡែកពីគ្នារវាង ស្ថាប័ននីតិបញ្ញាតិ ស្ថាប័ននីតិប្រតិបត្តិ និងអំណាចតុលាការ។ ផ្ទុយទៅវិញត្រូវបានគេធ្វើការរិះគន់ថា អំណាចទាំងបីមិនបានកាត់ផ្តាច់ពីគ្នានោះឡើយ ជាពិសេសអ្នកមានអំណាចនៅតែមានសិទ្ធិបង្គាប់បញ្ជាទៅលើស្ថាប័ន តុលាការ និងរួមទាំងអំពើពុករលួយមួយចំនួនដែលកើតមាននៅក្នុងប្រព័ន្ធតុលាករបស់ខ្លួនឯងផងដែរ។ ប្រសិនបើនិយាយអំពីដំណើរការនៃនីតិវិធីវិញ ដូចដែលយើងដឹងស្រាប់មកហើយថា ប្រព័ន្ធតុលាការនៅកម្ពុជាមិនទាន់បានធ្វើការបែងចែកគ្នាដាច់ស្រឡះឡើយទេ ដោយទាំងរឿងព្រហ្មទណ្ឌ និងរឿងរដ្ឋប្បវេណីគឺដោះស្រាយនៅក្នុងស្ថាប័នតុលាការរួមគ្នា ចំណុចអាចធ្វើឲ្យមិនមានសមត្ថភាពពិតប្រាកដទៅលើរឿងក្តីណាពិតប្រាកដឡើង។ ម្យ៉ាងទៀតចំពោះអំពើពុករលួយវិញគឺនៅតែមាននៅឡើយ មិនទាន់អាចលុបបំបាត់បាននៅឡើយទេ។

# សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលដែលយើងខ្ញុំបានធ្វើការស្រាវជ្រាវលើប្រធានបទបទល្មើសរំលោភសេពសន្ថវៈក្នុងទំនាក់ទំនងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរនេះ បង្ហាញឲ្យឃើញថាបទល្មើសរំលោភសេពសន្ថវៈជាបទល្មើសដែលកើតឡើងច្រើន និងពិបាកក្នុងការចាត់ការរឿងក្តីបទល្មើសនេះមានលក្ខណៈស្មុគស្មាញ និងអាចមានការភ័ន្តច្រឡំខ្លាំងទៀតផង ដូចនេះប្រសិនបើចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាមានការធ្វេសប្រហែលតែបន្តិច វាអាចធ្វើឲ្យមានភាពអយុត្តិធម៌កើតឡើង។ ប៉ុន្តែយ៉ាងណាមិញតាមការសិក្សាលើការអនុវត្តនីតិវិធីរវាងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរទៅលើបទល្មើសនេះ មានការលេចឡើងជាផលវិបាកជាច្រើន ដែលផលវិបាកនេះអាចជាគុណសម្បត្តិ ហើយក៏អាចជាគុណវិបត្តិផងដែរ។

**ចំពោះគុណសម្បត្តិរបស់វា** គឺកាន់តែមានភាពយុត្តិធម៌។ ទោះបីជាពេលខ្លះមានភាពមិនស្រុះស្រួលគ្នារវាងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរក្នុងការអនុវត្តនីតិវិធីណាមួយក៏ដោយ ក៏ប៉ុន្តែ ទាំងនេះសុទ្ធតែធ្វើឡើងដើម្បីការពារផលប្រយោជន៍ ជនរងគ្រោះ និងជនល្មើសមិនឲ្យមានភាព ស្រពិចស្រពិលទៅលើករណីណាមួយឡើយ ជៀសវាងមានការដាក់ទណ្ឌកម្មច្រឡំ ឬ ឲ្យជនល្មើសមានសេរីភាព ពោលគឺធ្វើយ៉ាងណាមិន ឲ្យមានភាពអយុត្តិធម៌កើតមានក្នុងប្រព័ន្ធតុលាការបានឡើយ។ ម្យ៉ាងទៀតដូចពាក្យចាស់ពោលថា "គំនិតពីរប្រសើរជាងគំនិតមួយ" ដូច្នេះសំណួរលើកឡើងថា ហេតុអ្វីបានជាក្នុងប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជាបង្កើតឲ្យមានទាំងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ? ការឆ្លើយតបទៅវិញគឺ មកពីប្រទេសកម្ពុជាបានទទួលឥទ្ធិពលពីបារាំង ហើយម្យ៉ាងទៀតដោយសារមានការយល់ឃើញថា ការបង្កើតឲ្យមានទាំងចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាដូចនេះគឺឲ្យពួកគេជួយគ្នាក្នុងការដោះស្រាយរឿងក្តីឲ្យមានភាពឆាប់រហ័ស និងមានភាពយុត្តិធម៌។ មតិផ្សេងទៀតបាននិយាយថា ដោយសារប្រទេសកម្ពុជា ជាប្រទេសក្មេងខ្ចីខាងប្រព័ន្ធយុត្តាធិការ ហើយមិនទាន់មានភាពរឹងមាំដូចប្រទេសអភិវឌ្ឍមួយចំនួន ដូច្នេះដើម្បីការពារអំពើពុករលួយមិនឲ្យកើតមានឡើងទើបបង្កើតឲ្យមានទាំងចៅក្រមស៊ើបសួរ និងទាំងព្រះរាជអាជ្ញាដូចនេះ។ យ៉ាងណាមិញទោះបីជាវាមានគុណសម្បត្តិច្រើនក៏ដោយ ក៏ប៉ុន្តែវាក៏អាចមានគុណវិបត្តិផងដែរនៅក្នុងករណីបទល្មើសរំលោភសេពសន្ថវៈនេះ។

**ចំពោះគុណវិបត្តិ** គឺវាអាចអូសបន្លាយពេលវេលានៃនីតិវិធីមិនអាចធ្វើការអនុវត្តបាន ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ទាំងតុលាការជនល្មើស និងជនរងគ្រោះ។ ដូចដែលយើងបានដឹងស្រាប់

ហើយថា ចំពោះជនរងគ្រោះមិនថាក្នុងករណីបទល្មើសរំលោភសេពសន្ថវៈ ឬ បទល្មើសអ្វីក៏ដោយ សុទ្ធតែចង់ឲ្យតុលាការរកយុត្តិធម៌ឲ្យខ្លួន និងចាប់ជនល្មើសមកផ្តន្ទាទោសតាមច្បាប់ឲ្យបានឆាប់រហ័ស ប៉ុន្តែប្រសិនមានការអូសបន្លាយនីតិវិធីបែបនេះ គឺអាចធ្វើឲ្យមានផលប៉ះពាល់ទឹកចិត្តរបស់ជនរងគ្រោះដោយអំពើល្មើសច្បាប់ខ្លាំងណាស់ ដែលអាចមានការរិះគន់ចំពោះតុលាការផងដែរ។ លើសពីនេះទៅទៀតចំពោះការអូសបន្លាយពេលវេលានេះដែរ គឺវាធ្វើឲ្យខាតពេលវេលាព្រោះវាចំណាយពេលច្រើនក្នុងការចាត់ការរឿងក្តីមួយ។ មិនថាក្នុងប្រទេសជឿនលឿនយ៉ាងណាក៏ដោយក៏មិនអាចជៀសផុតពីបទល្មើសរំលោភសេពសន្ថវៈបានទេ ដោយឡែកចំពោះប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ផងនោះ បទល្មើសនេះកើតឡើងជាច្រើនករណីក្នុងមួយថ្ងៃៗ ហេតុដូចនេះហើយ ប្រសិនបើចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាមិនចាត់ការរឿងក្តីមួយឲ្យបានឆាប់រហ័សទេនោះ គឺមិនអាចចាត់ការរឿងក្តីផ្សេងទៀតឲ្យទាន់ពេលវេលាបានឡើយ។ ម្យ៉ាងទៀតខាងហិរញ្ញវត្ថុក៏ជាបញ្ហារបស់តុលាការកម្ពុជាដែរ ដូចដែលបានបញ្ជាក់ខាងលើហើយប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ដូចនេះនៅមានការខ្វះខាតខាងថវិការច្រើន នោះប្រសិនបើមានការអូសបន្លាយពេលវេលាយូរ ដោយសារការប្តឹងផ្តល់ទៅដល់ថ្នាក់លើនៃឋានានុក្រមណាមួយនោះ គឺត្រូវមានការចំណាយថវិការជាច្រើន។ គុណវិបត្តិមួយទៀងគឺវិវាទនៃនីតិវិធី ចំពោះបទល្មើសរំលោភសេពសន្ថវៈនេះគឺដោយសារការមិនព្រមព្រៀងគ្នារបស់ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាក្នុងការអនុវត្តនីតិវិធីណាមួយ។ កាលណាចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាមិនមានភាពចុះសម្រុងគ្នាក្នុងការអនុវត្តនីតិវិធីក្នុងចំណាត់ការរឿងក្តីជាញឹកញាប់ នោះនឹងមានការវាយតម្លៃពីមជ្ឈដ្ឋានខាងក្រៅថាតុលាការរបស់ប្រទេសកម្ពុជា មិនបានរៀបចំនូវសណ្តាប់ធ្នាប់ឲ្យបានល្អ និងមានការសម្រេចដោយមិនយកចិត្តទុកដាក់ទើបធ្វើឲ្យមានវិវាទកើតឡើងដូច្នេះ។

ដូចនេះបញ្ជាក់ឲ្យឃើញថា គុណវិបត្តិនៃផលវិបាកនៃការអនុវត្តតួនាទី និងអំណាច រវាងព្រះរាជអាជ្ញាក្នុងទំនាក់ទំនងចៅក្រមស៊ើបសួរ (ករីណីបទល្មើសរំលោភសេពសន្ថវៈ) មានច្រើនជាងគុណសម្បត្តិ ដោយយើងឃើញថាទោះបីជាមាននីតិវិធីមួយចំនួនធ្វើឡើងដោយមានភាពរលូនក៏ដោយ ក៏នៅតែមានវិវាទបានកើតឡើងជាច្រើនក្នុងការអនុវត្ត តួនាទីរបស់អ្នកទាំងពីរ។

# អនុសាសន៍

ក្រោយពីបានសិក្សាអំពី ប្រធានបទស្តីពី បទល្មើសរំលោភសេពសន្ថវៈក្នុងទំនាក់ទំនងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ យើងឃើញថា ករណីបទរំលោភនេះពិតជាមានផលវិបាកច្រើនកើតឡើងក្នុងខណៈពេលនៃការអនុវត្តតួនាទីដែលបណ្តាលឲ្យមានការយឺតយ៉ាវ ដល់នីតិវិធីក្នុងការដាក់ទោសទណ្ឌជនល្មើស ហើយម្យ៉ាងទៀតបទល្មើសរំលោភសេពសន្ថវៈនេះជាបទល្មើសមួយដែលមានផលប៉ះពាល់ខ្លាំងណាស់ចំពោះជនរងគ្រោះ និងសង្គមទាំងមូល ដូច្នេះហើយយើងខ្ញុំទាំងពីរសូមផ្តល់អនុសាសន៍ខ្លះៗដើម្បីជួយកាត់បន្ថយទាំងផលវិបាករបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងបទល្មើសរំលោភសេពសន្ថវៈ

## ១. ចំពោះតុលាការ

- ចៅក្រម និងព្រះរាជអាជ្ញា ត្រូវធ្វើការពិចារណាឲ្យច្បាស់លាស់មុននឹងសម្រេចថាធ្វើនីតិវិធីណាមួយជៀសវាងការ មិនចុះសម្រុងគ្នា ដែលអាចធ្វើឲ្យខាតប្រយោជន៍ ជនរងគ្រោះ ឬ ជនល្មើស
- ចៅក្រម និងព្រះរាជអាជ្ញាត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចាត់ការរឿងក្តី។
- បង្កើតឲ្យមានតុលាការពីរគឺ ព្រហ្មទណ្ឌ និង រដ្ឋប្បវេណី ដើម្បីចែកសមត្ថកិច្ចដាច់ពីគ្នា ហើយចៅក្រមធ្វើការឲ្យមានជំនាញច្បាស់លាស់
- តុលាការត្រូវតែមានឯករាជ្យភាពពេញលេញ

## ២. រាជរដ្ឋាភិបាល

- គ្រឿងញៀនៈ រាជរដ្ឋាភិបាលត្រូវធ្វើយ៉ាងណាលុបបំបាត់ឲ្យបាន នូវការនាំចូល ផលិត និងចែកចាយគ្រឿងញៀនឲ្យមានប្រសិទ្ធភាព
- គ្រឿងស្រវឹងៈ មិនត្រូវអនុញ្ញាតឲ្យអនីតិជនក្រោមអាយុ ១៨ឆ្នាំសេពគ្រឿងស្រវឹង។ ម្យ៉ាងទៀត មិនត្រូវអនុញ្ញាតឲ្យទស្សនាវត្តី ទូរទស្សន៍ ធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម និងមានការចាប់រង្វាន់ជាដើម។ ជាពិសេសការលើកផ្លាកសញ្ញានៅលើដងផ្លូវដែលផ្សព្វផ្សាយពីគ្រឿងស្រវឹងឡើយ។
- វីដេអូ និងរូបភាពអាសអាភាសៈ ទប់ស្កាត់ការកុំឲ្យក្មេងក្រោមអាយុ ១៨ មើលរឿងអាសអាភាស និងគ្រប់តូបលក់ CD ទាំងអស់មិនត្រូវអនុញ្ញាតឲ្យមានលក់រឿង

អាសអាភាសទេ។ ក្រៅពីនេះទៅទៀត ត្រូវបញ្ឈប់នូវទស្សនាវដ្តីណាដែលបង្ហាញពីរូបអាសអាភាស និងសិចស៊ីជ្រុលហួសហេតុ។ មិនត្រូវអនុញ្ញាតឲ្យបញ្ចាំងនូវរឿងដែលមានឈុតឆាកអាសអាភាស។ ជាពិសេសតារាខ្មែរមិនគួរយកតម្រាប់តាមតារាបរទេសដែលស្លៀកពាក់សិចស៊ីខ្លាំងនោះទេ។

- អំពើពុករលួយៈ រាជរដ្ឋាភិបាលត្រូវតែលុបបំបាត់ឲ្យបាននូវអំពើពុករលួយ ទាំងនៅក្នុងស្ថាប័នតុលាការ និងមន្ត្រីនគរបាលយុត្តិធម៌ ជាមួយជនល្មើសដែលអាចធ្វើឲ្យមាននិទណ្ឌភាព។
- មានការផ្សព្វផ្សាយឲ្យប្រជាជនបានដឹង និងយល់អំពីផលវិបាកដែលបណ្តាលមកពីការកកើតនូវបទល្មើសរំលោភសេពសន្ថវៈ និងធ្វើការផ្សព្វផ្សាយឲ្យបានទូលំលាយអំពីទណ្ឌកម្មធ្ងន់ធ្ងរចំពោះជនណាដែលប្រព្រឹត្តអំពើនេះ។
- ជួយលើកទឹកចិត្តជនរងគ្រោះដោយមធ្យោបាយផ្សេងៗ និងបំបាត់នូវការរើសអើងចំពោះជនរងគ្រោះពីសំណាក់ជនដទៃ។

### ៣. ប្រជាជន

- ត្រូវតែចេះសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅពេលមានបទល្មើសកើតឡើង
- ជួយផ្តល់កម្លាំងចិត្ត និងពន្យល់ដល់ជនរងគ្រោះ កុំឲ្យបាក់ទឹកចិត្ត
- មិនត្រូវរើសអើងជនរងគ្រោះ និងត្រូវចេះរក្សាការសំងាត់ជនរងគ្រោះដោយមិនយកទៅនិយាយប្រាប់ក្រៅពីអាជ្ញាធរមានសមត្ថកិច្ច។

### ៤. ជនរងគ្រោះ និងគ្រួសារ

- ត្រូវទៅប្តឹងអាជ្ញាធរមានសមត្ថកិច្ច អំពីអំពើដែលបានប្រព្រឹត្តមកលើខ្លួនឲ្យបានឆាប់រហ័ស ដើម្បីឲ្យអាជ្ញាធរមានសមត្ថកិច្ចងាយស្រួលក្នុងការស្វែងរកភស្តុតាង និងចាប់ជនល្មើស
- ត្រូវហ៊ានបកអាក្រាតពីជនល្មើស ដោយនិយាយប្រាប់មន្ត្រីមានសមត្ថកិច្ចតាមត្រង់ពីអំពើដែលជនល្មើសបានប្រព្រឹត្តមកលើខ្លួន ដោយគ្មានការលាក់កំបាំងឡើយ
- ត្រូវហ៊ានប្រឈមមុខនឹងការពិត និងចូលរួមយ៉ាងសកម្មក្នុងការផ្តល់ពិតមាន
- អាណាព្យាបាល ក្រុមគ្រួសារ មិនត្រូវធ្វើការបិទបាំង ឬ មិនធ្វើសេចក្តីរាយការណ៍ជូនសមត្ថកិច្ចអំពីករណីរំលោភទោះដោយមានមូលហេតុណាក៏ដោយ

- ជ្រៀសវាងការបង្ខំជនរងគ្រោះឲ្យរៀបការជាមួយជនល្មើស ឬទទួលយកលុយជាថ្នូរសម្រាប់ការរក្សាកិត្តិយសគ្រួសារ។

## ឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

២. ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

៣. ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

៤. ការនុវត្តន៍យុទ្ធសាស្ត្រចតុកោណ និង តំរូវការជំនួយអភិវឌ្ឍន៍

៥. ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

៦. សេចក្តីណែនាំស្តីពីនីតិវេជ្ជសាស្ត្រសម្រាប់ជំនួយដល់ការធ្វើកោសល្យវិច័យ រៀបរៀងដោយក្រុមការងារអន្តរក្រសួង(ក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ) ឆ្នាំ ២០០៦

៧. សៀវភៅនីតិព្រហ្មទណ្ឌទូទៅ លោកគ្រូកៅសីហា ឆ្នាំ២០១៣

៨. សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្ន វីរសេនីយ៍ទោ អាន សុវីដា ឆ្នាំ ២០១៤

៩. សៀវភៅនីតិព្រហ្មទណ្ឌថ្នាក់បរញ្ញាបត្រនីតិសាស្ត្រ រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ី សោភា

១០. មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចងក្រងដោយ លោក សឿន មុនីវ័ត្ន ព្រះរាជអាជ្ញារង ខេត្តកំពង់ធំ ឆ្នាំ ២០១១

១១. សៀវភៅ នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល អំណោយស្ថានទូតបារាំងឆ្នាំ ២០០៩

១២. សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយសាស្ត្រាចារ្យ អ៊ាន សំអាត ឆ្នាំ២០១៥

១៣. សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៧

១៤. សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៥

១៥. សៀវភៅ នីតិវិធីព្រហ្មទណ្ឌ របស់សាស្ត្រាចារ្យ អៀង សំណាង ឆ្នាំ២០១៥

១៦. សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកស្រី ឌី លីឡា និងលោក ខាន់ សុខា

១៧. គេហទំព័រលីកាដូ អំពីការរួចខ្លួនពីបទល្មើសៈ ការនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈក្នុងប្រព័ន្ធតុលាការកម្ពុជារបាយការណ៍ចេញផ្សាយ ខែវិច្ឆិកា ឆ្នាំ ២០១៥ សម្ព័ន្ធរដំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

# ឧបសម្ព័ន្ធ